មន្ទីរសន្តិសុខ
វត្តសំរោងក្នុង

គំនូរព្រាងនៃការចងចាំនៅក្នុងសៀវភៅនេះ ត្រូវបានគូរឡើង ក្រោយការដឹកនាំ និងសម្របសម្រួលផ្ទាល់ពីក្រុមបុគ្គលិកអង្គការយុវសន្តិភាព ដែលធ្លាប់ធ្វើកិច្ចការងារអប់រំស្រាវជ្រាវ និងអភិរក្សទីតាំងឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមអស់រយៈពេលជាច្រើនឆ្នាំនៅតាមសហគមន៍។

រូបគំនូរព្រាងនៃការចងចាំនៅក្នុងសៀវភៅនេះ គូរឡើងដោយអ្នកជំនាញផ្នែកគំនូរ អនុលោមតាមទិដ្ឋភាពជាក់ស្តែងជាមួយភស្តុតាងនៅសេសសល់ និងទិដ្ឋភាពរួមដែលរៀបរាប់ឡើងដោយជនរងគ្រោះជាច្រើននាក់ ត្រូវបានបូកបញ្ចូលគ្នាដោយផ្សារភ្ជាប់ទៅនិងបទពិសោធន៍ដែលពួកគាត់ធ្លាប់ត្រូវយោធាខ្មែរក្រហមចាប់បញ្ជូនខ្លួន សួរចម្លើយ ធ្វើទារុណកម្ម ឃុំឃាំង និងបង្ខំឱ្យធ្វើការងារក្នុងមន្ទីរសន្តិសុខមួយនេះ។

គំនូរព្រាងទាំងនេះ គឺបង្ហាញពីទិដ្ឋភាពដោយរួមបញ្ចូលទាំងទីកន្លែង ព្រឹត្តិការណ៍ តួរអង្គ និងពេលវេលា ដោយឆ្លងកាត់កិច្ចពិភាក្សាពិគ្រោះយោបល់ និងកែតម្រូវជាច្រើនលើកច្រើនសារ ជាមួយក្រុមជនរងគ្រោះក្នុងរបបខ្មែរក្រហម អាជ្ញាធរពាក់ព័ន្ធ អ្នកជំនាញផ្នែកប្រវត្តិសាស្ត្រ អ្នកជំនាញផ្នែកគូរគំនូរ និងបុគ្គលិកអង្គការរហូតទទួលបានស្នាដៃរួមចុងក្រោយ សម្រាប់ជាឯកសារៀនសូត្រអំពីប្រវត្តិមន្ទីរសន្តិសុខវត្តសំរោងក្នុង ក្នុងរបបខ្មែរក្រហម។

9 789924 975502

ប្រវត្តិសាស្ត្រខ្មែរក្រហម

មន្ទីរសន្តិសុខ
វត្តសំរោងក្នុង
១៩៧៥ - ១៩៧៩

គុកខ្មែរក្រហម
The Khmer Rouge PRISON

ប្រវត្តិសាស្ត្រខ្មែរក្រហម

ជំរុំឃុំឃាំងទី២១ ខណ្ឌ១៦ - ខណ្ឌ១៦

មន្ទីរសន្តិសុខ
វត្តសំរោងក្នុង
គុកខ្មែរក្រហម
១៩៧៥ - ១៩៧៩

ការសិក្សាស្រាវជ្រាវ និងការចងចាំ

ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ប្រវត្តិមន្ទីរសន្តិសុខវត្តសំរោងក្នុង (គុក)

អង្គការយុវសន្តិភាព

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ (៨៥៥) ២៣ ៨៨១ ៣៤០

សារអេឡិចត្រូនិចៈ director@yfpcambodia.org

គេហទំព័រៈ www.yfpcambodia.org

បណ្តាញទំនាក់ទំនងសង្គម

(Facebook, Twitter, YouTube)ៈ Youth For Peace- CAMBODIA

បុគ្គលិកស្រាវជ្រាវ

លោក សុខ គឿន　　លោក ម៉ន សុគឿន

កញ្ញា ខន រក្សា

យុវជនស្ម័គ្រចិត្តនៃក្រុមអ្នកស្រាវជ្រាវវ័យក្មេង

កញ្ញា គង់ កន្ធិកា　　លោក ហ៊ុន សេរីវឌ្ឍនា

កញ្ញា អ៊ុន រិទ្ធី　　លោក សារិន ខៃសុិញ

លោក សល់ រត្តនៈ　　លោក ហួត គីមហាក់

លោក សឿប ចិត្រា　　កញ្ញា ហ៊ាង នីកា

ត្រួតពិនិត្យដោយ

លោក កែវ ដួង　សាស្ត្រាចារ្យផ្នែកប្រវត្តិវិទ្យា
នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

សូមឧទ្ទិសស្មារដៃ

ជូនចំពោះជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិត
នៅទូទាំងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម។

បោះពុម្ពលើកទី១ ខែឧសភា ឆ្នាំ២០២៣
នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ISBN-13: 978-9924-9755-0-2

ផលិតដោយ
អង្គការយុវសន្តិភាព
Youth For Peace (YFP) Organization

ជំនួយទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ
Education Justice and Memory Network (EdJAM)

រក្សាសិទ្ធិគ្រប់យ៉ាង

ដោយអង្គការយុវសន្តិភាពមិនមានផ្នែកណាមួយនៅ
ក្នុងសៀវភៅនេះត្រូវបានចម្លង
ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី
អង្គការយុវសន្តិភាពឡើយ។

ផែនទីបង្ហាញទិដ្ឋភាពទីតាំងមន្ទីរសន្តិសុខ
វត្តសំរោងក្នុង (១៩៧៦-១៩៧៩)

កំណត់សម្គាល់

១. ប៉ុស្តិ៍ត្រួតពិនិត្យ
២. អគារសួរចម្លើយនៅកុដិឈើចាស់
៣. អគារឃុំឃាំងអ្នកទោសជាស្ត្រីនៅព្រះវិហារចាស់
៤. អគារឃុំឃាំងអ្នកទោសជាបុរសនៅសាលាធម្មសភា
៥. អគារឃុំឃាំងបណ្តោះអាសន្ននៅសាលាបាយ
៦. ចង្ក្រានដាំបាយ
៧. ស្រះទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ
៨. អគារសួរចម្លើយ និងធ្វើទារុណកម្មនៅកុដិថ្មចាស់
៩. កន្លែងងូតទឹកអ្នកទោស និងកន្លែងចាក់លាមក
១០. រណ្តៅសាកសពរួម
១១. អណ្តូងសម្លាប់កុមារ

មាតិកា

សេចក្តីថ្លែងអំណរគុណ i

អារម្ភកថា iii

ជំពូក១៖ សេចក្តីសង្ខេប

របបខ្មែរក្រហម ៣

មន្ទីរសន្តិសុខ ៧

មន្ទីរសន្តិសុខភូមិភាគពាយ័ព្យ ១០

ជំពូក២៖ បរិបទប្រវត្តិសាស្ត្រវត្តសំរោងក្នុង

១. ប្រវត្តិវត្តសំរោងក្នុងនៅមុនរបបខ្មែរក្រហម ១៥

២. ការចូលមកដល់របស់យោធាខ្មែរក្រហម ១៦

៣. ការធ្វើទុក្ខបុកម្នេញព្រះសង្ឃ ១៧

៤. ការរស់នៅរបស់ប្រជាជនជុំវិញវត្ត ១៩

ជំពូក៣៖ ការប្រែក្លាយទៅជាមន្ទីរសន្តិសុខវត្តសំរោងក្នុង

១. ការបង្កើតមន្ទីរសន្តិសុខ ២៣

២. រដ្ឋបាលមន្ទីរសន្តិសុខ ២៤

ជំពូក៤៖ ស្ថានភាពអ្នកទោស

១. ការចាប់ខ្លួន និងការឃុំឃាំងអ្នកទោស ២៩

២. ការសួរចម្លើយ និងការធ្វើទារុណកម្ម ៣១

៣. របបអាហារប្រចាំថ្ងៃរបស់អ្នកទោស ៣៣

៤. ការងាររបស់អ្នកទោស ៣៦

៥. ការសម្លាប់អ្នកទោស ៣៩

ជំពូក៥៖ ទិដ្ឋភាពមន្ទីរសន្តិសុខវត្តសំរោងក្នុង

១. ប៉ុស្តិ៍ត្រួតពិនិត្យ ៤៥

២. អគារសួរចម្លើយនៅកុដិឈើចាស់ ៤៨

៣. អគារឃុំឃាំងអ្នកទោសជាស្ត្រីនៅព្រះវិហារចាស់ ៥១

៤. អគារឃុំឃាំងអ្នកទោសជាបុរសនៅសាលាធម្មសភា ៥៥

៥. អគារឃុំឃាំងបណ្តោះអាសន្ននៅសាលាបាយ ៥៨

៦. ចង្ក្រានដាំបាយ ៦២

៧. ស្រះទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ៦៤

៨. អគារសួរចម្លើយ និងធ្វើទារុណកម្មនៅកុដិថ្មចាស់ ៦៧

៩. កន្លែងងូតទឹករបស់អ្នកទោស និងកន្លែងចាក់លាមក ៦៨

១០. រណ្តៅសាកសព ៧០

១១. អណ្តូងសម្លាប់កុមារ ៧២

ជំពូក៦៖ ថ្ងៃចុងក្រោយនៃមន្ទីរសន្តិសុខវត្តសំរោងក្នុង

១. ហេតុការណ៍ចុងក្រោយនៅក្នុងមន្ទីរសន្តិសុខ ៧៧

២. ស្ថានភាពវត្តក្រោយពេលយោធាចាកចេញ ៧៩

ជំពូក៧៖ ការជីករណ្តៅសាកសព និងការកសាងស្តូប

១. ការជីករណ្តៅសាកសពនៅកំឡុងឆ្នាំ១៩៨០ ៨៣

២. ការកសាងស្តូបតម្កល់អដ្ឋិធាតុ ៨៣

ជំពូក៨៖ ការអភិរក្សអតីតមន្ទីរសន្តិសុខវត្តសំរោងក្នុង

១. ការងារចងចាំ អប់រំ ផ្សព្វផ្សាយ និងការអភិរក្ស ៩៣

២. មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍ ៩៤

៣. មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍សំរោងក្នុង ៩៦

កំណត់ចំណាំ ១០០

និទ្ទានុក្រម ១០៩

សេចក្តីថ្លែងអំណរគុណ

អង្គការយុវសន្តិភាព សូមថ្លែងអំណរគុណចំពោះជនរងគ្រោះទាំងអស់រួមមាន អតីតអ្នកជាប់ឃុំឃាំង កុមារបម្រើការងារនៅទីនោះ ដោយបង្ខំ អតីតព្រះសង្ឃ អ្នកជួយសង្គ្រោះអ្នកទោស និងអ្នកដែលមានសាច់ញាតិជាប់ឃុំឃាំង ឬស្លាប់នៅក្នុងមន្ទីរសន្តិសុខវត្តសំរោងក្នុង សមាជិកក្រុមអ្នកសិក្សាស្រាវជ្រាវវ័យក្មេងដែលជាក្រុមនិស្សិតស្ម័គ្រចិត្ត ក្រុមបុគ្គលិកស្រាវជ្រាវរបស់អង្គការយុវសន្តិភាព សមាជិកគណៈកម្មការអភិរក្សទីតាំងឧក្រិដ្ឋកម្មវត្តសំរោងក្នុង និងអាជ្ញាធរមូលដ្ឋាន ដែលបានចូលរួមក្នុងដំណើរការសិក្សាស្រាវជ្រាវអំពីប្រវត្តិទីតាំង និងព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅក្នុងមន្ទីរសន្តិសុខវត្តសំរោងក្នុងកាលពីរបបប៉ុលពតខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

ក្នុងឱកាសនេះ ក៏សូមអរគុណចំពោះអគ្គនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សានៃក្រសួងអប់រំយុវជន និងកីឡា មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈមន្ទីរទេសចរណ៍ មន្ទីរធម្មការ និងសាសនាក្នុងខេត្តបាត់ដំបង អង្គភាពគាំពារជនរងគ្រោះ និងសហមេធាវីជាតិនាំមុខនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សាស្ត្រាចារ្យជំនាញផ្នែកប្រវត្តិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សារមន្ទីរឧក្រិដ្ឋកម្មទួលស្លែង និងមជ្ឈមណ្ឌលបុប្ផាណា ដែលបានចូលរួមក្នុងកិច្ចពិភាក្សាផ្តល់យោបល់លើលទ្ធផលនៃការស្រាវជ្រាវផងដែរ។

ជាចុងក្រោយក៏សូមអរគុណដល់ Education Justice and Memory Network (EdJAM) ដែលបានផ្តល់ជំនួយទ្រទ្រង់ផ្នែកហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ដំណើរការនៃការប្រព្រឹត្តិទៅនៃគម្រោងស្រាវជ្រាវប្រវត្តិមន្ទីរសន្តិសុខវត្តសំរោងក្នុងផងដែរ។

ការសិក្សាស្រាវជ្រាវនេះ ពិតជាមានតម្លៃធំធេងក្នុងការចងចាំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមសម្រាប់មនុស្សជាតិគ្រប់ជំនាន់បានសិក្សាឈ្វេងយល់បន្ត និងមិនអាចភ្លេចបាន។

អារម្ភកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយ សូមបង្ហាញនូវសៀវភៅ “មន្ទីរសន្តិសុខវត្តសំរោងក្នុង” ដែលជាស្នាដៃស្រាវជ្រាវថ្មីមួយបន្ថែមទៀតផលិតដោយអង្គការយុវសន្តិភាព ដោយរួមបញ្ចូលនូវប្រវត្តិសាស្ត្រ ទីតាំងនៃការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្មនៅក្នុងរបបខ្មែរក្រហម ជាមួយនិងសិល្បៈគំនូរព្រាងនៃការចងចាំ។ គោលបំណងនៃការស្រាវជ្រាវនិងចងក្រងសៀវភៅនេះ ដើម្បីធ្វើឱ្យចងចាំនូវបទពិសោធន៍អតីតកាល ការអភិរក្សទីតាំងប្រវត្តិសាស្ត្រខ្មែរក្រហមក្នុងស្មារតីចូលរួមថែរក្សាភស្តុតាង និងលើកកម្ពស់ការអប់រំឱ្យទូលំទូលាយសម្រាប់មនុស្សជំនាន់ថ្មីបានសិក្សាឈ្វេងយល់យូរអង្វែង ធ្វើយ៉ាងណាការពារកុំឱ្យកើតឡើងជាថ្មីម្តងទៀត។

សៀវភៅនេះ បានបង្ហាញអំពីទីតាំងភូមិសាស្ត្រនៃព្រឹត្តិការណ៍ដែលខ្មែរក្រហមបានប្រែក្លាយវត្តសំរោងក្នុងទៅជាមន្ទីរសន្តិសុខ (គុក) សម្រាប់ឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់មនុស្ស ដែលផ្ទុយស្រឡះមាគ៌ាព្រះពុទ្ធសាសនា។

សៀវភៅនេះ កើតឡើងបានដោយកិច្ចខិតខំប្រឹងប្រែងធ្វើការងារផ្គាល់ជាមួយអតីតអ្នកទោស កុមារបម្រើការងារដោយបង្ខំ អតីតព្រះសង្ឃ អ្នកជួយសង្គ្រោះ និងអ្នកដែលមានសាច់ញាតិជាប់ឃុំឃាំងឬស្លាប់នៅមន្ទីរសន្តិសុខវត្តសំរោងក្នុងអំឡុងរបបខ្មែរក្រហម បាននិយាយអំពីការពិត ដែលបានកើតឡើងនៅទីនោះ។ លើសពីនេះទៅទៀត កិច្ចការស្រាវជ្រាវនេះ ក៏បានរួមបញ្ចូលនូវប្រភពឯកសារ

ផ្សេងៗពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចម្លើយសារភាព របស់អ្នកទោសក្នុងមន្ទីរសន្តិសុខ ស-២១ និងស្នាដៃអ្នកជំនាញផ្នែក ប្រវត្តិសាស្ត្រមួយចំនួនទៀត។

គំនូរព្រាងនៃការចងចាំ ត្រូវបានគូស និងផ្ទៀងផ្ទាត់កែតម្រូវ ជាច្រើនសាពីអ្នកជំនាញ ដោយផ្អែកលើព័ត៌មានបង្ហាញដោយអតីត អ្នកជាប់ឃុំឃាំង អ្នកបម្រើការ និងអ្នកដែលបានចូលមកក្នុងមន្ទីរ សន្តិសុខនេះ តាមរយៈការសម្ភាសន៍ជាបុគ្គល ពិភាក្សាជាក្រុម និង ការចង្អុលបង្ហាញទីតាំងជាក់ស្តែង។

ក្រុមការងារស្រាវជ្រាវ បានជ្រើសរើសយុវជនស្ម័គ្រចិត្តមួយ ក្រុម គឺជាក្រុមអ្នកស្រាវជ្រាវវ័យក្មេង ដើម្បីចូលរួមកសាងស្នាដៃរួមគ្នា និងរៀនសូត្រអំពីប្រវត្តិសាស្ត្រទាំងឡាយ ដែលបានកើតឡើងក្នុងរបប សម័យខ្មែរក្រហម ជាពិសេសលើកិច្ចការងារស្រាវជ្រាវដោយផ្ទាល់។

ទោះយ៉ាងណាក្តី ខ្ញុំសូមអរគុណ ដល់អ្នកពាក់ព័ន្ធទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងថាមពលជាច្រើនក្នុង ការចូលរួមការស្រាវជ្រាវមួយនេះ។ ហើយក៏សូមអរគុណដល់អ្នក អានគ្រប់រូប ដែលបានអានសៀវភៅមួយនេះ។ នេះស្តែងឱ្យឃើញថា យើងទាំងអស់គ្នាកំពុងចូលរួមក្នុងកិច្ចការងារនៃការចងចាំ និងការពារ កុំឱ្យមានអំពើឧក្រិដ្ឋកម្ម និងជម្លោះដោយភាពហិង្សាកើតឡើងជាថ្មី ម្តងទៀត ដើម្បីបុព្វហេតុមួយនៃយុត្តិធម៌សង្គម ការអភិវឌ្ឍ និង សន្តិភាពសម្រាប់ទាំងអស់គ្នា។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣

ម៉ន សុគឿន

នាយកប្រតិបត្តិ

ជំពូក១

សេចក្តីសង្ខេប
អំពីរបបខ្មែរក្រហម

“ព្រឹត្តិការណ៍ ភូមិសាស្ត្រ និងមន្ទីរសន្តិសុខ (គុក)”



របបខ្មែរក្រហម

"ខ្មែរក្រហម" គឺជាឈ្មោះដែលសម្តេច នរោត្តមសីហនុ មានព្រះរាជបន្ទូលសំដៅលើក្រុមកុម្មុយនីស្តមួយក្រុមនៅកម្ពុជា ដែលប្រឆាំងនឹងការដឹកនាំប្រទេសរបស់ព្រះអង្គនៅទសវត្សរ៍១៩៦០ ហើយមានឈ្មោះផ្លូវការចុងក្រោយថា"បក្សកុម្មុយនីស្តកម្ពុជា"។[1]

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ឧត្តមសេនីយ៍ លន់ នល់ និង ព្រះអង្គម្ចាស់ ស៊ីវត្ថិ សិរីមតៈ បានដឹកនាំរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីដំណែងប្រមុខរដ្ឋ នៅពេលដែលព្រះអង្គ កំពុងគង់នៅទីក្រុងម៉ូស្គូនៃសហភាពសូវៀត ព្រោះតែការមិនពេញចិត្ត ការដឹកនាំនយោបាយ សង្គម និងការកើនឡើងនៃកងទ័ពវៀតណាម លើទឹកដីកម្ពុជាភាគខាងកើត។[2]

ថ្វីបើរដ្ឋប្រហារនេះ ទទួលបានការគាំទ្រពីសំណាក់ប្រជាជន មួយចំនួន ជាពិសេសក្រុមបញ្ញវន្តខ្មែរក៏ដោយ ក៏ប្រជាជននៅតាម ទីជនបទ ស្រុកស្រែចម្ការ នៅតែគោរពស្រលាញ់ និងមានភក្តីភាព ចំពោះសម្តេចព្រះនរោត្តម សីហនុ ដដែល ហើយក៏មិនពេញចិត្ត ចំពោះការធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គនោះឡើយ។ ប្រជាជនជាច្រើន បាននាំគ្នាចូលក្នុងព្រៃ (ព្រៃម៉ាគី) ចូលរួមចលនាជាមួយខ្មែរក្រហម ដើម្បីប្រមូលកម្លាំងប្រឆាំង និងរបបសាធារណរដ្ឋខ្មែរ ដែលដឹកនាំ ដោយ លន់ នល់។ ខ្មែរក្រហមបានសាបព្រោះផ្នត់គំនិតបដិវត្តន៍

សង្គមនិយម ក្រោមការដឹកនាំរបស់ក្រុមបញ្ជវន្តមួយក្រុមដែលប្រកាន់ភ្ជាប់នូវលទ្ធិម៉ាក់លេនីន ធ្វើជាមូលដ្ឋានក្នុងទស្សនវិស័យគ្រប់ជ្រុងជ្រោយរបស់ខ្លួន និងអនុវត្តគ្រប់សកម្មភាព។

ចលនាខ្មែរក្រហមបានរីកសាយភាយយ៉ាងលឿននៅតាមជនបទ។ ចលនាខ្មែរក្រហមបានត្រួតត្រាប្រទេសកម្ពុជាស្ទើរតែទាំងស្រុងតាំងពីមុនឆ្នាំ១៩៧៥ មកម្ល៉េះ លើកលែងនៅតាមទីប្រជុំជនមួយចំនួន និងក្រុងភ្នំពេញប៉ុណ្ណោះ។ ទន្ទឹមនឹងនោះ មន្ទីរសន្តិសុខ(គុក)មួយចំនួនត្រូវបានបង្កើតឡើងនៅក្នុងតំបន់ដែលខ្មែរក្រហមរំដោះបាន ដូចជាមន្ទីរសន្តិសុខ ម-១៣ នៅខេត្តកំពង់ស្ពឺ និងមន្ទីរសន្តិសុខក្រាំងតាចាន់ នៅស្រុកត្រាំកក់ ខេត្តតាកែវជាដើម។[៣]

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ផែនការដណ្តើមកាន់កាប់ក្រុងភ្នំពេញរបស់ខ្មែរក្រហមត្រូវបានទទួលជ័យជម្នះជាស្ថាពរ ដោយកងទ័ពខ្មែរក្រហមបានវាយចូលគ្រប់គ្រងទីក្រុងភ្នំពេញ។ ប្រជាជនរស់នៅទីក្រុងភ្នំពេញយ៉ាងហោចណាស់ចំនួនពីរលាននាក់ ត្រូវបានជម្លៀសដោយបង្ខំទៅទីជនបទនានា ក្នុងគោលបំណងដើម្បីឱ្យខ្មាំងចុះខ្សោយ ទាំងខ្មាំងខាងក្នុង ខ្មាំងខាងក្រៅ ទប់ស្កាត់ការងើបបះបោរ និងពង្រឹងសហការណ៍ លើកកម្ពស់វណ្ណៈកសិករ កម្មករ បំបាត់វណ្ណៈនាយទុន វណ្ណៈសក្តិភូមិ និងវណ្ណៈអនុធន គ្មានអ្នកមាន គ្មានអ្នកក្រ គ្មានអ្នកជិះជាន់ គ្មានអ្នកដែលត្រូវគេជិះជាន់ និងរួមគ្នាបង្កបង្កើនផលកសាងជាតិ ស្របតាមរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ដែលប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦។

ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រោមនយោបាយ “មហាលោតផ្លោះ មហាអស្ចារ្យ” ខ្មែរក្រហមបានកែទម្រង់ក្នុងការដឹកនាំប្រទេសជាបន្តបន្ទាប់ពីបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យទៅ

បដិវត្តន៍សង្គមនិយម និងឆ្ពោះទៅរកកុម្មុយនីស្តនិយម។[៤] ក្នុងនោះក៏មានគោលនយោបាយសំខាន់ៗមួយចំនួនត្រូវបានបង្កើត និងបានអនុវត្តន៍ជាបន្តបន្ទាប់រួមមានដូចជា (ទី១) ការផ្លាស់ទីលំនៅរបស់ប្រជាជនច្រើនលើកច្រើនសារ ពីទីប្រជុំជនទៅទីជនបទ និងពីទីជនបទមួយទៅកាន់ទីជនបទមួយទៀត។ (ទី២) ការបង្កើតការប្រតិបត្តិសហករណ៍ និងការដ្ឋាន។ (ទី៣) ការអប់រំ“សមាសភាពមិនល្អ” និងការកម្ទេច“ខ្មាំង”។ (ទី៤) ការកំណត់គោលដៅក្រុមមនុស្សជាក់លាក់នានាដូចជាជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក និងអតីតរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ រួមទាំងមន្ត្រីរាជការស៊ីវិល និងអតីតយោធា ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ។ (ទី៥) ការដាក់បទបញ្ជាបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍។[៥]

នៅដើមឆ្នាំ១៩៧៦ ផែនការបួនឆ្នាំត្រូវបានរៀបចំឡើងយ៉ាងប្រញាប់ក្នុងគោលបំណងសម្រេចឱ្យបានទិន្នផលជាតិជាមធ្យមបង្កបង្កើនផលស្រូវឱ្យបានបីតោនក្នុងមួយហិចតាសម្រាប់ប្រភេទដីស្រែធម្មតា និងប្រាំមួយតោន ទៅប្រាំពីរតោន ក្នុងមួយហិចតាលើប្រភេទដីលេខមួយ គឺដីមានជីជាតិ ហើយទិន្នផលត្រូវរំពឹងកើនឡើងរៀងរាល់ឆ្នាំបន្តបន្ទាប់។ ផ្ទុយទៅវិញ ផែនការនេះមិនបានសម្រេចនោះឡើយ ដោយផលស្រូវមិនបានឆ្លើយតបតាមផែនការ។ ស្ទើរតែគ្រប់កន្លែង ប្រជាជនត្រូវបង្ខំឱ្យធ្វើការងារច្រើន និងហូបតិចបំផុត[៦]។ ជាទូទៅ ហូបបបររាវៗមានគ្រាប់អង្ករត្រឹមកន្លះស្លាបព្រាបាយលាយជាមួយនឹងព្រលិត ឬត្រកួន ឬដើមចេកជាដើម ដែលក្នុងមួយថ្ងៃបានទទួលរបបអាហារចំនួនពីរពេល គឺអាហារពេលថ្ងៃត្រង់ និងអាហារពេលល្ងាច។

នៅក្នុងរបបខ្មែរក្រហមចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ មានការកាប់សម្លាប់មនុស្ស ការ

ធ្វើទារុណកម្ម ការរំលោភផ្លូវភេទ ការប្រើប្រាស់អំពើហិង្សាលើរូបរាងកាយ ការបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ ការធ្វើការងារដោយបង្ខំ ការបាត់ខ្លួន ការរើសអើង និងករណីអមនុស្សធម៌ផ្សេងៗទៀត។[៧] អ្នកជំនាញជាច្រើនបានទទួលយកការប៉ាន់ប្រមាណចំនួនអ្នកស្លាប់ពី ១.៥០០.០០០នាក់ ទៅ ២.០០០.០០០នាក់ ថាជាចំនួនត្រឹមត្រូវបំផុត។[៨] នៅឆ្នាំ២០០៨ មជ្ឈមណ្ឌលឯកសារកម្ពុជា បានរកឃើញចំនួនសាកសពមាន ១.៣០០.០០០នាក់ និងរណ្តៅសាកសពរួមចំនួន ៣៩០រណ្តៅ នៅទូទាំងប្រទេស។[៩] អ្នកជំនាញជាច្រើនបានសន្និដ្ឋានថាចំនួនអ្នកស្លាប់ និងចំនួនរណ្តៅសាកសពអាចខ្ពស់ជាងនេះ ដោយចំនួនរណ្តៅសាកសពរួមផ្សេងទៀតទំនងជាមិនបានរកឃើញ ហើយចំនួនអ្នកស្លាប់ជាច្រើនទៀតក៏មិនបានយកទៅកប់នៅក្នុងរណ្តៅដែរ។

របបខ្មែរក្រហមត្រូវបានដួលរលំក៏ដោយសារមូលហេតុមួយចំនួនរួមមាន ការដាក់ឱ្យអនុវត្តផែនការបួនឆ្នាំ (១៩៧៧-១៩៨០) បណ្តាលឱ្យប្រជាជនទ្រុឌទ្រោម ការធ្វើបន្សុទ្ធកម្មក្នុងជួរកម្មាភិបាលខ្មែរក្រហម ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦ និងការប៉ះទង្គិចគ្នាជាមួយវៀតណាមចាប់ពីឆ្នាំ១៩៧៧។ រហូតដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានវាយឈ្នះកងទ័ពខ្មែរក្រហមចូលកាន់កាប់ក្រុងភ្នំពេញបានទាំងស្រុង។ ចំណែកកងទ័ពខ្មែរក្រហមរួមជាមួយថ្នាក់ដឹកនាំបានដកថយសំដៅទៅនៅតាមខេត្តជាប់ព្រំដែនប្រទេសថៃ ដើម្បីធ្វើការតស៊ូប្រយុទ្ធបន្ត[១០]។

ក្រោយរបបខ្មែរក្រហម (កម្ពុជាប្រជាធិបតេយ្យ) ដួលរលំ មន្ទីរសន្តិសុខដែលបានរកឃើញមានចំនួន ១៩៦កន្លែង នៅទូទាំងប្រទេស បើយោងតាមមជ្ឈមណ្ឌលឯកសារកម្ពុជា។[១១]

មន្ទីរសន្តិសុខ

ចាប់ផ្តើមឆ្នាំ១៩៧១ មុនពេលបក្សកុម្មុយនីស្តកម្ពុជាឡើងកាន់អំណាចប្រព័ន្ធសន្តិសុខត្រូវបានបង្កើតឡើងនៅក្នុង “តំបន់រំដោះ” ក្នុងគោលបំណង កំណត់អត្តសញ្ញាណ និងកម្ទេចខ្មាំងខាងក្នុង ដើម្បីការពារផ្នែកសន្តិសុខផ្ទៃក្នុងតាមរយៈការលើកទឹកចិត្តឱ្យរាយការណ៍ពីគ្នា។ ពាក្យថា“មន្ទីរសន្តិសុខ”ជំនួសឱ្យពាក្យថា“គុក”ត្រូវបានហៅដោយខ្មែរក្រហម។ ខ្មែរក្រហមបានបង្កើតមន្ទីរសន្តិសុខជាបន្តបន្ទាប់ស្ទើរគ្រប់កន្លែងទូទាំងប្រទេស។ ទីតាំងមន្ទីរសន្តិសុខ ស្ថិតនៅតាមសាលារៀន វត្តអារាម អគាររដ្ឋ និងទីតាំងបង្កើតថ្មី។ មន្ទីរសន្តិសុខទាំងនោះ បានរៀបចំប្រព័ន្ធតាមដាននៅគ្រប់ជាន់ថ្នាក់សំដៅវែកមុខរាយការណ៍ និងកម្ទេចខ្មាំង។[12] ចំនួនអ្នកទោសជាច្រើនត្រូវបានចោទប្រកាន់ និងចាប់ខ្លួនបញ្ជូនទៅមន្ទីរសន្តិសុខទាំងនោះ ដើម្បីសួរចម្លើយ ឃុំឃាំង និងចុងក្រោយសម្លាប់ចោល។ ពាក្យថា“នាំយកទៅអប់រំ នាំយកទៅរៀនសូត្រ នាំយកទៅកសាង ឬប្តូរទៅកន្លែងថ្មី”ជាដើម គឺជាពាក្យដំបូងដែលខ្មែរក្រហមបាននិយាយញុះញង់ទៅកាន់អ្នកដែលត្រូវចាប់ខ្លួន ដើម្បីលាក់ការសម្ងាត់។

នៅក្នុងរចនាសម្ព័ន្ធនៃប្រព័ន្ធមន្ទីរសន្តិសុខ ត្រូវបានរៀបចំឡើងជាលំដាប់ថ្នាក់មានច្រាំកម្រិត។ ប្រព័ន្ធមន្ទីរសន្តិសុខថ្នាក់ទាបបំផុត គឺស្ថិតក្នុងសមត្ថកិច្ចកម្រិតឃុំ ឬសហករណ៍ដែលមានកងឈ្លបជាអ្នកបំពេញតួនាទីការពារសន្តិសុខនៅក្នុងមូលដ្ឋាន។ អ្នកទោស

ដែលត្រូវបានកងឈ្លបចាប់ និងឃុំខ្លួនមានចំនួនតិចតួចតែប៉ុណ្ណោះ ក្រោមការចោទពីបទលួចហូបអាហារ សមូហភាព និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់សមូហភាព ហើយត្រូវបានដោះលែងវិញក្រោយអប់រំ ឬឃុំខ្លួនក្នុងរយៈពេលខ្លី។ ក្នុងនោះក៏មានអ្នកទោសមួយចំនួនរកឃើញថាបានប្រព្រឹត្តិកំហុសធ្ងន់ត្រូវបានកងឈ្លបបញ្ជូនទៅមន្ទីរសន្តិសុខកម្រិតខ្ពស់ជាងនេះបន្ត។ មន្ទីរសន្តិសុខស្រុក និងមន្ទីរសន្តិសុខតំបន់ គឺជាប្រព័ន្ធមន្ទីរសន្តិសុខមានកម្រិតខ្ពស់ជាងថ្នាក់ឃុំ។ មន្ទីរសន្តិសុខទាំងពីរសំដៅចាប់អ្នកទោសកម្រិតធ្ងន់ ដូចជាអតីតមន្ត្រីរដ្ឋការ យោធាក្នុងរបប លន់ នល់ និងក្រុមខ្មែរក្រហមថ្នាក់ក្រោមមួយចំនួន ដែលជាប់ចោទពីបទកប្ប៉ត់ធ្វើឱ្យប៉ះពាល់ដល់បដិវត្តន៍។ លើសពីនេះក៏មានអ្នកទោសជាប្រជាជនសាមញ្ញ ដែលចោទពីបទល្មើសមួយចំនួនដូចជា ការលួច ការធ្វើដំណើរគ្មានការអនុញ្ញាត រត់ចោលជួរកងទ័ព និយាយអាក្រក់ពីអង្គការបដិវត្តន៍ និងការប្រព្រឹត្តខុសសីលធម៌ជាដើម។ មន្ទីរសន្តិសុខភូមិភាគ គឺជាមន្ទីរសន្តិសុខកម្រិតខ្ពស់ ជាងមន្ទីរសន្តិសុខស្រុក និងតំបន់ សម្រាប់ឃុំឃាំងអ្នកទោស ដែលជាអតីតកម្មាភិបាលខ្មែរក្រហម និងក្រុមគ្រួសាររបស់ពួកគេ ក្រោមការចោទប្រកាន់អំពីការប្រព្រឹត្តិកំហុសក្នុងកម្រិតភូមិភាគ ឬរកឃើញធ្លាប់ជាប់ពាក់ព័ន្ធ ឬធ្លាប់បម្រើការក្នុងរបប លន់ នល់ ជាដើម។ ឧទាហរណ៍ មន្ទីរសន្តិសុខភូមិភាគពាយ័ព្យស្ថិតនៅក្នុងក្រុងបាត់ដំបង និងនៅបន្ទាយនាងជាដើម។[១៣] មន្ទីរសន្តិសុខកម្រិតមជ្ឈិម គឺជាមន្ទីរសន្តិសុខកម្រិតខ្ពស់បំផុតដែលគេស្គាល់ថា“មន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង”។[១៤] អ្នកស្លាប់នៅមន្ទីរសន្តិសុខស-២១ មានចំនួន ១៨០៦៣នាក់។[១៥] ភាគច្រើននៃអ្នកទោសទាំងនោះគឺជាកម្មាភិបាល កងទ័ពខ្មែរក្រហម និងអ្នកជាប់ពាក់ព័ន្ធក្រោមបង្គាប់

ដែលរងការចោទប្រកាន់ និងបានចាប់បញ្ជូនមកក្រោមរូបភាពពីបទ
ក្បត់បដិវត្តន៍ ឬក្បត់បក្សកុម្មុយនីស្តកម្ពុជា។ មានអ្នកទោសមួយចំនួន
ត្រូវបានបញ្ជូនពីភូមិភាគពាយ័ព្យមកមន្ទីរសន្តិសុខស-២១ ផងដែរ។

ជាទូទៅរចនាសម្ព័ន្ធនៃប្រព័ន្ធមន្ទីរសន្តិសុខ បានបង្កើតឡើង
ជាប្រព័ន្ធអាចបញ្ជូនអ្នកទោសពីកម្រិតមួយទៅកម្រិតមួយទៀតបាន
តាមការកំណត់អត្តសញ្ញាណជាក់ស្តែងរបស់អ្នកទោស។ មន្ទីរសន្តិសុខ
មានកម្រិតកាន់តែខ្ពស់ដូចជាមន្ទីរសន្តិសុខ ស-២១ អត្រានៃការដោះ
លែងអ្នកទោសមិនមានទេ។

សម្រង់សម្តី

ប៊ុល ពត *បាននិយាយដោយផ្ទាល់នៅក្នុងសន្និបាតក្នុង
ឆ្នាំ១៩៧៦ ពាក់ព័ន្ធនឹងការបោសសម្អាតខ្មាំងនៅក្នុង
សហករណ៍ថា៖*

“ជាវិធានការជាច់ខាតឥតឈប់ឈរដើម្បីកម្ទេចខ្មាំង”

មន្ទីរសន្តិសុខភូមិភាគពាយ័ព្យ

ភូមិភាគពាយ័ព្យរួមបញ្ចូលខេត្តចំនួនពីរ គឺខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង។ កាលនោះ ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន ស្ថិតក្នុងទឹកដីរួមរបស់ខេត្តបាត់ដំបងនៅឡើយ។[១៦] ភូមិភាគពាយ័ព្យ ដឹកនាំដោយ មូល សម្បត្តិ ហៅ រស់ ញឹម គឺជាលេខាភូមិភាគ ហើយក៏ជាអ្នកបដិវត្តជើងចាស់មួយរូប ឈ្មោះ តាកន ហៅ កឹ ជាអនុលេខាភូមិភាគ និងឈ្មោះខាំ ជាសមាជិកភូមិភាគ។[១៧]

មន្ទីរសន្តិសុខភូមិភាគពាយ័ព្យ ត្រូវបានចាប់ផ្តើមបង្កើតនៅក្នុងឆ្នាំ១៩៧៦។ រស់ ញឹម បានដឹកនាំកិច្ចប្រជុំមួយជាមួយសមាជិកចូលរួមសំខាន់ៗរបស់ភូមិភាគនេះរួមមាន ឈ្មោះ សាន ឈ្មោះ អែម ឈ្មោះ កយ ឈ្មោះ ខ្លែង ឈ្មោះ ហំ ឈ្មោះ នូវ និងឈ្មោះខូយ ដែលទីកន្លែងប្រជុំនៅមន្ទីរសេនាធិការយោធា ដើម្បីពិភាក្សាអំពីការបង្កើតឱ្យមានមន្ទីរសន្តិសុខ។ រស់ ញឹម និយាយថា “ខ្ញុំហៅមិត្តទាំងអស់គ្នាមកនេះ ដើម្បីពិភាក្សាអំពីបញ្ហារៀបចំអង្គភាពសន្តិសុខមួយរបស់ភូមិភាគយើង ដើម្បីគិតគូរអំពីបញ្ហារបស់ប្រជាជនដែលបានរត់លួនពីកន្លែងមួយទៅកន្លែងមួយ។ ដូចនេះ រយៈពេលកន្លងមក យើងគ្មានអ្នកណាគិតគូរសោះ។ តែឥឡូវយើងត្រូវរៀបចំកម្មាភិបាលកងទ័ព និងកងនារីមួយកងអនុសេនាតូចសម្រាប់ការពារសន្តិសុខ។ ដូចនេះ យើងត្រូវរកកន្លែងណា ដែលស្ងាត់កុំឱ្យប្រជាជន ឬកម្មករមកនៅជិតកន្លែងសន្តិសុខនាំឱ្យបែកការ”។[១៨]

មន្ទីរសន្តិសុខភូមិភាគពាយ័ព្យបែងចែកជាពីរផ្នែកធំៗស្ថិតនៅទីតាំងពីរផ្សេងគ្នា គឺមន្ទីរសន្តិសុខភូមិភាគនៅក្រុងបាត់ដំបង និងមន្ទីរសន្តិសុខភូមិភាគនៅបន្ទាយនាង។ រចនាសម្ព័ន្ធទូទៅនៅក្នុងមន្ទីរសន្តិសុខភូមិពាគពាយ័ព្យមាន មិត្តម៉ៅ ជាប្រធាន មិត្តកយ(បួយ បឿន) ជាអនុប្រធាន និងមិត្តផៃ ជាសមាជិក។ មន្ទីរសន្តិសុខភូមិភាគនេះ បង្កើតឡើងដើម្បីជាក់ឃុំឃាំង សួរចម្លើយ និងកម្ទេចអ្នកទោសដែលបញ្ជូនមកពីមន្ទីរសន្តិសុខតំបន់ មន្ទីរសន្តិសុខស្រុក និងការចុះចាប់អ្នកទោសដោយផ្ទាល់ ដោយកងយោធាមន្ទីរសន្តិសុខ។[19]

មន្ទីរសន្តិសុខកម្រិតថ្នាក់ស្រុកត្រូវបានបង្កើតឡើងជាច្រើនកន្លែង នៅក្នុងភូមិភាគពាយ័ព្យ។ មន្ទីរសន្តិសុខវត្តសំរោងក្នុង គឺជាមន្ទីរសន្តិសុខកម្រិតថ្នាក់ស្រុក ស្ថិតក្នុងស្រុក៤១ តំបន់៤ មានឈ្មោះតឹក ម៉ន ហៅ រ៉ៃ ជាលេខាស្រុក និងឈ្មោះ ហៀ វ៉ាន់ ជាអនុលេខាស្រុក និងដាវ សឹង ហៅព្រំ ជាសមាជិក និងឈ្មោះឆោម ជាប្រធានឈ្លបស្រុក។[20] មន្ទីរសន្តិសុខនេះ ត្រូវបានយោធាខ្មែរក្រហមបង្កើតឡើងនៅដើមឆ្នាំ១៩៧៦ ជ្រកក្រោមរូបភាពជាវត្តអារាម ដោយយោធាខ្មែរក្រហមបានរៀបចំប្រែក្លាយវត្តសំរោងក្នុងទាំងមូល ឱ្យទៅជាកន្លែងឃុំឃាំង ធ្វើទារុណកម្ម សួរចម្លើយ និងសម្លាប់មនុស្សយ៉ាងសម្ងាត់។ ចាប់តាំងពីពេលបង្កើតរហូតដល់ថ្ងៃដួលរលំទៅវិញ មន្ទីរសន្តិសុខមួយនេះ ស្ថិតក្រោមការគ្រប់គ្រងដោយកងយោធាខ្មែរក្រហមផ្ទាល់។ មានមនុស្សចំនួនជាច្រើនត្រូវបានចាប់ខ្លួនបញ្ជូនមកកាន់មន្ទីរសន្តិសុខមួយនេះ ក្នុងរូបភាពជាអ្នកទោស។ អ្នកទោសចំនួន ១០០០៨នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តសំរោងក្នុងដែលតួលេខនេះយោងតាម លោកអាចារ្យ ធុន សុវត្ថិ ជាសាក្សីសំខាន់ដែលបានចូលមកក្នុងវត្តសំរោងក្នុងភ្លាមៗក្រោយពេលពួកយោធា

ខ្មែរក្រហមចាកចេញអស់ និងបានប្រទះឃើញបញ្ជីចំនួនអ្នកទោស
ដែលបានកត់ត្រាទុក។ យ៉ាងណាមិញពិតជាគួរឱ្យសោកស្តាយលោក
អាចារ្យមិនបានរក្សាទុកឯកសារទាំងនោះទេ។[២១]



ជំពូក២

បរិបទប្រវត្តិសាស្ត្រវត្ត សំរោងក្នុង

“មុនរបបខ្មែរក្រហម ការចូលមកដល់
នៃយោធាខ្មែរក្រហម ការធ្វើទុកបុកម្នេញ
ព្រះសង្ឃ និងស្ថានភាពរស់នៅ
របស់ប្រជាជនជុំវិញវត្ត”

គំនូរនេះបង្ហាញអំពីទិដ្ឋភាពរបស់ព្រះសង្ឃវត្តសំរោងក្នុង ជាច្រើនអង្គកំពុង ស្ងួងស្រូវ នៅក្នុងស្រែខាងលិចរបងវត្តនៅឆ្នាំ១៩៧៥។

១. ប្រវត្តិវត្តសំរោងក្នុងនៅមុនរបបខ្មែរក្រហម

វត្តសំរោងក្នុង មានទីតាំងនៅភូមិសំរោងក្នុង ឃុំសំរោងក្នុង ស្រុកឯកភ្នំ (អតីតស្រុកសង្កែ) ខេត្តបាត់ដំបង ស្ថិតក្នុងតំបន់ពាយ័ព្យ នៃប្រទេសកម្ពុជា មានចម្ងាយប្រមាណ ៣០០គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងប្រមាណ ៦គីឡូម៉ែត្រ ពីក្រុងបាត់ដំបងតាមបណ្តោយផ្លូវស្របដងស្ទឹងសង្កែទៅទិសខាងជើង។ ក្នុងប្រវត្តិសាស្ត្រ វត្តនេះ ត្រូវបានចាត់ទុកជាវត្តមានអាយុកាលចំណាស់មួយនៅក្នុងខេត្តបាត់ដំបង ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៧០៧ ក្នុងរូបភាពជំបូងជាអាស្រមរបស់ធុតង្គជ័យ ក្នុងអំឡុងនៃការគ្រប់គ្រងអំណាចរបស់គ្រួសារស្តេចគ្រាញ់ ចៅហ្វាយ ប៉ែន មកម្ល៉េះ ហើយក៏ជាកន្លែងស័ក្តិសិទ្ធិសម្រាប់បន់ស្រន់តាមអបិយជំនឿរបស់អ្នកស្រុក អ្នកភូមិ និងមន្ត្រី អ្នកមុខ អ្នកការ រហូតបានប្រែក្លាយជាវត្តអារាមសម្រាប់គោរពបូជាបែបព្រះពុទ្ធសាសនា ហើយបានចាក់ឫសយ៉ាងរឹងមាំនៅក្នុងសង្គមរហូតមកដល់សព្វថ្ងៃ។

ក្រោយព្រឹត្តិការណ៍នៃរដ្ឋប្រហារទម្លាក់ សម្តេចព្រះ នរោត្តម សីហនុ នាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ បានបង្ករជាសង្គ្រាមរវាងភាគីខ្មែរក្រហម និងភាគីសាធារណរដ្ឋខ្មែរ ដឹកនាំដោយ លន់ នល់ បានបំផ្លិចបំផ្លាញរចនាសម្ព័ន្ធសង្គមកម្ពុជាកាន់តែធ្ងន់ធ្ងរទៅៗក្នុងគោលដៅដណ្តើមគ្នាដឹកនាំប្រទេសកម្ពុជា។ អង្គការយូណេស្កូបានយកបម្រាមមកបិទក្នុងវត្តសំរោងក្នុងការពារវត្តបុរាណមួយនេះ ឱ្យរួចផុតពីការបំផ្លាញណាមួយ នៅពេលដែលឃើញវត្តអារាមប្រមាណ ៩០០

ត្រូវបានបំផ្លាញដោយយុទ្ធនាការទម្លាក់គ្រាប់បែកតាមផ្លូវអាកាស ពីសំណាក់សហរដ្ឋអាមេរិចមកលើប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៧០ ដល់ខែមិថុនា ឆ្នាំ១៩៧៣។[២២] ទោះជាយ៉ាងណាក្តី វត្តអារាមនេះ ត្រូវបានកងកម្លាំងសាធារណរដ្ឋខ្មែរប្រើប្រាស់ជាកន្លែងជួបប្រជុំកងទ័ពម្តងម្កាល ដើម្បីត្រៀមទៅសមរភូមិច្បាំងទប់ទល់ជាមួយការវាយប្រហារពីសំណាក់យោធាខ្មែរក្រហម។ ទិដ្ឋភាពវត្តនេះ សម្បូរដោយដើមដូងដាំដុះនៅក្បែរៗរបង និងសងខាងផ្លូវក្នុងវត្តជាមួយនឹងដើមឈើហូបផ្លែនានា និងដើមចេក។ នៅក្នុងបរិវេណវត្តមានសំណង់អគារសាងសង់អំពីថ្ម និងឈើប្រក់ក្បឿងស្រកាត្រី រួមមាន អគារព្រះវិហារ (ចាស់) អគារសាលាធម្មសភា អគារសាលាបាយ កុដិឈើធំមួយ និងមានកុដិតូចៗមួយចំនួនទៀត។ ក្រៅពីនេះ នៅមានប្រាង្គប្រាសាទចំណាស់សង់ពីឥដ្ឋតាន់ចំនួនពីរបន្ថែមទៀតរួមជាមួយស្រះទឹកចំនួនមួយផងដែរ។ វត្តនេះមានរបងសង់ពីឥដ្ឋកម្ពស់១.៥០ម៉ែត្រ លាតសន្ធឹងចាប់ពីចំហៀងនៃទិសខាងកើតរហូតដល់ខ្លោងទ្វារវត្តទិសខាងត្បូង និងបន្តដោយរបងធ្វើអំពីដែកលួសភ្ជាប់ជាមួយបង្គោលឈើខ្លឹម រហូតដល់ខាងក្រោយវត្តទិសខាងលិច។ ចំណែកខាងជើងជាប់ផ្លូវរទេះគោ ដីព្រៃ និងចម្ការអ្នកភូមិ ហើយមិនមានរបងត្រឹមត្រូវនោះទេ (បច្ចុប្បន្នរបងជុំវិញវត្តត្រូវបានរុះរើកសាងថ្មី)។ វត្តនេះត្រូវបានកំណត់ធ្វើជាទីតាំងស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងសំណុំរឿង០០២ ជាទីតាំងប្រព្រឹត្តកម្មលើពុទ្ធសាសនិកនៅកម្ពុជាផងដែរ។[២៣]

២. ការចូលមកដល់របស់យោធាខ្មែរក្រហម

នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានចូលកាន់កាប់ទីរួមខេត្តបាត់ដំបង បង្ខំភាគីសាធារណរដ្ឋខ្មែរឱ្យចុះចាញ់

និងចាប់ផ្តើមរៀបចំផែនការជម្លៀសប្រជាជនចេញពីទីរួមខេត្ត។[២៤] វេលាម៉ោងប្រហែល ២រសៀលនៅថ្ងៃដដែល យោធាខ្មែរក្រហមបានចូលមកដល់វត្តសំរោងក្នុង និងតំបន់ជុំវិញវត្ត។ ខណៈពេលនោះ នៅវត្តសំរោងក្នុង មានព្រះសង្ឃគង់ស្នាក់នៅជាធម្មតា ដែលមានព្រះតេជគុណ ទេស ថាំង (ចៅអធិការវត្ត) ព្រះតេជគុណ គឹម សេង (គ្រូសូត្រស្តាំ) និងព្រះតេជគុណ ឈន វ៉ាង (គ្រូសូត្រឆ្វេង) រួមជាមួយព្រះសង្ឃគង់នៅផ្សេងៗទៀតសរុបចំនួនប្រមាណ ៣០អង្គ។ ក្រៅពីព្រះសង្ឃដែលគង់ស្នាក់នៅវត្តអចិន្ត្រៃយ៍ក៏មានព្រះសង្ឃ និងមន្ត្រីសង្ឃមួយចំនួនផ្សេងទៀតរួមមានព្រះគ្រូ ងិន ប្លែក (ព្រះមេគុណស្រុកសង្កែ) ព្រះគ្រូថុន រុំ ព្រះតេជគុណ ធុន សុវត្ថិ (លោកអាចារ្យរ៉ៃ) និងព្រះតេជគុណ ឈិត រួម ជាដើម ដែលបានជម្លៀសព្រះកាយចាកចេញពីវត្តពោធិក្នុង (ស្ថិតក្នុងក្រុងបាត់ដំបងសព្វថ្ងៃ) មកគង់នៅក្នុងវត្តសំរោងក្នុងជាបណ្តោះអាសន្ន ក្រោយពេលទទួលដំណឹងអំពីផែនការជាក់លាក់ថាយោធាខ្មែរក្រហមនឹងចូលដល់ក្រុងបាត់ដំបងពីរឬបីថ្ងៃទៀត។ ក្នុងឆ្នាំ១៩៧៥ វត្តសំរោងក្នុងមិនទាន់ត្រូវបានប្រើប្រាស់ជាមន្ទីរសន្តិសុខភ្លាមៗនៅឡើយទេ អំឡុងពេលខ្មែរក្រហមចូលទៅដល់វត្តនេះដំបូង។ ក៏ប៉ុន្តែវត្តនេះ បានរឹតបន្តឹងមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងគោលបំណងប្រតិបត្តិព្រះពុទ្ធសាសនាទៀតឡើយ។[២៥]

៣. ការធ្វើទុក្ខបុកម្នេញព្រះសង្ឃ

នៅឆ្នាំ១៩៧៥ ព្រះសង្ឃនៅក្នុងវត្តសំរោងក្នុងទាំងអស់នៅតែទទួលបានការអនុញ្ញាតឱ្យគង់នៅក្នុងវត្តជាធម្មតា ប៉ុន្តែត្រូវទទួលរងការបង្ខិតបង្ខំឱ្យធ្វើការងារកសិកម្ម ធ្វើស្រែបង្កបង្កើនផលស្រូវនៅជាប់ខាងលិចរបងវត្ត និងដាំដំណាំផ្សេងៗមួយចំនួនទៀតនៅក្នុងបរិវេណវត្តជាដើម។ ចាប់ពីពាក់កណ្តាលខែមករា ដល់ខែមេសា

ឆ្នាំ១៩៧៦ ក្រោយរដូវច្រូតស្រូវរួច ព្រះសង្ឃវត្តសំរោងក្នុងទាំងអស់បូករួមព្រះសង្ឃដែលយោធាខ្មែរក្រហមប្រមូលមកពីវត្តផ្សេងៗមកដាក់នៅក្នុងវត្តសំរោងក្នុង សរុបប្រមាណ ៣០០អង្គ ត្រូវបានបញ្ជូនឱ្យទៅកសាងប្រព័ន្ធធារាសាស្ត្រ លើកទំនប់ ជីកប្រឡាយ នៅវាលអណ្តូងត្នោត (បច្ចុប្បន្នហៅថាប្រឡាយលោក) ដែលមានបណ្តោយ ១៥០០ម៉ែត្រ ទទឹង ៤ម៉ែត្រ និងជម្រៅ ២ម៉ែត្រ ស្ថិតនៅក្នុងភូមិសំរោងតាកុក ឃុំសំរោងក្នុង (បច្ចុប្បន្ន)។ ខ្មែរក្រហមបានបង្ខំព្រះសង្ឃឱ្យធ្វើការងាររហូតដល់ ១២ម៉ោងក្នុងមួយថ្ងៃ ចាប់ពីពេលព្រឹកព្រលឹមរហូតដល់ពេលព្រលប់ និងឱ្យចូលរួមប្រជុំជីវភាព ឬប្រជុំស្វ័យទិតៀនក្នុងមួយសប្តាហ៍ ១ដង ទៅ ២ដង បន្ទាប់ពីសម្រាកការងារ ដើម្បីស្តាប់ផែនការកសាង សង្គមនិយម តស៊ូកសាងសាមគ្គីភាពផ្ទៃក្នុងបដិវត្តន៍ និងការបញ្ចុះបញ្ចូលឱ្យព្រះសង្ឃលាចាកសិក្ខាបទដោយខ្លួនឯង ដោយបញ្ជាក់ប្រាប់ថាសង្គមនេះ អត់ត្រូវការសាសនា អត់មានព្រះសង្ឃ អត់មានបុណ្យបាបអ្វីទៀតទេ។[២៦]

ក្រោយមកដោយមិនអាចទ្រាំទ្រការធ្វើការហួសកម្លាំងឆាន់មិនគ្រប់គ្រាន់ ហើយថែមទាំងមិនសមស្របតាមក្បួនច្បាប់ធម៌វិន័យ ធ្វើឱ្យព្រះសង្ឃស្ទើរទាំងអស់ចាប់ផ្តើមលាចាកសិក្ខាបទបណ្តើរៗ។ ចុងក្រោយនៅមានព្រះសង្ឃតែ ១១អង្គ តែប៉ុណ្ណោះ ដែលមិនយល់ព្រមលាចាកសិក្ខាបទ និងស្ម័គ្រចិត្តចូលទៅព្រៃរនាមតាមវិធានការដាក់ទណ្ឌកម្មរបស់ខ្មែរក្រហម។ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៦ ទើបខ្មែរក្រហមចាប់ផ្សឹកព្រះសង្ឃទាំង ១១អង្គនោះ និងបញ្ជូនឱ្យទៅធ្វើការនៅតាមសហករណ៍នានា។[២៧] ក្រោយពីព្រះសង្ឃទាំងអស់ចាកចេញពីវត្ត យោធាខ្មែរក្រហមបានដាក់ទីតាំងប្រចាំការនៅក្នុងវត្តសំរោងក្នុងនេះតែម្តង និងមិនអនុញ្ញាតឱ្យមានអ្នកណាចេញចូល ឬ

ដើរឆ្លងកាត់ដូចមុនទៀតនោះទេ។

នៅក្នុងរបបខ្មែរក្រហម សាសនាទាំងឡាយរួមមានព្រះពុទ្ធសាសនា ឥស្លាមសាសនា និងសាសនាដទៃទៀត ត្រូវបានលុបបំបាត់ចោល ទោះបីជាមានការបញ្ជាក់ក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យថាប្រជាជនកម្ពុជាគ្រប់រូប មានសិទ្ធិជឿ ឬមិនជឿលើជំនឿសាសនាយ៉ាងណាក្តី។[២៨]

៤. ការរស់នៅរបស់ប្រជាជនជុំវិញវត្ត

នៅជុំវិញវត្តសំរោងក្នុងមានផ្ទះប្រជាជនរស់នៅរង្វើលៗពីគ្នាជាងសព្វថ្ងៃ ដែលមានផ្ទះខ្លះតូច ផ្ទះខ្លះធំ និងភាគច្រើនសង់ពីឈើប្រក់ក្បឿងស្រកាត្រី។ មិនយូរប៉ុន្មានបន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះក្នុងឆ្នាំ១៩៧៥ ប្រជាជនដែលរស់នៅជុំវិញនេះ ត្រូវបានបង្ខំឱ្យផ្លាស់ប្តូររបៀបរបបនៃការរស់នៅជាថ្មី ដោយបោះបង់ចោលនូវប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា តួនាទីក្នុងសង្គមចាស់ និងទ្រព្យសម្បត្តិឯកជនត្រូវបានដកហូត ដោយរៀបចំឱ្យរស់នៅបែបជាសមូហភាព នៅតាមសហករណ៍ ដែលត្រូវបានចាត់ទុកជាអង្គភាពចំណុះរបស់ឃុំ ហើយស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាភិបាលឃុំ។ ភាសាក្នុងការទំនាក់ទំនងហៅគ្នាត្រូវបានផ្លាស់ប្តូរដោយប្រើពាក្យ“សមមិត្ត”នៅដើមឈ្មោះជំនួសឱ្យពាក្យ យាយ តា អ៊ុំ ពូ មីង បង ប្អូន ជាដើម។ ការស្លៀកពាក់ត្រូវបានកំណត់យកសម្លៀកបំពាក់ពណ៌ខ្មៅ ក្រមាក្រឡាពណ៌សលាយពណ៌ក្រហម និងពាក់ស្បែកជើងកង់ឡាន (ធ្វើពីសំបកកង់ឡាន)។ មនុស្សនៅក្នុងសហករណ៍ក្បែវត្តត្រូវបង្ខំឱ្យធ្វើកសិកម្មឆ្ងាយពីវត្តសំរោងក្នុង។ ខ្មែរក្រហមយកផ្ទះអ្នកភូមិមួយចំនួននៅទិសខាងត្បូងវត្តសំរោងក្នុងប្រើប្រាស់សម្រាប់មនុស្សវ័យចំណាស់ៗដែលមិនអាចធ្វើការងារកើតឱ្យពួកគាត់រស់នៅ

មើលថែកុមារតូចៗ។ ចំណែកផ្ទះមួយចំនួនត្រូវបានរុះរើយកចេញ។ លើសពីនេះ មានកន្លែងខ្លះទៀត ត្រូវបានប្រើប្រាស់សម្រាប់ជាកន្លែងផលិតស្ករត្នោត។ សហការណ៍នៅជុំវិញវត្តសំរោងក្នុងមិនស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរសន្តិសុខក្នុងវត្តសំរោងក្នុងនោះទេ។[២៩]

ជំពូក៣

ការប្រែក្លាយវត្តសំរោងក្នុង ទៅជាមន្ទីរសន្តិសុខ (គុក)

“ការបង្កើតមន្ទីរសន្តិសុខ និងរដ្ឋបាលមន្ទីរ សន្តិសុខ”

ការប្រែក្លាយពី“**ឥត្តសំរោងក្នុង**”
ទៅជា“**គុក**”

១. ការបង្កើតមន្ទីរសន្តិសុខ

ចាប់ពីដើមឆ្នាំ១៩៧៦ យោធាខ្មែរក្រហមបានចូលមករៀបចំវត្តសំរោងក្នុងឱ្យទៅជាមន្ទីរសន្តិសុខ (គុក) ស្ថិតក្នុងភូមិសាស្ត្រ ភូមិសំរោងក្នុង ឃុំ៤ (ឃុំសំរោងក្នុង) ស្រុក៤១ (ក្នុងស្រុកសង្កែ) តំបន់៤ ភូមិភាគពាយ័ព្យ។ មន្ទីរសន្តិសុខនេះ ជាមន្ទីរសន្តិសុខក្នុងស្រុក៤១ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងចំណោមមន្ទីរសន្តិសុខដទៃទៀត នៅក្នុងភូមិភាគពាយ័ព្យ ហើយជាកន្លែងសម្ងាត់សម្រាប់ឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្ម និងចុងក្រោយកម្ទេចចោលរាល់អ្នកដែលត្រូវចាត់ទុកថាជាខ្មាំងប្រឆាំងបដិវត្តន៍។ ស្រុក៤១ ដឹកនាំដោយ តឹក ម៉ន ហៅ រ៉ៃ ជាលេខាស្រុក ហៀ វ៉ាន់ ជាអនុលេខាស្រុក និងដារ៉ សឹង ហៅព្រំ ជាសមាជិក។[៣០] ស្រុកនេះ គឺជាអង្គភាពសំខាន់មួយក្នុងឋានានុក្រមនៃរបបកម្ពុជាប្រជាធិបតេយ្យទទួលខុសត្រូវចំពោះសន្តិសុខផ្ទៃក្នុងរួមទាំងមានអំណាចអាចចាប់ និងសម្លាប់មនុស្ស នៅក្នុងរង្វង់សមត្ថកិច្ចក្នុងដែនដីរបស់ខ្លួនគ្រប់គ្រង និងរាយការណ៍ទៅថ្នាក់លើ ព្រោះមានមន្ទីរសន្តិសុខ។

ក្រោយពេលយោធាខ្មែរក្រហមប្រែក្លាយវត្តសំរោងក្នុងទៅជាមន្ទីរសន្តិសុខ ស្ថានភាពជុំវិញត្រូវបានរឹតបន្តឹងជាថ្មី លំនៅដ្ឋានប្រជាជនធ្លាប់រស់នៅជាប់របងវត្តតម្រូវឱ្យរុះរើ និងផ្លាស់ចេញឱ្យឆ្ងាយ ហើយហាមមិនឱ្យមានមនុស្សឆ្លងកាត់តំបន់ជុំវិញទីនេះជាដាច់ខាត។

២. រដ្ឋបាលមន្ទីរសន្តិសុខ

មន្ទីរសន្តិសុខវត្តសំរោងក្នុង មានរចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងយ៉ាងហ្មត់ចត់ដោយកងយោធាខ្មែរក្រហមពីរជំនាន់ផ្សេងគ្នា គឺជំនាន់ពាយ័ព្យ និងជំនាន់និរតី។[៣១]

ចាប់ពីពេលបង្កើតក្នុងឆ្នាំ១៩៧៦ រហូតដល់ចុងឆ្នាំ១៩៧៧ យោធាភូមិភាគពាយ័ព្យបានគ្រប់គ្រងមន្ទីរសន្តិសុខនេះ។ យោធាភូមិភាគពាយ័ព្យមានចំនួនប្រមាណ ១០នាក់ប៉ុណ្ណោះ ដែលភាគច្រើនជាបុរសមានវ័យជំទង់ ជាមួយភាពម៉ឺងម៉ាត់ ប្រកបដោយការប្រយ័ត្នប្រយែងខ្ពស់ មិននិយាយច្រើន មានភាពរហ័សរហួន និងហៅគ្នាដោយមិនសូវប្រើឈ្មោះចំៗនោះទេ។ អ្នកគ្រប់គ្រងទីនេះមានឈ្មោះ ស៊ន ហៅ សូត្រ ឈ្មោះនី ឈ្មោះ ផែង ឈ្មោះ លឿត និងមានឈ្មោះ ញឹក លួន ហៅ គោលោត ដែលតែងតែមានវត្តមានចេញចូលមកត្រួតពិនិត្យ និងពិភាក្សាការងារជាមួយអ្នកគ្រប់គ្រងនៅមន្ទីរសន្តិសុខមួយនេះជាប្រចាំ។

ចាប់ពីចុងឆ្នាំ១៩៧៧ ដល់ថ្ងៃដួលរលំនៃរបបខ្មែរក្រហម មន្ទីរសន្តិសុខវត្តសំរោងក្នុង ត្រូវបានបម្លែងមកឱ្យអ្នកថ្មីមកពីភូមិភាគនិរតីជាអ្នកគ្រប់គ្រងវិញម្តង ដោយមាន តា ម៉ុក ជាប្រធានភូមិភាគ។ ការផ្លាស់ប្តូរការគ្រប់គ្រងធ្វើឡើងខណៈពេលថ្នាក់ដឹកនាំសំខាន់ៗរួមជាមួយអ្នកពាក់ព័ន្ធផ្សេងៗជាច្រើននៅគ្រប់កម្រិតចាប់ពីថ្នាក់ឃុំ ស្រុក តំបន់ ភូមិភាគ និងក្នុងជួរកងទ័ពជាដើម នៅភូមិភាគពាយ័ព្យ រួមមានលេខា អនុលេខា សមាជិក ជំនួយការ នៅតាមសហករណ៍ ឃុំ ស្រុក តំបន់ មន្ទីរ ជួរកងទ័ព រោងចក្រ ត្រូវបានបោសសម្អាត និងមួយចំនួនត្រូវបានចាប់បញ្ជូនខ្លួនទៅមន្ទីរសន្តិសុខ ស-២១ (គុកទួលស្លែង) មានការកើនឡើង ដើម្បីសួរចម្លើយ ធ្វើទារុណកម្មបង្ខំឱ្យ

សារភាពអំពីខ្សែស្រឡាយក្បត់របស់ម្នាក់ៗ ហើយចុងក្រោយត្រូវបានសម្លាប់ចោល ដូចជា តឹក ម៉ន ហៅ រ៉ែ លេខាស្រុក៤១ ហៀវ៉ាន់ អនុលេខាស្រុក៤១ និង ដាវ សឹង ហៅព្រំ ជាសមាជិកស្រុក៤១ ជាដើម។[៣២] យោធាមកពីភូមិភាគនិរតីបានចូលមកគ្រប់គ្រងមន្ទីរសន្តិសុខវត្តសំរោងក្នុងជំនួសអ្នកគ្រប់គ្រងចាស់ ហើយអ្នកគ្រប់គ្រងនៅទីនេះកន្លងមកត្រូវបានពួកនិរតីបញ្ជូនតួនាទី និងមានការចាប់ខ្លួនជាបន្តបន្ទាប់ដូចជា ឈ្មោះ ញឹក លួន ហៅគោលោត ឈ្មោះនី និង ផែង ជាដើម។ នៅពេលពួកនិរតីគ្រប់គ្រងមន្ទីរសន្តិសុខសំរោងក្នុង មិនសូវរឹតត្បិតចំពោះអ្នកទោសប៉ុន្មានទេ ជាពិសេសអ្នកទោសស្រាលៗ ជាប្រជាជនសាមញ្ញ។ ចំនួនអ្នកទោសមានការថយចុះដោយសារអគារឃុំឃាំងមួយខ្នងត្រូវបានទុកចោល មិនមានដាក់ឃុំអ្នកទោសដូចមុនឡើយ។ ពួកនិរតីមានចំនួនប្រមាណ ១៥នាក់ ក្នុងនោះមានយោធាម្នាក់ឈ្មោះ យឹង ដែលបម្រើការងារ និងគ្រប់គ្រងនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង។ ពួកគេជាមនុស្សវ័យជំទង់ ហើយមានចំនួនស្ត្រីច្រើនជាងក្នុងជំនាន់ពាយ័ព្យគ្រប់គ្រង។[៣៣]

សម្រង់សម្ដីសាក្សី

ឆេង ម៉ៅ(ស្រី) ធ្លាប់ចូលក្នុងវត្តសំរោងក្នុងកំឡុងឆ្នាំ១៩៧៦ គាត់បាននិយាយថា៖

“ខ្ញុំបានរត់ចូលមកក្នុងមន្ទីរសន្តិសុខសំរោងក្នុង ដោយសារប្តីរបស់ខ្ញុំត្រូវបានគេចាប់មកទីនេះ។ ខ្ញុំបាននិយាយសុំពួកយោធាឱ្យលែងប្តីខ្ញុំ។ ខ្ញុំត្រូវបានគេដេញចេញពីវត្តភ្លាមៗ ហើយមិនបានចាប់ខ្ញុំឃុំនោះទេ។ ពេលខ្ញុំចូលមក ខ្ញុំឃើញយោធានៅក្នុងវត្តនេះប្រហែលជាង ១៥នាក់ប៉ុនហ្នឹង មានស្រីមានប្រុស”។

សម្រង់សម្តីសាក្សី

ឈាន គឿន (ប្រុស) អតីតកងកុមារ មានអាយុ១២ឆ្នាំ
គាត់បាននិយាយថា៖
“ជាញឹកញាប់ខ្ញុំបានឃើញគេបណ្តើរអ្នកទោសចូលជាហូរហែរ ចូលមកវត្តសំរោងក្នុង ដោយមានចងស្លាបសេកអ្នកទោសជាមួយខ្សែគោដាក់បន្តគ្នាជាបន្តបន្ទាប់ ហើយមានកម្មាភិបាល ឬក៏មានយោធាពីរនាក់មានស្ពាយកាំភ្លើង ដោយម្នាក់ដើរខាងមុខនិងម្នាក់ដើរខាងក្រោយ”។

ជំពូក៤

ស្ថានភាពអ្នកទោស

“ការចាប់ខ្លួន ការឃុំខ្លួន ការសួរចម្លើយ
ការធ្វើទារុណកម្ម ការសម្លាប់ ការធ្វើការងារ
និងរបបអាហារអ្នកទោស”

គំនូរនេះបង្ហាញអំពីទិដ្ឋភាពយោធាកំពុងបណ្តើរអ្នកទោសបួននាក់
មកមន្ទីរសន្តិសុខវត្តសំរោងក្នុង ដោយដៃជាប់ខ្សែចំណងបន្តគ្នា។

១. ការចាប់ខ្លួន និងឃុំឃាំងអ្នកទោស

អ្នកទោសភាគច្រើនត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរសន្តិសុខវត្តសំរោងក្នុងនៅចន្លោះឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨ ដោយយោធានិងកងឈ្លបឃុំ នៅអំឡុងពេលអង្គការបដិវត្តន៍បើកការស្រាវជ្រាវស្វែងរកចាប់ខ្លួនខ្មាំងបង្កប់ផ្ទៃក្នុង ដែលជាកិច្ចការចម្បងតាមរយៈឈ្លបយកការណ៍ និងការស្រង់ប្រវត្តិរូបជាញឹកញាប់ស្របតាមពាក្យស្លោក“ជីកស្មៅត្រូវជីកទាំងឫស”។ អ្នកទោសដែលចាប់បញ្ជូនមកមន្ទីរសន្តិសុខវត្តសំរោងក្នុងរួមមានអតីតប៉ូលីស យោធា និងសមាជិកក្រុមគ្រួសារ មន្ត្រីស៊ីវិល គ្រូបង្រៀន គ្រូពេទ្យ មេ ១០ខ្នង (មេក្រុម) មេ ៥០ខ្នង (មេឃុំ) និងបុគ្គលមានទ្រព្យសម្បត្តិស្តុកស្តម្ភនៅក្នុងរបបសាធារណរដ្ឋជាដើម។ លើសពីនេះ គឺមានអ្នកទោសជាប្រជាជនសាមញ្ញ រួមមានប្រជាជនថ្មី និងប្រជាជនចាស់ ដែលត្រូវបានចោទប្រកាន់ដូចជាខុសសីលធម៌ លួចស្រូវអង្ករ លួចចំណីអាហារ គេចវេសមិនគោរពការចាត់តាំង ឬមានកំហុសការងារដោយសារការធ្វើឱ្យខូចខាតរបស់របរសមូហភាពជាដើម ដែលជាទោសកំហុសប្រឆាំងនឹងបដិវត្តន៍។[៣៤]

អ្នកទោសថ្មីៗជាច្រើនត្រូវបានចាប់បញ្ជូនមកឃុំឃាំងជាបន្តបន្ទាប់នៅពេលព្រលប់ៗក្រោយពេលអ្នកទោសចាស់ៗត្រូវបានសម្លាប់ និងមានចំនួនតិចតួចត្រូវបានដោះលែងវិញដោយសារគ្មានកំហុស។ អ្នកទោសដែលបានបញ្ជូនមក ត្រូវចងដៃទៅក្រោយទាំង

សងខាង (ចងស្លាបសេក) ដោយខ្សែគោ ឬខ្សែអង្រឹង និងមានយោធា ពីរនាក់ ឬបីនាក់បណ្តើរមក។ ចំនួនអ្នកទោសដែលបានចាប់បញ្ជូន មក មានម្នាក់ៗ និងមកជាក្រុមៗ។ ជារឿយៗអ្នកទោសដែលបញ្ជូន មកជាក្រុមមានគ្នាចាប់ពី ពីរនាក់ទៅប្រាំនាក់ឬច្រើនជាងនេះ។ ដៃ របស់ពួកគាត់ ត្រូវបានចងស្លាបសេកភ្ជាប់ពីមនុស្សម្នាក់ទៅមនុស្ស ម្នាក់ទៀត ដោយប្រើខ្សែវែងមួយ។[៣៥] ទោះយ៉ាងនេះក្តី ក៏មានអ្នកទោស ខ្លះ ត្រូវបានចាប់ខ្លួនភ្លាមៗនៅទីតាំងនៅក្បែរមន្ទីរសន្តិសុខដោយមិន ប្រើខ្សែចងដៃ។[៣៦] ចំណែកអ្នកខ្លះ ដែលមានជំងឺ មិនអាចដើរបានក៏ ត្រូវបានយោធានាំគ្នាទៅលើកដាក់ក្នុងអង្រឹងសែងមក ឬដឹកជញ្ជូន តាមរទេះគោនាំចេញពីផ្ទះ ឬពីមន្ទីរពេទ្យ យកមកឃុំឃាំងទុកនៅក្នុង មន្ទីរសន្តិសុខវត្តសំរោងក្នុងដែរ។ ជាទូទៅអ្នកទោសជាស្ត្រីត្រូវឃុំ ឃាំងដាច់ដោយឡែកពីអ្នកទោសបុរស។[៣៧]

សម្រង់សម្តីសាក្សី

ឈ្មោង សូម (ប្រុស) ជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង បាននិយាយថា៖

"បីបួនថ្ងៃមុនថ្ងៃរំដោះ ខ្ញុំត្រូវខ្មែរក្រហមចាប់ដាក់ទីលាន បញ្ជាន់ស្រូវបឹងថ្ងាន់សហករណ៍ឃុំ។ នៅពេលយប់ប្រហែលម៉ោង ២ ទៅ ម៉ោង ៣ ខ្មែរក្រហមបានចាប់ខ្ញុំដាក់លើឡានដឹកសំដៅទៅគុកសំរោងក្នុង។ មកដល់ភូមិតាប៉ុនឡានខូច អញ្ចឹងទៅខ្មែរក្រហមឱ្យចុះដើរ។ នៅតាមផ្លូវ ដល់ភូមិតាកុក ឱ្យតែមានអ្នកចេញមកឈរតាមថ្នល់ ខ្មែរក្រហមចាប់វាយ ខ្ទោះទាំងអស់ គ្មានសួរអ្នកណាធ្វើអី! អ្នកនោះធ្វើអីទេ! ទម្រាំដើរមកដល់ គុកសំរោងក្នុងភ្លឺស្រាងហើយ។"

យោធានៃមន្ទីរសន្តិសុខ និងកងឈ្លបឃុំមានភាពខុសគ្នាក្នុងការចាប់ខ្លួនអ្នកទោស។ យោធាទទួលខុសត្រូវក្នុងការចាប់ចងអ្នកដែលពាក់ព័ន្ធជាមួយរបបចាស់(របបសាធារណរដ្ឋខ្មែរ) ដូចជាអតីតប៉ូលីស យោធា មន្ត្រីស៊ីវិល អ្នកមានស្តុកស្តម្ភ និងសមាជិកគ្រួសារ។ ចំណែកងយោធាឃុំ មានតួនាទីក្នុងការចាប់ចងអ្នកទោស ដែលបានប្រព្រឹត្តកំហុសនៅក្នុងឃុំឬក្នុងសហករណ៍ផ្ទាល់ និងអ្នកដែលបានប្រព្រឹត្តិខុសសីលធម៌(មនុស្សប្រុស ស្រីលួចស្រលាញ់គ្នា) ដែលចាត់ទុកថាជាអ្នកទោសកម្រិតធ្ងន់ធ្ងរ។[៣៨]

២. ការសួរចម្លើយ និងការធ្វើទារុណកម្ម

អ្នកទោសទាំងអស់ត្រូវបានបញ្ជូនចូលដល់ក្នុងបរិវេណវត្តសំរោងក្នុងត្រូវបានកត់ត្រាឈ្មោះ កាលបរិច្ឆេទបញ្ជូនចូល និងសួរចម្លើយជាបឋមជាមុន ដើម្បីកំណត់អត្តសញ្ញាណ និងប្រភេទនៃទោសកម្រិតធ្ងន់ ឬទោសកម្រិតស្រាល ឬគ្មានទោស មុននឹងធ្វើការសម្រេចបញ្ជូនទៅឃុំឃាំង ឬដោះលែងទៅវិញ។ ជាធម្មតាការសួរចម្លើយបឋម គឺប្រព្រឹត្តិទៅដោយមានយោធានៃមន្ទីរសន្តិសុខចំនួនពីរនាក់សហការក្នុងការសួរចម្លើយស្រង់ព័ត៌មានផ្ទាល់ខ្លួន។ ក្នុងចំណោមយោធាទាំងពីរនាក់ មានម្នាក់ជាអ្នកសួរចម្លើយ ហើយកត់ត្រាចម្លើយសារភាព និងម្នាក់ទៀតឈរនៅចំហៀងអ្នកទោសចាំការពារ។ អ្នកទោសអង្គុយលើកៅអីឈើ ដោយដាក់បាតដៃផ្ងារត្រួតលើគ្នា ឆ្លើយគ្រប់សំណួរ ដែលបានសួរ ដោយមិនទុកពេលឱ្យគិតយូរនោះទេ។ យ៉ាងណា មិញក៏មានអ្នកទោសមួយចំនួនមិនអនុញ្ញាតឱ្យអង្គុយដែរនៅពេលសួរចម្លើយលើកដំបូង។ រាល់ចម្លើយសារភាពទាំងអស់របស់អ្នកទោសម្នាក់ៗត្រូវបានកត់ត្រាដាក់ចូលនៅក្នុងសៀវភៅដោយប្រើប្រាស់បិចសរសេរ។[៣៩]



គំនូរនេះបង្ហាញអំពីទិដ្ឋភាពនៃការសួរចម្លើយអ្នកទោសដែលទើបបាន បញ្ជូនមកដល់ នៅក្រោមកុដិឈើ ដោយមានយោធាចំនួន ២នាក់ មាន ម្នាក់ជាអ្នកសួរចម្លើយ និងកត់ត្រា ហើយម្នាក់ទៀតជាអ្នកយាមការពារ។

ការសួរចម្លើយដោយមិនប្រើទារុណកម្មត្រូវបានធ្វើឡើង សម្រាប់អ្នកទោសកម្រិតស្រាល។ រីឯអ្នកទោសកម្រិតធ្ងន់ត្រូវបានយោធាចំនួនបីនាក់ ឬបួននាក់សហការគ្នាក្នុងការសួរចម្លើយដោយហិង្សាជាច្រើនលើកច្រើនសាក្នុងរយៈពេលពីរថ្ងៃម្តង ប្រសិនបើចម្លើយសារភាពមិនទាន់អាចយកជាការបាន។ យោធាទីមួយជាអ្នកសួរនិងកត់ត្រាចម្លើយសារភាព យោធាទីពីរជាអ្នកការពារ យោធាទីបី និងទីបួនជាអ្នកធ្វើទារុណកម្មដូចជាវាយដំ ទាត់ធាក់ ជាន់ក ឆក់ខ្សែចរន្តអគ្គិសនីបានមកពីការបញ្ឆេះម៉ូតូម៉ាក សេ អិល។ ជារឿយៗមានអ្នកទោសមួយចំនួនទៀត ទទួលរងការធ្វើទារុណកម្មធ្វើឱ្យថប់ដង្ហើម តាមរយៈការច្រកក្បាលចូលក្នុងថង់ប្លាស្ទិកពណ៌សថ្លា និងជ្រមុជក្បាលចូលទៅក្នុងពាងទឹក ជួនកាលសន្លប់បាត់ស្មារតីក៏មាន។[៤០]

៣. របបអាហារប្រចាំថ្ងៃរបស់អ្នកទោស

បបររាវៗជាមួយសម្លបន្លែ ដែលជាំដុះនៅក្នុងវត្តផ្ទាល់ គឺជារបបអាហារប្រចាំថ្ងៃរបស់អ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង។ ក្នុងមួយថ្ងៃមានចែករបបអាហារពីរពេលរួមមានអាហារពេលថ្ងៃត្រង់ និងអាហារពេលល្ងាច។ អ្នកទោសម្នាក់ៗ ទទួលបានបបរបីវែក ដែលមានគ្រាប់អង្ករប្រហែលមួយស្លាបព្រាបាយ ព្រោះបបរក្នុងមួយខ្នោះត្នោតជាក់អង្ករតែប្រាំកំប៉ុងតែប៉ុណ្ណោះ។ បន្ថែមពីលើបបររាវៗ អ្នកទោសបានទទួលបន្ថែមនូវសម្លបីវែកពុំមានជាក់សាច់អ្វីទាំងអស់ តែមានក្លិនប្រហុកតិចៗដូចជា សម្លត្រកួន សម្លស្ពៃជាដើម ដោយចុងភៅស្លឆ្លាស់គ្នារាល់ថ្ងៃ។ អ្នកខ្លះទទួលបានអាហារពេញចាន ហើយអ្នកខ្លះទៀតបានតែពាក់កណ្តាលចានប៉ុណ្ណោះ ដោយសារចុងភៅដួសចាក់ៗមិនយកចិត្តទុកដាក់ធ្វើឱ្យកំពប់ចេញពីចាន។[៤១]

ជារៀងរាល់ថ្ងៃ នៅវេលាម៉ោង ១១ថ្ងៃត្រង់ យោធាបានវាយ



គំនូរនេះបង្ហាញអំពីទិដ្ឋភាព អ្នកទោសកំពុងកាន់ចានមកទទួលយកចំណែក អាហារ សម្រាប់ហូបម្នាក់ម្តងៗ ដោយបានចំណែកស្មើគ្នា។ បន្ទាប់ពី ទទួលបានអាហារ ហើយត្រូវដើរយកទៅហូបក្នុងអគារឃុំឃាំងដែល ម្នាក់ៗជាប់ឃុំ។

ជួងជាសញ្ញាប្រាប់ថាដល់ពេលសម្រាកធ្វើការ និងប្រញាប់មកទទួលរបបអាហារ។ ជាធម្មតាអ្នកទោសស្រាលទាំងអស់ត្រូវឈរជាពីរជួរ ដោយម្នាក់ៗដៃកាន់ចាន និងស្លាបព្រារៀងៗខ្លួនជាស្រេច ដើរចូលទៅយកបបរ និងសម្លម្នាក់ម្តងៗ។ ពេលទទួលបានអាហាររួចអ្នកទាំងនោះ ត្រូវយកទៅហូបនៅក្នុងអគារ ដែលខ្លួនជាប់ឃុំឃាំង។ នៅម៉ោង ១រសៀល សំឡេងជួងបន្លឺឡើងម្តងទៀត ជាសញ្ញាប្រាប់ឱ្យអ្នកទោសទាំងអស់ចេញទៅធ្វើការ ហើយពួកគេត្រូវយកចាន ដែលបានដាក់អាហារយកទៅហូប និងស្លាបព្រាមកលាងទុកដាក់នៅកន្លែងដាក់ចានក្រោមកុដិឈើដូចដើមវិញ ហើយត្រូវចាំចាន និងស្លាបព្រារបស់ខ្លួន ចៀសវាងកុំឱ្យបាត់បង់ ឬច្រឡំគ្នា។ នៅម៉ោង ៥រសៀល យោធាវាយជួងម្តងទៀតជាសញ្ញាប្រាប់ឱ្យអ្នកទោសសម្រាកពីការងារ និងមកទទួលអាហារយកទៅហូបក្នុងកន្លែងឃុំឃាំងដដែល លុះព្រឹកឡើងដល់ម៉ោងធ្វើការត្រូវយកចានមកលាងទុកនៅកន្លែងដាក់ចានវិញដូចសព្វដង មុនចាប់ផ្តើមធ្វើការងារ។ ចំណែកអ្នកទោសធ្ងន់ជាប់ខ្នោះជើង មិនអាចទៅណាបាន តម្រូវឱ្យអ្នកទោសស្រាលចំនួនពីរនាក់ ដែលទទួលបានការចាត់តាំងដោយយោធានៅទីនោះ ធ្វើជាអ្នកយកអាហារទៅចែកឱ្យហូបនៅក្នុងកន្លែងឃុំឃាំងផ្ទាល់ជារៀងរាល់ថ្ងៃ ដោយម្នាក់ៗទទួលបានរបបអាហារពីរពេលក្នុងមួយថ្ងៃដូចអ្នកទោសស្រាលដែរ។[៤២]

៤. ការងាររបស់អ្នកទោស

អ្នកជាប់ទោសកម្រិតស្រាលនៅក្នុងមន្ទីរសន្តិសុខ ត្រូវបន្តអប់រំតាមរយៈការបង្ខំឱ្យធ្វើការងារ ដោយមានការយាមយ៉ាងតឹងរ៉ឹង។ ម៉ោងធ្វើការចាប់ផ្តើមពីម៉ោង ៧ព្រឹក ដល់ម៉ោង ១១ថ្ងៃត្រង់ និងបន្តធ្វើចាប់ពីម៉ោង ១រសៀល ដល់ម៉ោង ៥ល្ងាច។ ការងារទាំងនោះជាការងារកសិកម្មដូចជា ចិញ្ចឹមសត្វ (ជ្រូក គោ មាន់) ដាំដំណាំ ចិញ្ច្រាំដើមទន្ទ្រានខែត្រ ដើមចក ដើម្បីធ្វើជី សម្រាប់ដាំបន្លែ ដូចជាត្រសក់ ត្រកួន ស្ពៃ ល្ពៅ និងត្រឡាចជាដើម។ លើសពីនេះ នៅមានការងារផ្សេងទៀតដូចជា ដកជម្រះស្មៅក្នុងសួនបន្លែជាដើម ដែលទីតាំងធ្វើការងារស្ថិតក្នុងបរិវេណវត្តសំរោងក្នុងផ្ទាល់។ ចំណែកអ្នកទោសធូនរិញ មិនអនុញ្ញាតឱ្យចេញទៅណានោះទេ ពួកគាត់ត្រូវស្ថិតនៅក្នុងអគារឃុំឃាំងជានិច្ចទាំងថ្ងៃទាំងយប់។ ក្រៅពីម៉ោងធ្វើការងារអ្នកទោសទាំងអស់ត្រូវឃុំខ្លួននៅតាមអគារឃុំឃាំងដែលខ្លួនជាប់ឃុំ។[៤៣]

សម្រង់សម្តីសាក្សី

សុិប ស៊ីម (ស្រី) នៅក្នុងរបបខ្មែរក្រហមមានអាយុ ១៤ឆ្នាំ ស្ថិតក្នុងកងកុមារ។ គាត់ត្រូវបានចាប់ខ្លួន នឹងបញ្ជូនមកវត្តសំរោងក្នុង។ គាត់បាននិយាយថា៖

“ពួកខ្មែរក្រហមបានដើរជួបខ្ញុំ ហើយបានចោទខ្ញុំ ថាបានលួចកើបស្រូវអង្គការ ព្រោះឃើញបាទដៃខ្ញុំឡើងក្រហម។ ពួកគេបាននាំខ្ញុំចូលក្នុងវត្តសំរោងក្នុង ហើយបានសួរចម្លើយខ្ញុំនៅក្រោយកុដិឈើ។ ពួកគេបានសួរ អំពីឈ្មោះ បងប្អូន និងសួរពាក់ព័ន្ធនឹងរឿងចោទខ្ញុំជាដើម។ ខ្ញុំមិនត្រូវបានដាក់ខ្នោះទេ។ ការងាររបស់ខ្ញុំ គឺធ្វើជីដកស្មៅក្នុងរងស្ពៃជាដើម។ ខ្ញុំបានបាយហូបចំនួនពីរពេលក្នុងមួយថ្ងៃ។ ខ្ញុំបានជាប់ឃុំឃាំងនៅទីនោះរយៈពេលមួយខែ ហើយបានលួចរត់ចេញពីវត្តមុនថ្ងៃវាយរំដោះមួយថ្ងៃតែប៉ុនោះ”។



គំនូរនេះបង្ហាញអំពីទិដ្ឋភាពអ្នកទោសស្រាលៗ កំពុងដកស្មៅ និង ប្រមូលផលដំណាំ បន្ថែទៅក្នុងបរិវេណវត្តសំរោងក្នុង។

គំនូរនេះបង្ហាញអំពីទិដ្ឋភាពនៅខាងឆ្វេង មានអ្នកទោសជាស្ត្រី និង បុរសចំនួនពីរនាក់ ដែលកងយោធាពីរនាក់កំពុងបណ្តើរចេញទៅកន្លែង សម្លាប់ខាងក្រៅរបងវត្ត ច្រកទ្វារខាងជើង ដោយអ្នកទោសទាំងពីរ នាក់ត្រូវច្រកក្បាលទឹងថង់ប្លាស្ទិកពណ៌សថ្លា និងជជាប់ចំណង។ រូបខាងស្តាំ គឺជាសកម្មភាពអ្នកទោសកំពុងដកស្មៅបន្តែ។

៥. ការសម្លាប់អ្នកទោស

ក្នុងចន្លោះឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨ កំណើននៃការបញ្ជូនអ្នកទោសកម្រិតធ្ងន់ៗយកទៅសម្លាប់ចោលនៅតាមរណ្តៅសាកសពមានចំនួនច្រើនស្ទើររាល់ថ្ងៃ ស្របពេលដែលមានការចាប់ខ្លួនអ្នកទោសថ្មីៗបញ្ជូនមកមន្ទីរសន្តិសុខក៏កាន់តែមានចំនួនច្រើន។ អ្នកទោសដែលត្រូវយកទៅសម្លាប់អាចជាប់ឃុំឃាំងត្រឹមរយៈពេលប្រហែលដប់ថ្ងៃប៉ុណ្ណោះ (ពេលពាយ័ព្យគ្រប់គ្រង)។[៤៤] ជាទូទៅនៅតាមមន្ទីរសន្តិសុខថ្នាក់ស្រុក ត្រូវបញ្ជូនបញ្ជីឈ្មោះ និងចម្លើយសារភាពអ្នកទោសទៅថ្នាក់លើ គឺគណៈស្រុកធ្វើការត្រួតពិនិត្យ។បន្ទាប់មកបញ្ជីឈ្មោះអ្នកទោសត្រូវបានបញ្ជូនត្រលប់មកមន្ទីរសន្តិសុខវិញ ហើយអ្នកទោសដែលត្រូវយកទៅសម្លាប់ត្រូវគូសសញ្ញាខ្វែងបញ្ជាក់នៅក្បែរឈ្មោះ។ ចំណែកអ្នកទោសគ្មានសញ្ញាគូសខ្វែងនៅក្បែរឈ្មោះត្រូវបន្តធ្វើការអប់រំកែប្រែតាមរយៈការដាក់ការងារឱ្យធ្វើនៅក្នុងមន្ទីរសន្តិសុខផ្ទាល់។[៤៥] ការនាំអ្នកទោសយកទៅសម្លាប់ច្រើនប្រព្រឹត្តទៅនៅពេលព្រលប់ៗដោយមានយោធាចំនួនពីរនាក់ជាអ្នកចាប់ចងអ្នកទោសប្រុស ស្រី ចាស់ ក្មេង បណ្តើរចេញពីអគារឃុំឃាំងដើរសំដៅទៅកន្លែងសម្លាប់នៅដីទួលខាងក្រោយឆៀងខាងជើងវត្ត ដោយយោធាម្នាក់ដើរខាងមុខអ្នកទោសដៃកាន់កាំភ្លើងវែង ហើយម្នាក់ទៀតដើរខាងក្រោយអ្នកទោសដៃកាន់ដំបងឈើ។ ក្នុងចំណោមអ្នកទោសទាំងនោះ ក៏មានអ្នកទោសខុសសីលធម៌មួយចំនួនត្រូវបានយោធាចាប់ច្រកក្បាលចូលក្នុងថង់ប្លាស្ទិកពណ៌សថ្លាយ៉ាងជិត ដោយដៃជាប់ចំណងពេលបណ្តើរយកទៅសម្លាប់។[៤៦] មានមនុស្សចំនួន ២នាក់ ឈ្មោះ ឆែម គិ ហៅ នី និងម្នាក់ទៀត ឈ្មោះ ផែង គឺជាអ្នកទទួលខុសត្រូវសម្លាប់អ្នកទោសដោយវាយកញ្ជ្រឹងករ និងដំបងបូស្សី ឬ

ត្បូងចប ឬដំបងឈើ ឬកំណាត់ដែក ដែលមានដុំដែកមូលផ្សាជាប់ខាងចុង រួចហើយរុញទម្លាក់ចូលទៅក្នុងរណ្តៅតែម្តង។[៤៧]

សម្រង់សម្តីសាក្សី

រាន់ ថាន់ (ប្រុស) ជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង បាននិយាយថា៖

“ខ្ញុំបានដឹងអំពីការសម្លាប់មនុស្ស នៅពេលយោធាខ្មែរក្រហមដោះលែងខ្ញុំចេញពីព្រះវិហារ ហើយចាត់តាំងខ្ញុំឱ្យធ្វើជាចុងភៅវិញ។ មានយោធាចំនួនពីរនាក់ ជាអ្នកទទួលខុសត្រូវសម្លាប់មនុស្ស ហើយអ្នកទាំងពីរមកវត្តសំរោងក្នុងតែពេល ដែលមានអ្នកទោសត្រូវយកទៅសម្លាប់។ ក្រោយសម្លាប់អ្នកទោសរួចរាល់ ខ្ញុំឃើញដៃរបស់ពួកគេកាន់ប្រមាត់មនុស្ស សង្ស័យថាជាប្រមាត់អ្នកទោសមួយចំនួនដែលបានសម្លាប់ត្រូវវះយកប្រមាត់”។



គំនូរនេះបង្ហាញអំពីទិដ្ឋភាពយោធាកំពុងចាប់អ្នកទោសច្រកថង់ប្លាស្ទិក ពណ៌សថ្លា រហូតសន្លប់បាត់ស្មារតី នៅត្រង់ចំណុចទីតាំងចន្លោះ អគារ សាលាធម្មសភា និងសាលាបាយ។

ជែនទីបង្ហាញទិដ្ឋភាពទីតាំងមន្ទីរសន្តិសុខ វត្តសំរោងក្នុង (១៩៧៦-១៩៧៩)

កំណត់សម្គាល់

១. ប៉ុស្តិ៍ត្រួតពិនិត្យ
២. អគារសួរចម្លើយនៅកុដិឈើចាស់
៣. អគារឃុំឃាំងអ្នកទោសជាស្ត្រីនៅព្រះវិហារចាស់
៤. អគារឃុំឃាំងអ្នកទោសជាបុរសនៅសាលាធម្មសភា
៥. អគារឃុំឃាំងបណ្តោះអាសន្ននៅសាលាបាយ
៦. ចង្ក្រានដាំបាយ
៧. ស្រះទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ
៨. អគារសួរចម្លើយ និងធ្វើទារុណកម្មនៅកុដិថ្មចាស់
៩. កន្លែងងូតទឹកអ្នកទោស និងកន្លែងចាក់លាមក
១០. រណ្តៅសាកសពរួម
១១. អណ្តូងសម្លាប់កុមារ

ជំពូក៥

ទិដ្ឋភាពក្នុងមន្ទីរសន្តិសុខ វត្តសំរោងក្នុង

“ទីតាំងប៉ុស្តិ៍ត្រួតពិនិត្យ ទីតាំងធ្វើទារុណកម្ម ទីតាំងឃុំឃាំង កន្លែងស្នាក់នៅរបស់យោធា កន្លែងដាំបាយ ស្រះទឹក កន្លែងងូតទឹក កន្លែងចាក់លាមក និងទីតាំងរណ្តៅសាកសព”

ឈ្វេងយល់អំពីទីតាំងទាំង ១១កន្លែង
ដែលខ្មែរក្រហមបានរៀបចំនៅវត្តសំរោងក្នុង
នៅអំឡុងពេលវត្តនេះក្លាយជាមន្ទីរសន្តិសុខ (គុក)។

១. ប៉ុស្តិ៍ត្រួតពិនិត្យ
២. អគារសួរចម្លើយនៅកុដិឈើចាស់
៣. អគារឃុំឃាំងអ្នកទោសជាស្ត្រីនៅព្រះវិហារចាស់
៤. អគារឃុំឃាំងអ្នកទោសជាបុរសនៅសាលាធម្មសភា
៥. អគារឃុំឃាំងបណ្តោះអាសន្ននៅសាលាបាយ
៦. ចង្ក្រានដាំបាយ
៧. ស្រះទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ
៨. អគារសួរចម្លើយ និងធ្វើទារុណកម្មនៅកុដិថ្មចាស់
៩. កន្លែងងូតទឹកអ្នកទោស និងកន្លែងចាក់លាមក
១០. រណ្តៅសាកសពរួម
១១. អណ្តូងសម្លាប់កុមារ

១. ប៉ុស្តិ៍ត្រួតពិនិត្យ

មុននឹងចូលទៅដល់មន្ទីរសន្តិសុខវត្តសំរោងក្នុង មានប៉ុស្តិ៍ត្រួតពិនិត្យមួយនៅច្រកចូលខាងត្បូងវត្ត ដែលមានចម្ងាយប្រមាណ ៣០ម៉ែត្រពីរបងវត្ត ស្ថិតនៅលើចិញ្ចើមផ្លូវខាងស្តាំដៃ បើធ្វើដំណើរចេញពីក្នុងវត្ត។ ដំបូងឡើយទីនេះ យោធាបានយកផ្ទះប្រជាជនធ្វើជាមន្ទីរពេទ្យ បន្ទាប់មកយកធ្វើជាផ្ទះរបស់កម្មាភិបាលខ្មែរក្រហមវិញ ហើយខាងមុខផ្ទះនោះ គឺជាប៉ុស្តិ៍ត្រួតពិនិត្យច្រកចេញចូលមន្ទីរសន្តិសុខ ដោយមានរនាំងរាំងផ្លូវអាចទាញបិទបើកបាន។ ប៉ុស្តិ៍ត្រួតពិនិត្យដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យសំបុត្រ និងផ្តល់ព័ត៌មានដល់អ្នកនៅខាងក្នុងមន្ទីរសន្តិសុខ ខណៈពេលមានថ្នាក់ដឹកនាំសំខាន់ៗអញ្ជើញមក។ លើសពីនេះទៀត ប៉ុស្តិ៍ត្រួតពិនិត្យនេះ ក៏ជាគោលដៅហាមឃាត់មិនឱ្យប្រជាជនឆ្លងកាត់តំបន់នេះជាដាច់ខាត។ លើកលែងអ្នកមានសំបុត្រស្នាមបញ្ជាក់ពីថ្នាក់លើត្រឹមត្រូវ គឺអនុញ្ញាតឱ្យឆ្លងកាត់បាន។ យោធាមន្ទីរសន្តិសុខប្រើកុមារអាយុ ១៣ឆ្នាំម្នាក់ ដែលជ្រើសរើសយកចេញពីកងកុមារមកជួយធ្វើជាអ្នកអានលិខិតនានារបស់អ្នកសុំឆ្លងកាត់ឱ្យយោធានៅប៉ុស្តិ៍ត្រួតពិនិត្យស្តាប់ រួចរត់ទៅប្រាប់កងយោធានៅខាងក្នុងមន្ទីរប្រសិនបើមានភ្ញៀវមករកជួប។ យោធាយាមប្រចាំការនៅទីនេះ ត្រូវបួរវេនគ្នា ដោយពេលព្រឹកមានយោធាចំនួនពីរនាក់ និងពេលរសៀលមានយោធាចំនួនពីរនាក់ផ្សេងទៀតមកជំនួស។ គួរបញ្ជាក់ផងដែរថា ប៉ុស្តិ៍ត្រួតពិនិត្យនេះមានតែនៅក្នុងជំនាន់យោធាភូមិភាគពាយ័ព្យគ្រប់គ្រងប៉ុណ្ណោះ។ នៅពេលយោធាភូមិភាគនិរតីគ្រប់គ្រង គឺមិនមានប៉ុស្តិ៍ត្រួតពិនិត្យបែបនេះទៀតទេ។[៤៨]

សម្រង់សម្ដីសាក្សី

ឈាន គឿន (ប្រុស) អតីតកងកុមារ និងជាអ្នកអានសំបុត្រនៅប៉ុស្ដិ៍ត្រួតពិនិត្យ បាននិយាយថា៖

“កាលនោះខ្ញុំមានអាយុ១២ឆ្នាំ ខ្ញុំដើរលេសគួរស្រូវពីក្រោយយុវជនដែលច្រូតនៅខាងមុខ និងជាអ្នកកាប់ ទន្ទ្រានខែត្រធ្វើដី។ ក្រោយមកដោយសារខ្ញុំចេះអក្សរ អាចអានអក្សររួច ទើបត្រូវយោធាខ្មែរក្រហមជ្រើសរើសខ្ញុំមកឱ្យចាំនៅប៉ុស្ដិ៍យាមជាមួយពួកគេដែលមានទីតាំងនៅផ្លូវចូលវត្តទិសខាងត្បូង។ គេប្រើខ្ញុំឱ្យអានសំបុត្រឱ្យពួកគេស្ដាប់ ហើយរត់ប្រាប់ដំណឹងដល់យោធានៅខាងក្នុងវត្ត។ យោធាអនុញ្ញាតឱ្យខ្ញុំអាចដើរពីទីតាំងប៉ុស្ដិ៍យាមចូលទៅខាងក្នុងវត្តបានត្រឹមកុដិឈើតែប៉ុណ្ណឹងទេ ដើម្បីផ្ដល់ដំណឹងដល់អ្នកខាងក្នុង ពេលមានភ្ញៀវមក។ នៅពេលពួកយោធានិរតីចូលមក ខ្ញុំមិនបានធ្វើការងារ នេះទៀតទេ ហើយទីនេះក៏អត់មានប៉ុស្ដ៍ត្រួតពិនិត្យអីទៀតដែរ”។

គំនូរនេះបង្ហាញអំពីទិដ្ឋភាពនៃប៉ុស្ដិ៍ត្រួតពិនិត្យនៅខាងត្បូងខ្លោងទ្វារវត្តសំរោងក្នុង។ គំនូរនេះ មានមនុស្សចំនួនបីនាក់ ដែលពីរនាក់ជាយោធាខ្មែរក្រហម និងម្នាក់ទៀតជាកុមារ ដែលត្រូវបានយោធាខ្មែរក្រហម ប្រើឱ្យធ្វើការងារនៅទីនោះផ្ទាល់ ដើម្បីជួយត្រួតពិនិត្យសំបុត្រ និងបញ្ជូនដំណឹងទៅប្រាប់អ្នកខាងក្នុង។ ប៉ុស្ដិ៍យាមនេះ មានតែនៅក្នុងជំនាន់យោធាពាយ័ព្យគ្រប់គ្រងប៉ុណ្ណោះ (១៩៧៦-១៩៧៧)។



គំនូរនេះបង្ហាញអំពីទិដ្ឋភាពនៃប៉ុស្តិ៍ត្រួតពិនិត្យនៅខាងត្បូងខ្លោងទ្វារវត្តសំរោងក្នុង។ គំនូរនេះ មានមនុស្សចំនួនបីនាក់ ដែលពីរនាក់ជាយោធាខ្មែរក្រហម និងម្នាក់ទៀតជាកុមារ ដែលត្រូវបានយោធាខ្មែរក្រហម ប្រើឱ្យធ្វើការងារនៅទីនោះផ្ទាល់ ដើម្បីជួយត្រួតពិនិត្យសំបុត្រ និងបញ្ជូនដំណឹងទៅប្រាប់អ្នកខាងក្នុង។ ប៉ុស្តិ៍យាមនេះ មានតែនៅក្នុងជំនាន់យោធាពាយ័ព្យគ្រប់គ្រងប៉ុណ្ណោះ (១៩៧៦-១៩៧៧)។

២. អគារសួរចម្លើយនៅកុដិឈើចាស់

យោធានៅក្នុងមន្ទីរសន្តិសុខវត្តសំរោងក្នុង បានយកកុដិឈើធំប្រក់ក្បឿង ធ្វើផុតពីដី ដោយមានដំបូលសំយ៉ាបទៅទិសខាងកើត និងខាងជើង ស្ថិតនៅជ្រុងខាងជើងឆៀងខាងកើតនៃជ្រុងព្រះវិហារថ្មី (បច្ចុប្បន្នរុះរើយកដីកសាងព្រះវិហារថ្មី) សម្រាប់ប្រើប្រាស់ដូចជា៖

- ទីតាំងសួរចម្លើយអ្នកទោសថ្មី

អ្នកទោសកំហុសស្រាល និងអ្នកទោសទើបបញ្ជូនចូលមកមន្ទីរសន្តិសុខថ្មីៗត្រូវបាននាំទៅសួរចម្លើយនៅខាងក្រោមកុដិឈើនេះ។ ទីតាំងសួរចម្លើយស្ថិតនៅខាងក្រោមកុដិឈើផ្ទាល់ មានតុមួយកៅអីពីរ ហើយយោធាចំនួន ២នាក់ មានម្នាក់អង្គុយនៅទល់មុខអ្នកទោស គឺជាអ្នកសួរចម្លើយ និងកត់ត្រារាល់អ្វីដែលត្រូវការ ហើយម្នាក់ទៀតឈរនៅជិតៗនោះដែរ។ ជាទូទៅសួរអំពីឈ្មោះ អាយុ ទីកន្លែងរស់នៅ ឪពុកម្តាយ ក្រុមគ្រួសារ ហើយសួរពីបទល្មើស ព្រមទាំងមូលហេតុនៃការប្រព្រឹត្តិផងដែរ។ ក្រោយបញ្ចប់ការសាកសួររួចរាល់ឃើញថាមានកំហុស អ្នកទោសត្រូវនាំទៅដាក់ក្នុងអគារឃុំឃាំងណាមួយទៅតាមការកំណត់របស់ពួកយោធា។

- ចង្ក្រានដាំស្ករនៅរដូវភ្លៀង

នៅរដូវភ្លៀងធ្លាក់ ទីតាំងចង្ក្រានបាយនៅខាងក្រៅក្បែរកុដិនេះ ត្រូវបានប្តូរមកធ្វើនៅខាងក្រោមកុដិវិញ ដើម្បីការពារភ្លៀង។ ដីត្រូវបានជីក ដើម្បីធ្វើជាចង្ក្រានដុតអុសសម្រាប់ដាំបាយ និងស្ករសម្រប់ថ្ងៃ។ នៅពេលផុតរដូវភ្លៀង ទីតាំងចង្ក្រានបាយនេះ ត្រូវរើទៅកន្លែងដើមវិញ ដែលស្ថិតនៅក្បែរកុដិនេះឯង។

គំនូរនេះបង្ហាញអំពីទិដ្ឋភាពនៅកុដិឈើ ដែលជាកន្លែងធ្វើការ និង ស្នាក់នៅរបស់ យោធាខ្មែរក្រហមដែលកំពុងបំរើការងារនៅទីនេះ ហើយក៏ជាកន្លែងសម្រាប់សួរចម្លើយអ្នកទោសដែលចូលមកដំបូងៗ ឬអ្នកទោសស្រាលផងដែរ។ នៅក្នុងរូបនេះមានមនុស្សចំនួន ៥នាក់ ដែល ៣នាក់ ជាយោធា និងម្នាក់ទៀតជាអ្នកទោសកំពុងត្រូវបាន យោធា ២នាក់ឱ្យអង្គុយដើម្បីសួរចម្លើយ។

- កន្លែងស្នាក់នៅ និងកន្លែងធ្វើការរបស់យោធា

ឡើងតាមជណ្តើរធ្វើពីឈើទៅជាន់ខាងលើ គឺជាកន្លែងធ្វើការ កន្លែងស្នាក់នៅ និងទុកដាក់សម្ភារៈប្រើប្រាស់របស់កងយោធាមន្ទីរសន្តិសុខ។ យោធាបានប្រើប្រាស់អង្រឹងចងភ្ជាប់ពីសសរមួយទៅសសរមួយទៀត ដើម្បីដេក ឬអង្គុយ។ លើសពីនេះទៀត នៅលើកុដិនេះគឺជាកន្លែងទទួលភ្ញៀវពីខាងក្រៅ ជួបជជែកអំពីកិច្ចការផ្សេងៗដូចជាឈ្មោះ ញឹក លួន ហៅ គោលោត ជាដើម។[៤៩]

សម្រង់សម្តីសាក្សី

ស៊ិប ស៊ីម អតីតអ្នកទោសម្នាក់ នៅមន្ទីរសន្តិសុខវត្តសំរោងក្នុង បាននិយាយថា៖

“ខ្ញុំត្រូវបានយោធាត្រូវបានយោធានាំមកសួរចម្លើយនៅក្រោមកុដនេះ។ មានយោធាចំនួនពីរនាក់ជាអ្នកសួរចម្លើយខ្ញុំ។ ពួកគេសួរអំពីឈ្មោះ អាយុ គ្រួសារ និងបទល្មើសដែលពួកគេចោទខ្ញុំ។ គេឱ្យខ្ញុំអង្គុយកៅអី ដាក់ដៃលើតុរួចតម្រូវឱ្យឆ្លើយឱ្យបានលឿនរាល់សំណួរដោយអ្នកសួរ គឺជាអ្នកកត់ត្រាចម្លើយ និងម្នាក់ទៀតឈរយាមក្បែខ្ញុំអង្គុយ ”។

៣. អគារឃុំឃាំងអ្នកទោសជាស្ត្រីនៅព្រះវិហារចាស់

ព្រះវិហាចាស់មានបណ្តោយ ២១ម៉ែត្រ ទទឹង ១៥ម៉ែត្រ កម្ពស់ ១៣.៥ម៉ែត្រ កសាងពីថ្មដំបូលឈើប្រក់ក្បឿង ត្រូវបានយោធាខ្មែរក្រហមសម្រេចយកធ្វើជាគុកសម្រាប់ដាក់អ្នកទោស ដែលត្រូវបានចាប់បញ្ជូនមក។ អគារព្រះវិហារនេះ ប្រើសម្រាប់ដាក់អ្នកទោសភាគច្រើនជាមនុស្សស្រី មានទាំងចាស់ និងមនុស្សវ័យជំទង់ ហើយអាចដាក់អ្នកទោសបានចំនួនប្រហែល ៥០នាក់។ អ្នកទោសត្រូវបានបញ្ជូនចូលក្នុងអគារឃុំឃាំងនេះ តាមច្រកទ្វារទិសខាងលិចតែប៉ុណ្ណោះក្នុងចំណោមទ្វារទាំងអស់ចំនួនបួន ដែលបែរមុខទៅទិសខាងកើតចំនួន ពីរទ្វារ និងបែរទៅទិសខាងលិចចំនួនពីរទ្វារ។ បង្អួចទាំងអស់មានចំនួន ១០បង្អួច បែរទៅទិសខាងត្បូង ៥បង្អួច និងខាងជើង ៥បង្អួច ត្រូវបានបិទជិតរួចដាក់ឈើខ្វែងដំដែកគោលបន្ថែមយ៉ាងរឹងមាំនៅពីខាងក្រៅ ដើម្បីការពារអ្នកទោសលួចរត់ចេញ។ អ្នកទោសដែលជាប់ឃុំនៅក្នុងព្រះវិហារមានពីរប្រភេទ គឺអ្នកទោសកម្រិតស្រាល និងអ្នកទោសកម្រិតធ្ងន់។ អ្នកទោសកម្រិតស្រាល មិនត្រូវបានយោធាដាក់ខ្នោះជើងទេ ទោះបីជាត្រូវជាប់នៅក្នុងព្រះវិហារនេះជាមួយអ្នកទោសកម្រិតធ្ងន់ក៏ដោយ។ អ្នកទោសកម្រិតស្រាលត្រូវដេកជាជួរជាមួយក្រុមអ្នកទោសកម្រិតស្រាលដូចគ្នា ដោយដេកផ្ទាល់នឹងឥដ្ឋជាជួរៗជើងទល់គ្នា ឬក្បាលទល់គ្នា ដោយមិនមាន មុង ភួយ ខ្នើយ អ្វីទាំងអស់។ អ្នកទោសកម្រិតស្រាលត្រូវបានអនុញ្ញាតឱ្យចេញទៅធ្វើការងារបង្កបង្កើនផលនៅពេលថ្ងៃ នៅក្នុងបរិវេណវត្តចាប់ពីម៉ោង ៧ព្រឹក ដល់ម៉ោង ១១ថ្ងៃត្រង់ និងបន្តធ្វើការងារចាប់ពីម៉ោង ១រសៀល ដល់ម៉ោង ៥ល្ងាច។ អ្នកទោសកម្រិតធ្ងន់ ជាប្រភេទអ្នកទោសដែលមិនអនុញ្ញាតឱ្យចេញទៅធ្វើការងារអ្វីទាំងអស់

គំនូរនេះបង្ហាញអំពីទិដ្ឋភាពខាងក្រៅនៃអគារព្រះវិហារចាស់ (អគារឃុំឃាំងអ្នកទោសជាស្ត្រី) ឃើញមានមនុស្សមានគ្នាប្រាំបីនាក់ ដែលបួននាក់ជាយោធា និងបួននាក់ទៀតជាអ្នកទោសស្ត្រី កំពុងបញ្ជូនចូលទៅក្នុងអគារឃុំឃាំង។

គំនូរនេះបង្ហាញអំពីទិដ្ឋភាពនៅខាងក្នុងអគារព្រះវិហារចាស់ ឃើញអ្នកទោសជាស្ត្រីកំពុងសម្រាក។

ត្រូវស្ថិតនៅក្នុងអគារឃុំឃាំងទាំងយប់ទាំងថ្ងៃដោយជើងជាប់ខ្នោះ សូម្បីទឹកក៏មិនឱ្យងូត ហើយកន្លែងគេង ហូបចុក និងបន្ទោរបង់ គឺនៅកន្លែងតែមួយស្ថិតក្នុងអគារឃុំឃាំងផ្ទាល់។ អ្នកទោសកម្រិតធ្ងន់ទាំងអស់តម្រូវឱ្យអង្គុយជាជួរហើយជើងរបស់ពួកគាត់ត្រូវបានយោធាដាក់ខ្នោះបន្តគ្នា ដោយដែកកង (ខ្នោះកែច្នៃធ្វើអំពីដែកថ្នាំងអំពៅ) មានរនុកដែកវែងមួយប្រវែង ៥ម៉ែត្រ ទៅ ៨ម៉ែត្រ សិកបញ្ចូលតាមរន្ធខ្នោះនៅជាប់ជើងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត មានចំនួនច្រើននាក់ និងនៅចុងរនុកដែក គឺត្រូវចាក់សោរជាប់ ធ្វើឱ្យអ្នកទោសទាំងអស់មិនអាចដោះចេញបាន។ នៅពេលត្រូវយកអ្នកទោសណាម្នាក់ចេញ យោធាត្រូវដោះសោរ បន្ទាប់មកដករនុកដែកចេញ ហើយយកអ្នកទោសណាដែលត្រូវយកចេញ គឺយកចេញ ហើយបន្ទាប់មកទើបសិករនុកដែកនោះចូលវិញ រួចចាក់សោរដូចដើម ជាហេតុងាយបង្ករឱ្យអ្នកទោសមានរបួសករជើងហើម ឬដំបៅ។ អ្នកទោសទាំងនោះ ត្រូវដេកផ្ទាល់នឹងឥដ្ឋរៀបជាជួរៗមិនមានមុង ភួយ ខ្នើយ អ្វីទាំងអស់ ហើយមានសម្លៀកបំពាក់តែមួយឈុតប៉ុណ្ណោះ គឺសម្លៀកបំពាក់បានពាក់ជាប់ខ្លួន អំឡុងពេលនៃការចាប់ពួកគាត់បញ្ជូនមកមន្ទីរសន្តិសុខ។ យោធាបានចាត់តាំងអ្នកទោសស្រាលចំនួនពីរនាក់ធ្វើជាអ្នកយកការណ៍ពីខាងក្នុងអគារឃុំឃាំង ហើយរាយការណ៍ប្រាប់ពួកគេប្រសិនបើអ្នកទោសណាម្នាក់ជជែកគ្នា ឬធ្វើអីខុសពីបម្រាមក្នុងមន្ទីរសន្តិសុខ។[៥០]

នៅក្នុងអគារព្រះវិហារនេះ យោធាបានដាក់បញ្ឈរពាងចំនួនបីនៅខាងជើងជាប់នឹងបល្ល័ង្កព្រះពុទ្ធរូបធំជាងគេក្នុងព្រះវិហារ សម្រាប់អ្នកទោសបន្ទោរបង់ ហើយពាងនីមួយៗមានគម្របឈើសម្រាប់គ្របបន្ទាប់ពីបន្ទោរបង់រួច។ អ្នកទោសកម្រិតស្រាលអាចដើរមកបន្ទោរបង់ដាក់ចូលក្នុងពាងផ្ទាល់។ រីឯអ្នកទោសធ្ងន់ត្រូវបន្ទោរបង់ដាក់ក្នុង

បាតលោក រួចមានអ្នកទោសស្រាលជាអ្នកជញ្ជូនមកចាក់ចូលទៅក្នុងពាង។ កន្លែងបន្ទោរបង់នេះ គឺមិនមានជញ្ជាំងបាំងបិទអ្វីនោះទេ។[៥១]

សម្រង់សម្តីសាក្សី

វ៉ាន់ ថាន (ប្រុស) ជាអតីតអ្នកទោសក្នុងមន្ទីរសន្តិសុខវត្តសំរោងក្នុង បាននិយាយថា៖

“ខ្ញុំត្រូវបាន យោធាខ្មែរក្រហមចាប់ពីសហករណ៍អូរមុន្នី ខាងអនង្គវិល ក្នុងឆ្នាំ១៩៧៧ ដោយសារខ្ញុំបានជួយអ្នកដែលធ្វើឱ្យឆេះឌីណាម៉ូ។ ខ្ញុំជាប់នៅទីនេះរយៈពេល ១៨ថ្ងៃ។ ពេលនោះ ខ្មែរក្រហមបានដាក់ខ្នោះជើងខ្ញុំ ឃុំក្នុងព្រះវិហារ ពួកវាបានសួរចម្លើយខ្ញុំ វាយខ្ញុំដោយដំបងថ្នោងបូស្សី និងជាន់កខ្ញុំ។ សំណាងល្អ ក្រោយមកខ្ញុំត្រូវបានមេគុកជ្រើសរើស ឱ្យមកធ្វើជាអ្នកដាំបាយ នៅក្បែរកុដិទើបខ្ញុំមានជីវិតដល់សព្វថ្ងៃ”។

៤. អគារឃុំឃាំងអ្នកទោសជាបុរសនៅសាលាធម្មសភា

អគារនេះស្ថិតនៅខាងជើងព្រះវិហារចាស់ចម្ងាយប្រមាណ ២៥ម៉ែត្រពីគ្នា មានទទឹង ១៣ម៉ែត្រ និងបណ្តោយ ២៣ម៉ែត្រ។ យោធាមន្ទីរសន្តិសុខវត្តសំរោងក្នុងបានសម្រេចយកអគារនេះ ធ្វើជាគុកសម្រាប់ដាក់អ្នកទោសជាមនុស្សប្រុស។ ទ្វារទាំងអស់ត្រូវបានចាក់សោរ។ រីឯបង្អួចវិញត្រូវបិទ និងដាក់ឈើខ្វែងដំដែកគោលជាប់ពីខាងក្រៅគ្រប់បង្អួច។ អ្នកទោសនៅទីនេះ មានពីរប្រភេទ គឺអ្នកទោសកម្រិតធ្ងន់ និងអ្នកទោសកម្រិតស្រាល។ ស្ថានភាពរស់នៅក្នុងអគារឃុំឃាំងនេះ មិនខុសពីស្ថានភាពនៅក្នុងព្រះវិហារចាស់ប៉ុន្មានទេ ទាំងការស្លៀកពាក់ ហូប ដេក ធ្វើការ ការឈ្លបយកការណ៍ និងការអនុវត្តបម្រាមនានា។ អ្នកទោសកម្រិតធ្ងន់ទាំងអស់ត្រូវបានយោធាដាក់ខ្នោះជាប់ជើងម្ខាងបន្តគ្នាជាច្រើននាក់ ហើយឱ្យអង្គុយ ឬដេកជាជួរ ដែលខ្នោះនីមួយៗមានប្រវែង ៥ម៉ែត្រ ទៅ ៨ម៉ែត្រ។ យោធាបានដាក់រៀបអ្នកទោសមានបីជួរវែង ក្បែរជញ្ជាំងខាងកើតមួយជួរ ខាងជើងមួយជួរ និងក្បែរជញ្ជាំងខាងត្បូងមួយជួរ ដោយក្នុងមួយជួរៗប្រើខ្នោះចំនួនពីរ ទៅបីខ្នោះ។ អ្នកទោសកម្រិតធ្ងន់មិនបានអនុញ្ញាតឱ្យចេញទៅខាងក្រៅបានទេ។ មានអ្នកទោសខ្លះពិបាកក្នុងការទ្រាំទ្រស់នៅក្នុងស្ថានភាពវេទនាបែបនេះ បានស្រែកជេរប្រមាថ និងនិយាយមិនល្អផ្សេងៗចំពោះយោធា និងអង្គការ ដើម្បីឱ្យយោធាខឹងរួចធាប់យកពួកគាត់ទៅសម្លាប់ឱ្យបានឆាប់។ ចំណែកអ្នកទោសកម្រិតស្រាលខ្មែរក្រហមមិនបានដាក់ខ្នោះជើងទេ ទោះបីជាប់ឃុំក្នុងអគារតែមួយជាមួយអ្នកទោសកម្រិតធ្ងន់ក៏ដោយ។ អ្នកទោសទាំងនោះ ដេកជាជួរៗនៅចំកណ្តាលនៃបរិវេណខាងមុខព្រះពុទ្ធរូប (ដេកមានរបៀបរៀបរយ)។ ពួកគាត់ត្រូវចេញទៅធ្វើការងារបង្កបង្កើន ផលក្នុងបរិវេណវត្តចាប់ពីម៉ោង ៧ព្រឹកដល់ម៉ោង ១១ថ្ងៃត្រង់ និងបន្តធ្វើការងារចាប់ពីម៉ោង

១រសៀលដល់ម៉ោង ៥ល្ងាច។ នៅក្នុងអគារនេះ យោធាបានដាក់បញ្ជរ ពាងចំនួនពីរនៅខាងមុខឆៀងខាងត្បូងនៃព្រះពុទ្ធរូប ដែលមានគម្រប ឈើសម្រាប់ឱ្យអ្នកទោសកំពុងជាប់ឃុំក្នុងនោះ បន្ទោរបង់ និងមិន មានជញ្ជាំងបិតបាំងអ្វីទាំងអស់។ អ្នកទោសស្រាលអាចមកបន្ទោរបង់ ដាក់ចូលក្នុងពាងផ្ទាល់តែម្តង។ រីឯអ្នកទោសកម្រិតធ្ងន់ត្រូវបន្ទោរបង់ ដាក់ក្នុងបាតលោក (បាតដែលព្រះសង្ឃស្ពាយសម្រាប់បិណ្ឌបាត) ដែល ក្នុងមួយខ្នោះរនុកដែកមានតែបាតមួយប៉ុណ្ណោះ។ ពេលបន្ទោរបង់រួច មានអ្នកទោសកម្រិតស្រាលម្នាក់ ដែលយោធាបានចាត់តាំងជាអ្នកយក បាតដាក់លាមកនោះ ទៅចាក់ចូលក្នុងពាងលាមក ហើយបាតដែល បានចាក់លាមកចេញនោះ ត្រូវយកមកទុកក្នុងកន្លែងដើមវិញ ដោយ មិនបានលាងសម្អាតអ្វីទាំងអស់។[៥២]

អគារធម្មសភានេះជាសំណង់វ័យចំណាស់មួយសង់ឡើងជា មួយខឿនខ្ពស់ពីដីប្រមាណ ១ម៉ែត្រ ជញ្ជាំងថ្ម ដំបូលធ្វើពីឈើប្រក់ ក្បឿង មានទ្វារ និងបង្អួចធ្វើពីឈើ។ អគារនេះ មានបណ្តោយ២០ ម៉ែត្រ និងទទឹង ១៣ម៉ែត្រ ក្រាលដោយឥដ្ឋការ៉ូ ពណ៌ស និងក្រហមជាំ។

សម្រង់សម្តីសាក្សី

ជន រឿន អតីតអ្នកទោសម្នាក់ នៅមន្ទីរសន្តិសុខវត្តសំរោងក្នុង បាននិយាយថា៖

“ខ្ញុំត្រូវបានយោធាចាប់បញ្ជូនមកវត្តសំរោងក្នុង។ យោធាបាននាំខ្ញុំ មកអគារសាលាធម្មសភានេះ។ ពេលយោធាបើកទ្វាខ្ញុំឃើញ អ្នកទោសជាច្រើននៅក្នុងអាគារមួយនេះ។ យោធាបានចាប់ខ្ញុំ ដាក់ខ្នោះតែម្តង និងដាក់ឃុំនៅទីនេះ”។



គំនូរនេះបង្ហាញអំពីទិដ្ឋភាពខាងក្រៅនៃអគារសាលាធម្មសភា (អគារឃុំឃាំងអ្នកទោសជាបុរស) មើលពីខាងក្រៅ។



គំនូរនេះបង្ហាញអំពីទិដ្ឋភាពនៅខាងក្នុងអគារសាលាធម្មសភា ឃើញពីអ្នកទោសជាបុរសកំពុងសម្រាក។

៥. អគារឃុំឃាំងបណ្តោះអាសន្ននៅសាលាបាយ

សាលាបាយស្ថិតនៅខាងជើងទន្ទឹម អគារធម្មសភា និងមានទំហំតូចជាងអគារធម្មសភាបន្តិច (បច្ចុប្បន្នកែលម្អ និងពង្រីកទំហំបន្តែម)។ អគារមួយនេះ ត្រូវបានធ្វើជាកន្លែងឃុំឃាំងអ្នកទោស នៅអំឡុងពេលពួកភូមិភាគពាយ័ព្យគ្រប់គ្រង។ អ្នកទោស ដែលយោធាបញ្ជូនមកជាក់ក្នុងអគារនេះ ជាអ្នកទើបនាំមកថ្មី និងអ្នកមានកំហុសតិចតួច។ នៅក្នុងអគារឃុំឃាំងមួយនេះ មានអ្នកទោសចម្រុះ មានទាំងប្រុស ស្រី មនុស្សចាស់ វ័យជំទង់ និងមានកុមារតូចៗ ដែលមកតាមឪពុកម្តាយរបស់ពួកគេកំពុងជាប់ឃុំនៅទីនេះផងដែរ នៅអំឡុងពេលចាប់ខ្លួន។ ការរស់នៅមិនមានការរៀបចំត្រឹមត្រូវ ដូចអគារឃុំឃាំងផ្សេងនោះទេ។ វាហាក់បីដូចជាកន្លែងឃុំឃាំងបណ្តោះអាសន្នតែប៉ុណ្ណោះ។ មានអ្នកទោសមួយចំនួន ជាប់ឃុំនៅក្នុងអគារនេះ ត្រឹមមួយយប់ក៏ត្រូវបានយោធាដោះលែងវិញ។[៥៣]

នៅពេលយោធាភូមិភាគនិរតីគ្រប់គ្រង អគារមួយនេះមិនត្រូវបានប្រើប្រាស់សម្រាប់ធ្វើជាកន្លែងឃុំឃាំងអ្នកទោសនោះទេ។ អគារនេះត្រូវបានបែងចែកជាពីរបន្ទប់ធំៗ ដោយប្រើជញ្ជាំងស្លឹកដូងគៀបជាមួយបន្ទះដើមបូស្សី។ បន្ទប់ធំខាងកើតត្រូវបានប្រើសម្រាប់ជាក់សម្ភារៈ និងផ្ទៃកខ្លះទុកទំនេរ។ ចំណែកបន្ទប់ធំខាងលិចត្រូវបានខណ្ឌចែកជាបីផ្នែក ដោយមិនមានជញ្ជាំងអ្វីឱ្យបានត្រឹមត្រូវទេ គឺសម្រាប់ជាកន្លែងធ្វើទារុណកម្មសួរចម្លើយមួយផ្នែក ជាកន្លែងស្នាក់នៅរបស់អ្នកមើលថែសត្វគោមួយផ្នែក និងមួយផ្នែកទៀតជាកន្លែងស្នាក់នៅរបស់ស្ត្រីបីនាក់ ដែលគ្រប់គ្នាជឿថាមានស្ត្រីម្នាក់ក្នុងចំណោមនោះជាអ្នកមានបុណ្យបារមី។

- ទីតាំងធ្វើទារុណកម្មដើម្បីសួរចម្លើយ

នៅពេលយោធាមកពីនិរតីគ្រប់គ្រង ទីតាំងធ្វើទារុណកម្ម



គំនូរនេះបង្ហាញអំពីទិដ្ឋភាពខាងក្រៅនៃសាលាបាយក្នុងសម័យនិរតីគ្រប់គ្រង គឺមិនមានដាក់អ្នកទោស ដូចសម័យពាយ័ព្យគ្រប់គ្រងទៀតនោះទេ។



គំនូរនេះបង្ហាញអំពីទិដ្ឋភាពនៃការធ្វើទារុណកម្មអ្នកទោស ដោយឆក់ខ្សែភ្លើង នៅក្នុងបន្ទប់ចុងខាងលិចក្នុងអគារសាលាបាយ។

ត្រូវបានបួរពីកុដិថ្មមកនៅអគារនេះវិញ ដោយយកបន្ទប់ខាងលិច (ជ្រុងខាងកើតឆៀងខាងត្បូង) ធ្វើជាកន្លែងធ្វើទារុណកម្មសួរចម្លើយអ្នកទោស។ នៅក្នុងបន្ទប់នេះមានម៉ូតូម៉ាក សេ អិល ពណ៌ខៀវមួយគ្រឿងទុកធ្វើជាឧបករណ៍ផលិតចរន្តអគ្គិសនីសម្រាប់ឆក់អ្នកទោសនៅពេលសួរចម្លើយ។ អ្នកទោសខ្លះត្រូវបានយោធាយកមកវាយដំទាត់ធាក់ធ្វើទារុណកម្មនៅខាងក្រៅបន្ទប់នេះក៏មាន។[៥៤]

- ទីតាំងស្នាក់នៅរបស់កុមារមើលថែសត្វគោ

មានកន្លែងមួយ នៅជ្រុងខាងជើង ឆៀងខាងកើតនៃបន្ទប់នេះ គឺជាកន្លែងសម្រាប់ឱ្យអ្នកមើលថែសត្វគោអាចចូលមកស្នាក់នៅតែចូលបានទូវពេលយប់ៗប៉ុណ្ណោះ។ លុះព្រឹកឡើងត្រូវចេញទៅធ្វើការងារប្រមូលលាមកអ្នកទោសនៅតាមអគារឃុំឃាំងទាំងអស់នៅក្នុងមន្ទីរសន្តិសុខវត្តសំរោងក្នុង និងទៅមើលសត្វគោជាដើម។[៥៥]

- ទីតាំងស្នាក់នៅរបស់អ្នកមានបុណ្យបារមី

នៅជ្រុងខាងលិចឆៀងខាងត្បូង បាំងដោយក្រណាត់រាំងនង និងមានគ្រែ២ នៅខាងក្នុងរួមជាមួយរបស់របរប្រើប្រាស់ផ្សេងៗមួយចំនួនទុកសម្រាប់ឱ្យស្ត្រីបីនាក់ ដែលម្នាក់ក្នុងចំណោមអ្នកទាំងបីនាក់នោះ ត្រូវបានអ្នកនៅក្នុងមន្ទីរសន្តិសុខជឿថាជាអ្នកមានបុណ្យបារមី ដែលចាប់បញ្ជូនមកពីមង្គលបុរី ខេត្តបន្ទាយមានជ័យបច្ចុប្បន្ន។ ស្ត្រីពីរនាក់ទៀត មានម្នាក់ជាស្នំ (អ្នកបម្រើ) និងម្នាក់ទៀតជាកូនរបស់ស្នំ ពួកគេទាំងពីរនាក់នេះមានតួនាទីជាអ្នកមើលការខុសត្រូវទៅលើអ្នកមានបុណ្យបារមី។ តែក្រោយមកអ្នកទាំងបីត្រូវបានយោធាបញ្ជូនចេញពីបន្ទប់យកទៅដាក់ឱ្យស្នាក់នៅក្នុងចេតិយជិតរបងវត្តខាងកើតវិញ ព្រោះមិនចង់ឱ្យឮសំឡេងអ្នកទោសស្រែកនៅពេលធ្វើទារុណកម្មសួរចម្លើយនៅក្បែរនោះ។[៥៦]

សម្រង់សម្តីសាក្សី

ឈុំ ជៀន (ប្រុស) មានអាយុ ១៦ឆ្នាំនៅក្នុងរបបខ្មែរក្រហម។ គាត់ត្រូវបានខ្មែរក្រហមចាប់ខ្លួន បាននិយាយថា៖

“ខ្ញុំត្រូវបានខ្មែរក្រហមចាប់ខ្លួន ដោយចោទថាខ្ញុំបានលួចកន្សែងកីនិងស្បែកជើងបូពាំ (ស្បែកជើងកង់ឡាន) ទាំងខ្ញុំមិនដឹងទាល់តែសោះ។ ពួកគេបានសួរចម្លើយខ្ញុំ និងឆក់ខ្សែភ្លើងតពីម៉ូតូ សេ អិល និងវាយខ្ញុំដោយថ្នោងខ្សែតីសម្រាប់វាយគោ។ បន្ទាប់ពួកគេបាននាំខ្ញុំទៅដាក់ក្នុងអគារឃុំឃាំង និងដាក់ខ្នោះខ្ញុំ។ ពួកគេបានមកសួរខ្ញុំម្តងហើយម្តងទៀតថាបានលួចរបស់ទាំងនោះដែរឬទេ? បើប្រាប់ពួកគេនឹងដោះលែងវិញ។ ខ្ញុំជាប់នៅទីនេះរយៈពេល ២១ថ្ងៃ ហើយត្រូវបានពួកវាដោះលែងឱ្យទៅ ដំបំបែកដីដាំស្ពៃ និងត្រសក់វិញ។ ក្រោយមកប្រើឱ្យឃ្វាលសត្វគោ និងប្រមូលលាមកនៅតាមអគារឃុំឃាំង យកទៅចាក់ចោលស្រះខាងជើងវត្ត។ ពួកយោធាឱ្យខ្ញុំស្នាក់នៅក្នុងបន្ទប់សាលាបាយក្បែរកន្លែងធ្វើទារុណកម្មដែលជាប់នឹងកន្លែងអ្នកមានបុណ្យស្នាក់នៅ។ ពេលនោះ នៅអំឡុងពេលពួកយោធាមកពីនិរតីគ្រប់គ្រង គឺមិនមានអ្នកទោសនៅក្នុងបន្ទប់នេះទៀតទេ។

៦. ចង្ក្រានដាំបាយ

នៅខាងលិចកុដិឈើធំ ក្បែរស្រះទឹក គឺជាកន្លែងដែលចម្អិនអាហារសម្រាប់អ្នកទោស និងយោធានៅក្នុងមន្ទីរសន្តិសុខនេះ។ ចង្ក្រានបាយនេះ ស្ថិតក្នុងទីវាលមិនមានផ្ទះបាយ ឬមានប្រក់ដំបូលអ្វីឡើយ។ ចង្ក្រាន គឺធ្វើដោយដីកលុងដីសម្រាប់ដុតអុស។ នៅទីនេះមានខ្នះខ្នោតធំៗចំនួនបី ដែលខ្នះខ្នោតពីរសម្រាប់ដាំបបរ និងខ្នះមួយទៀតសម្រាប់ស្លសម្ល។ ចុងភៅ គឺជាអ្នកទោសកំពុងជាប់ឃុំនៅទីនេះ ដែលចេះដាំបាយធ្វើម្ហូប ត្រូវបានយោធាជ្រើសរើសមកធ្វើជាអ្នកដាំស្លផ្គត់ផ្គង់របបអាហារប្រចាំថ្ងៃនៅទីនេះ។ អ្នកដាំស្លមានគ្នាចំនួនបីនាក់ រួមមាន បុរសម្នាក់ជាអ្នកដាំបបរ និងស្ត្រីចំនួនពីរនាក់ជាអ្នកស្លសម្ល។ ការដាំស្លត្រូវធ្វើចំនួនពីរដងក្នុងមួយថ្ងៃ គឺសម្រាប់របបអាហារពេលថ្ងៃត្រង់ម្តង និងពេលល្ងាចមួយដង។ នៅរដូវរស្សាមានភ្លៀងធ្លាក់ ចង្ក្រានបាយត្រូវបានផ្លាស់ប្តូរទីតាំងដើម មកធ្វើនៅក្រោមកុដិឈើចាស់។ លុះដល់រដូវប្រាំងលែងមានភ្លៀងធ្លាក់ ត្រូវប្តូរមកនៅកន្លែងដើមវិញ។ អុសសម្រាប់ដុត ត្រូវបានផ្គត់ផ្គង់ដោយដឹកជញ្ជូនមកពីខាងក្រៅ ដោយរទេះគោក្នុងរយៈពេលកន្លះខែម្តង។[៥៧]

សម្រង់សម្តីសាក្សី

វ៉ាន់ ថាន (ប្រុស) ជាអតីតអ្នកទោសក្នុងមន្ទីរសន្តិសុខវត្តសំរោងក្នុង បាននិយាយថា៖

“ខ្ញុំត្រូវបានយោធានៅក្នុងមន្ទីរសន្តិសុខជ្រើសរើសឱ្យមកដាំបាយ ពីព្រោះខ្ញុំអាចដាំបាយបាន។ មួយរយៈក្រោយមក ខ្ញុំត្រូវបានដោះលែងពីមន្ទីរឃុំឃាំងនេះ ដោយសារមេគុកអនុញ្ញាតបន្ទាប់ពីខ្ញុំប្រគល់នាឡិកាដៃមួយគ្រឿងឱ្យទៅគេ”។

គំនូរនេះបង្ហាញអំពីទិដ្ឋភាពនៅកន្លែងដាំបាយនៅក្នុងមន្ទីរសន្តិសុខ វត្តសំរោងក្នុង និងមានអ្នកទោសបីនាក់ ស្រីពីរនាក់ ប្រុសម្នាក់ត្រូវបានជ្រើសរើសឱ្យធ្វើជាចុងភៅ។

គំនូរនេះបង្ហាញអំពីសកម្មភាពចែកបាយ ឱ្យអ្នកទោស នៅម៉ោងសម្រាកពីការងារនៅពេលថ្ងៃត្រង់។

៧. ស្រះទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ

ស្រះទឹកនេះ ស្ថិតនៅជាប់នឹងកន្លែងជាំបាយ ក្បែរកន្លែងស្នាក់នៅរបស់យោធា។ ស្រះទឹកនេះមានទឹកថ្លាល្អ អំណោយផលសម្រាប់ការផ្គត់ផ្គង់លើការដាំស្ល យកធ្វើទឹកផឹក និងសម្រាប់កងយោធាប្រើប្រាស់ប្រចាំថ្ងៃ។ ស្រះទឹកនេះ អាចស្តុកទឹកបានសម្រាប់ប្រើប្រាស់ពេញមួយឆ្នាំ។[៥៨] ស្រះទឹកនេះមានបណ្តោយ ៣៨ម៉ែត្រ និងទទឹង ២៥ម៉ែត្រ និងជម្រៅ ៥ម៉ែត្រ។

សម្រង់សម្តីសាក្សី

កាក់ សុខន ប្រុស ជាអតីតព្រះសង្ឃនៅវត្តសំរោងក្នុងមុនរបបខ្មែរក្រហមបាននិយាយថា៖
“ស្រះទឹកនេះ មានតាំងពីយូរណាស់មកហើយ តាំងពីមុនខ្មែរក្រហម។ វាជាប្រភពផ្តល់ទឹកប្រើប្រាស់សម្រាប់ព្រះសង្ឃគង់ស្នាក់នៅក្នុងវត្ត និងប្រើសម្រាប់ស្រោចដំណាំផ្សេងៗ ដែលមានក្នុងបរិវេណវត្ត។ សព្វថ្ងៃនេះ ស្រះទឹកនេះនៅដដែល ហើយនៅតែជាកន្លែងស្តុកទឹកដ៏សំខាន់សម្រាប់ផ្គត់ផ្គង់ដល់ការប្រើប្រាស់ក្នុងវត្តសព្វគ្រប់”។

គំនូរនេះបង្ហាញអំពីទិដ្ឋភាពស្រះទឹកសម្រាប់ដងទឹកប្រើប្រាស់ប្រចាំថ្ងៃ នៅក្នុងមន្ទីរសន្តិសុខ។



គំនូរនេះបង្ហាញអំពីទិដ្ឋភាពអគារសួរចម្លើយអ្នកទោសកម្រិតធ្ងន់ ដោយមើលពីខាងក្រៅ នៅពេលយោធាពាយ័ព្យគ្រប់គ្រង (១៩៧៦-១៩៧៧)។

គំនូរនេះបង្ហាញអំពីទិដ្ឋភាពនៃការធ្វើទារុណកម្ម អ្នកទោសធ្ងន់ នៅខាងក្នុងអគារ។

៨. អគារសួរចម្លើយ និងធ្វើទារុណកម្មនៅកុដិថ្មចាស់

កុដិចាស់នេះ ស្ថិតនៅដាច់ឆ្ងាយពីអគារផ្សេងៗត្រូវបានយោធាមន្ទីរសន្តិសុខវត្តសំរោងក្នុងនៅជំនាន់ភូមិភាគពាយ័ព្យ យកមកប្រើប្រាស់ជាកន្លែងធ្វើទារុណកម្មសួរចម្លើយអ្នកទោស ដើម្បីស្រង់ព័ត៌មាន និងស្វែងរកខ្សែស្រឡាយក្បត់។ អគារនេះមានបណ្តោយ ១០ម៉ែត្រ និងទទឹង ៤.៥ម៉ែត្រ។ ជាទូទៅការសួរចម្លើយអ្នកទោសធ្វើឡើងរយៈពេលពីរថ្ងៃម្តង។ អ្នកទោសដែលឆ្លងកាត់ការសួរចម្លើយនៅទីនេះ មានចំនួនច្រើនត្រូវទទួលរងនូវទារុណកម្មធ្ងន់ធ្ងរដូចជា វាយនឹងរំពាត់ ខ្សែតី ទាត់ធាក់ ច្រកក្បាលចូលក្នុងថង់ប្លាស្ទិកឱ្យថប់ដង្ហើម និងជ្រមុជក្បាលចូលក្នុងពាងទឹកជាដើម។ នៅពេលសួរចម្លើយរួចរាល់ អ្នកទោសត្រូវនាំទៅកន្លែងឃុំឃាំងដើមវិញ រងចាំការសរុបចម្លើយ និងការសម្រេចចិត្តពីថ្នាក់លើ។ អ្នកទោសដែលផ្តល់ចម្លើយសារភាពគ្រប់គ្រាន់ ចុងក្រោយត្រូវបាននាំយកទៅសម្លាប់ចោល។[៥៩]

នៅក្រោមការគ្រប់គ្រងរបស់ភូមិភាគនិរតីកុដិថ្មនេះ មិនត្រូវបានប្រើប្រាស់ជាកន្លែងសួរចម្លើយទៀតនោះទេ។ បរិវេណជុំវិញកុដិប្រើសម្រាប់ជាទីតាំងដាំបន្លែ ចិញ្ចឹមសត្វដូចជាសត្វជ្រូក និងមាន់ជាដើម។ កុដិនេះ សាងសង់ពីថ្ម ប្រក់ក្បឿង មានទទឹង ៤.៥០ម៉ែត្រ បណ្តោយ ៩.៥០ម៉ែត្របង្ហួចចំនួនជ្រាំបី និងទ្វារចំនួនពីរ ជាអតីតកុដិលោកតា ស៊ឹង ស្ថិតនៅក្បែររបងវត្តផ្នែកខាងក្រោយ ឆៀងខាងជើងក្បែរកន្លែងសម្លាប់អ្នកទោស។

សម្រង់សម្តីសាក្សី

ជន រឿន អតីតអ្នកទោសម្នាក់ នៅមន្ទីរសន្តិសុខវត្តសំរោងក្នុង បាននិយាយថា៖ “ពេលយោធានាំខ្ញុំចូលមកដល់ក្នុងវត្តភ្លាមពួកគេបញ្ជាឱ្យខ្ញុំវត់ទៅមកៗ នៅក្នុងវត្តរហូតខ្ញុំអស់កម្លាំងខ្លាំងវត់ទៅមុនលែងរួច ។ មូលហេតុដែលពួកគេឱ្យខ្ញុំវត់ ពីព្រោះដោយសារខ្ញុំព្យាយាមរត់គេចនៅពេលពួកគេចាប់ខ្លួនខ្ញុំ”។

៩. កន្លែងងូតទឹករបស់អ្នកទោស និងកន្លែងចាក់លាមក

ស្រះទឹកមានទំហំតូចល្មម ស្ថិតនៅខាងជើងសាលាបាយនៅខាងក្រៅរបងវត្ត (បច្ចុប្បន្ននៅខាងមុខបូជនីយដ្ឋាន ដែលតម្កល់ធាតុអ្នកស្លាប់កាលពីសម័យខ្មែរក្រហម) ជាកន្លែងងូតទឹករបស់អ្នកទោសជាស្ត្រីកំពុងជាប់ឃុំនៅក្នុងព្រះវិហារចាស់។ កងយោធាមន្ទីរសន្តិសុខបានអនុញ្ញាតឱ្យអ្នកទោសស្រាលមកងូតទឹកក្នុងមួយសប្តាហ៍ម្តង។ ជាធម្មតាមានកងយោធាចំនួនបីនាក់ ម្នាក់កាន់កាំភ្លើង ម្នាក់កាន់ដំបង និងម្នាក់ទៀតមានក្រមារបង់ក បាននាំអ្នកទោសមកងូតទឹកនៅក្នុងស្រះនេះ ដោយឱ្យអ្នកទោសចុះទៅងូតទឹកក្នុងស្រះឱ្យលឿន។ បើសិនមានអ្នកណាចុះងូតទឹកក្នុងស្រះយឺតយ៉ាវនោះ យោធានឹងយកដំបងវាយ។ ស្ថានភាពទឹកមានពណ៌ខ្មៅថ្លា និងឡើងប្រែមកល្អក់នៅពេលអ្នកចុះងូតច្រើនគ្នា។[៦០]

នៅម្ខាងនៃមាត់ស្រះទឹកនេះ ក៏ជាកន្លែងចាក់លាមកដែលប្រមូលយកចេញពីអគារឃុំឃាំងអ្នកទោសទាំងអស់នៅក្នុងមន្ទីរ

សម្រង់សម្តីសាក្សី

ឈុំ ជៀន (ប្រុស) អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង ពាននិយាយថា៖

“ក្រោយពេលពួកយោធាដោះលែងខ្ញុំចេញពីអគារឃុំឃាំងពួកគេបានឱ្យខ្ញុំធ្វើការងារជាច្រើនក្នុងនោះខ្ញុំត្រូវប្រមូលលាមកអ្នកទោសនៅតាមអគារឃុំឃាំងរៀងរាល់ព្រឹករួចហើយរែកមកចាក់ចោលនៅមាត់ស្រះនេះ”។

គំនូរនេះបង្ហាញអំពីទិដ្ឋភាពអ្នកទោសជាស្ត្រីកំពុងងូតទឹក
នៅក្នុងស្រះទឹកនៅខាងជើងរបងវត្ត ដោយមានការយាមពីយោធា។



គំនូរនេះបង្ហាញអំពីទិដ្ឋភាពអ្នកវែកឈាមកប្រមូលពីអគារឃុំឃាំងមក
ចាក់ចោលនៅម្ខាងនៃមាត់ស្រះ ដែលអ្នកទោសងូតទឹកជារៀងរាល់ថ្ងៃ។

សន្តិសុខ។ យោធាបានចាត់តាំងអ្នកទោសម្នាក់ ដើរប្រមូលលាមក យកចេញពីក្នុងពាងលាមកទាំងអស់ ចាក់ចូលក្នុងធុង រួចហើយវែក ដើរសំដៅមកចាក់ចោលទៅទីតាំងនៃមាត់ស្រះនេះ ជារៀងរាល់ថ្ងៃ នាពេលព្រឹក។[៦១]

១០. រណ្តៅសាកសព

រណ្តៅសាកសព គឺជារណ្តៅរួមត្រូវបានជីកចូលទៅក្នុងដី មានជម្រៅ និងទំហំផ្សេងគ្នាសម្រាប់ទម្លាក់សាកសពអ្នកទោស ក្រោយពេលសម្លាប់រួច។ រណ្តៅធំៗត្រូវបានជីកនៅអំឡុងយោធា ភូមិភាគពាយ័ព្យគ្រប់គ្រង។ ចំណែករណ្តៅតូចៗជារណ្តៅថ្មីភាគច្រើន ត្រូវបានជីកបន្ថែមក្នុងអំឡុងភូមិភាគនិរតីគ្រប់គ្រង។ រណ្តៅសាកសព ទាំងនោះ ស្ថិតនៅដីទួលខាងលិចឆៀងខាងជើងនៃបរិវេណវត្ត (ដីក្នុង បរិវេណបូជនីយដ្ឋានតម្កល់អដ្ឋិធាតុសព្វថ្ងៃ) ដែលជាដីចម្ការរបស់ អ្នកភូមិ។ រណ្តៅសាកសពទាំងនោះ ត្រូវបានយោធាមន្ទីរសន្តិសុខវត្ត សំរោងក្នុងប្រើឱ្យអ្នកទោសដែលកំពុងជាប់ឃុំផ្ទាល់ជាអ្នកជីក។ ក្នុង មួយរណ្តៅមានសាកសពលើសពី ១០នាក់ ទៅ ២០នាក់ ឬមានចំនួន ច្រើនជាងនេះ។ រណ្តៅណាដែលមានសាកសពពេញអស់ហើយ គឺ ត្រូវបានកាយដីលុប។[៦២]

> *សម្រង់សម្តីសាក្សី*
>
> *ស៊ិប ស៊ីម អតីតអ្នកទោសម្នាក់ នៅមន្ទីរសន្តិសុខវត្តសំរោងក្នុង បាននិយាយថា៖*
>
> *“ខ្ញុំត្រូវបានយោធាប្រើឱ្យមកជីករណ្តៅនៅទីនេះ ខាងត្បូងរបង បូជនីយដ្ឋានសព្វថ្ងៃ។ នៅពេលខ្ញុំកំពុងកាប់ដី ស្រាប់តែមានយោធា ដើរមកហៅខ្ញុំឱ្យត្រលប់ចូលទៅក្នុងវត្តវិញ។ ពេលនោះខ្ញុំមិនដឹង ថាពួកគេប្រើខ្ញុំជីកក្នុងបំណងយកធ្វើអីទេ តែក្រោយមកទើបដឹង ថា ទីតាំងជាប់កន្លែងខ្ញុំជីកសុទ្ធតែជារណ្តៅសាកសពទាំងអស់”។*

គំនូរនេះបង្ហាញអំពីទិដ្ឋភាពនៃបណ្តុំរណ្តៅសាកសពអ្នកទោស
ដែលយោធានាំយកទៅសម្លាប់នៅខាងក្រោយរបងវត្តជ្រុងខាងជើង។

១១. អណ្តូងសម្លាប់កុមារ

កុមារទាំងនោះចូលមកមន្ទីរសន្តិសុខបានជាមួយឪពុក ឬម្តាយឬសាច់ញាតិរបស់ពួកគេ អំឡុងពេលនៃការចាប់ខ្លួន។ គេជឿថា កុមារត្រូវបានសម្លាប់ គឺជាកូនរបស់អ្នកទោសកម្រិតធ្ងន់ៗដែលត្រូវបានសម្លាប់នៅទីនេះ។ មានសាក្សីម្នាក់ដែលជាអ្នកឡើងត្រង់ទឹកត្នោតដើម្បីយកទៅធ្វើស្ករត្នោតនៅក្បែរអណ្តូងបានឃើញដោយផ្ទាល់ភ្នែកអំពីសកម្មភាពកងយោធាមន្ទីរសន្តិសុខនាំកុមារតូចៗមកសម្លាប់ដោយវាយដំបង និងចាប់បោកនឹងគល់ត្នោតនៅក្បែរនោះ រួចបោះចូលទៅក្នុងអណ្តូងមួយនេះតែម្តង។ អណ្តូងនេះ ជាប្រភេទអណ្តូងដីរាងដូចជាកូនស្រះទឹកតូចមួយ ដែលមានផ្ទៃក្រឡាប្រមាណ ២០ម៉ែត្រការ៉េ ជម្រៅ ៣ម៉ែត្រ ទៅ ៤ម៉ែត្រ ដែលស្ថិតនៅខាងត្បូងទីតាំងរណ្តៅសាកសពខាងក្រោយជ្រុងខាងជើងនៃរបងវត្ត។[៦៣]



គំនូរនេះបង្ហាញអំពីទិដ្ឋភាពសម្លាប់កុមារតូចៗ ទម្លាក់ចូលក្នុងអណ្តូងនៅ ខាងក្រោយវត្តជ្រុងខាងជើងនៃរបងវត្ត។

សម្រង់សម្តីសាក្សី

ឈ្មោង សួម អតីតអ្នកទោសម្នាក់ នៅមន្ទីរសន្តិសុខវត្តសំរោងក្នុង បាននិយាយថា៖

“ខ្ញុំជាប់ឃុំក្នុងអគារសាលាធម្មសភា ហើយជើងរបស់ខ្ញុំត្រូវជាប់ខ្នោះ។ នៅយប់ចុងក្រោយ ស្ថានភាពពិតជាធ្វើឱ្យខ្ញុំមានការភ័យខ្លាំងណាស់ ព្រោះយោធាបានចូលមកនាំអ្នកទោសច្រើននាក់ជាបន្តបន្ទាប់ចាកចេញពីក្នុងអាគារឃុំឃាំងសាលាធម្មសភាយកទៅសម្លាប់ចោល។ លុះព្រឹកឡើងទើបមានការបោះគ្រាប់បែកចូលក្នុងអគារឃុំឃាំងសាលាធម្មសភាថែមទៀត បំណងសម្លាប់អ្នកទោសឱ្យអស់។ គ្រាប់បែកមួយគ្រាប់បានរមៀលមកមិនឆ្ងាយប៉ុន្មានពីកន្លែងខ្ញុំអង្គុយរួចផ្ទុះឡើងបណ្តាលឱ្យអ្នកទោសមួយចំនួនរងរបួស និងស្លាប់។ ខ្ញុំពិតជាមានសំណាងដែលមិនត្រូវរបួស ឬបាត់បង់ជីវិតដោយសារគ្រាប់បែប ដោយសារមានអ្នកផ្សេងៗទៀតជាំង និងខ្ញុំបានទម្លាក់ខ្លួនក្រាបនឹងឥដ្ឋទាន់”។

ជំពូក៦

ថ្ងៃចុងក្រោយ នៃមន្ទីរសន្តិសុខវត្តសំរោងក្នុង

“ការបោកគ្រាប់បែកសម្លាប់អ្នកទោស
ការដោះលែងអ្នកទោស និងការចាកចេញ
របស់ខ្មែរក្រហម”

១. ហេតុការណ៍ចុងក្រោយនៅក្នុងមន្ទីរសន្តិសុខ

នៅក្នុងខែមករា ឆ្នាំ១៩៧៩ នៅពេលកំពុងប្រឈមមុខជាមួយយោធាវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា សភាពការណ៍នៅក្នុងមន្ទីរសន្តិសុខវត្តសំរោងក្នុងក៏បានប្រែប្រួល។ កងយោធាដែលនៅទីនេះ ហាក់បីដូចជាដឹងមុនអំពីស្ថានការណ៍ខាងក្រៅកំពុងគំរាមកំហែង ដែលនាំឱ្យកងយោធាមិនសូវយកចិត្តទុកដាក់ចំពោះការឃ្លាំមើលអ្នកទោសដូចសព្វដង។ មានអ្នកទោសខ្លះបានលួចរត់ចេញពីមន្ទីរសន្តិសុខទាំងប្រថុយប្រថាននៅពេលម៉ោងសម្រាកពីការងារ។ នៅយប់ថ្ងៃចុង ក្រោយមុនពេលមន្ទីរសន្តិសុខវត្តសំរោងក្នុងត្រូវបិទបញ្ចប់ កងយោធាបានចូលមកនាំអ្នកទោសពីក្នុងអគារឃុំឃាំងយកទៅសម្លាប់ចោលទាំងយប់ជាក្រុមៗ។ បើតាមសាក្សីដែលកំពុងជាប់ឃុំក្នុងសាលាធម្មសភា លោកឈ្នាង សួម បានឃើញយោធាយកអ្នកទោសចងបណ្តើរ ២ខ្សែ ដែលក្នុងមួយខ្សែមានប្រហែល ១៥នាក់ យកទៅសម្លាប់។ មួយសន្ទុះក្រោយមក យោធាបានអុជចង្កៀងដៃកាន់ដំបង និងខ្សែមួយដុំ បើកទ្វារចូលមកចាប់អ្នកទោសចងស្លាបសេកបញ្ជូនចេញមកមួយចំនួនទៀត។ មិនយូរប៉ុន្មានកងយោធាក៏ត្រលប់មកវិញម្តងទៀត រួចបានចាប់អ្នកទោសចងខ្សែប្រហែល ១៥នាក់ បន្ថែមទៀត បណ្តើរចេញទៅបាត់។ សកម្មភាពនៅយប់នោះធ្វើឱ្យអ្នកទោសទាំងអស់ភ័យខ្លាចគ្រប់គ្នា។ ក្រោយពេលចាប់អ្នកទោសបណ្តើរចេញស្ងាត់មួយសន្ទុះ

សំឡេងបាញ់ផ្លោងពីចម្ងាយលាន់លឺដល់វត្តសំរោងក្នុង នាំឱ្យអ្នកទោសនៅក្នុងអគារឃុំឃាំងរំពឹងថាកំពុងមានអ្នកមកជួយ បើទោះបីមិនដឹងថាសំឡេងនោះចេញពីទិសខាងណាក៏ដោយ។ នៅពេលព្រឹកថ្ងៃបន្ទាប់ប្រហែលចន្លោះម៉ោង៧ព្រឹកទៅ៨ព្រឹកពួកអ្នកទោសកម្រិតស្រាលបាននាំគ្នារត់ស្លន់ស្លោនៅក្នុងអគារឃុំឃាំង ដើម្បីរកផ្លូវចេញ។ ពេលនោះមានយោធាមកលបមើលតាមបង្អួចដែរ តែពួកគេមិនបានធ្វើអ្វីទេ ហើយបានត្រឡប់ទៅវិញ។ ចៃដន្យស្រាប់តែមានទ្វារមួយរបើកនាំឱ្យអ្នកទោសកម្រិតស្រាលអាចរត់ចេញពីកន្លែងឃុំឃាំងបាន។ ពេលឃើញដូចនេះ យោធាបានបាញ់កាំភ្លើងគំរាមច្រើនគ្រាប់តែមិនបណ្តាលឱ្យមនុស្សស្លាប់ទេ។ ក្រោយពីអ្នកទោសស្រាលរត់ចេញអស់ នៅសល់តែអ្នកទោសធ្ងន់ដែលជាប់ខ្នោះ។ ពួកយោធាទាញទ្វារបិទវិញ។ មួយសន្ទុះក្រោយមកលឺសំឡេងបើកទ្វារស្រាប់តែមានគ្រាប់បែកចំនួនពីរគ្រាប់ បោះចូលមកខាងក្នុងអគារ ដោយមួយគ្រាប់រមៀលមកដល់កន្លែងអ្នកទោសជាប់ខ្នោះកំពុងអង្គុយ និងមួយគ្រាប់ទៀតធ្លាក់ជាប់នៅក្បែរទ្វារផ្ទុះឡើងទាំង ២គ្រាប់បណ្តាលឱ្យមានអ្នកទោសមួយចំនួនស្លាប់ និងរបួស។ បន្ទាប់ពីបោកគ្រាប់បែកកងយោធាទាំងអស់បានរត់គេចខ្លួនចាកចេញពីមន្ទីរសន្តិសុខវត្តសំរោងក្នុងយ៉ាងប្រញាប់។ ភ្លាមៗនោះ អ្នកទោសនៅខាងក្នុងអគារដែលនៅមានជីវិត បាននាំគ្នាស្រែកហៅឱ្យអ្នកខាងក្រៅជួយ ហើយព្យាយាមដោះសោរ ដើម្បីដកដៃកខ្នោះចេញពីជើង ប៉ុន្តែមិនអាចដោះរួចនោះទេ ។ អ្នកភូមិម្នាក់ឈ្មោះ ងិន ងួន បានរត់ចូលមកក្នុងបរិវេណវត្តសំរោងក្នុង ដោយដៃកាន់ពូថៅ បន្ទាប់ពីគាត់បានលឺសូរសំឡេងគ្រាប់បែកផ្ទុះ និងលឺសំឡេងអ្នកខាងក្នុងវត្តស្រែកឱ្យជួយ។ គាត់បានយកពូថៅដែរបស់គាត់ មកកាប់គាស់ទ្វារសាលាធម្មសភា

និងដំសោរខ្ទោះជួយរំដោះអ្នកទោស បន្ទាប់មករត់ទៅគាស់ទ្វារព្រះវិហារចាស់បន្តជាមួយបុរសម្នាក់ទៀត ដើម្បីជួយរំដោះអ្នកទោស។ អ្នកទោសខ្លះនៅមានកម្លាំងអាចរត់ចេញបានដោយខ្លួនឯង និងអ្នកខ្លះគ្មានកម្លាំងក្នុងការងើបរត់នោះទេ តែត្រូវបានអ្នកផ្សេងៗទៀតជួយនាំចេញ។

២. ស្ថានភាពវត្តសំរោងក្នុងក្រោយពេលយោធាចាកចេញ

ក្រោយពេលយោធាខ្មែរក្រហមចាកចេញអស់ពីវត្តសំរោងក្នុង អ្នកទោសទាំងអស់ដែលនៅរស់រានមានជីវិតក៏បានចាកចេញគ្មានសល់។ ស្ថានភាពក្នុងបរិវេណវត្តមានសភាពស្ងាត់ជ្រងំ មិនមានអ្នកណាម្នាក់ហ៊ានចូលទៅក្នុងវត្តនោះទេ ដោយសារបារម្ភពីសន្តិសុខ និងសុវត្ថិភាព។ អស់រយៈពេលពីរទៅបីថ្ងៃក្រោយមក ទើបមានអ្នកស្រុកអ្នកភូមិមួយចំនួនបានចាប់ផ្តើមចូលមកក្នុងបរិវេណវត្ត ហើយបានមើលឃើញពីភស្តុតាងដែលនៅសេសសល់ដូចជា សាកសពមនុស្សនៅក្នុងសាលាធម្មសភាមានសភាពហើមស្អុយ មានខ្ទោះជើង សម្ភារៈធ្វើទារុណកម្មមួយចំនួននៅខាងកើតស្រះទឹក សម្ភារៈផ្ទះបាយ សម្ភារៈធ្វើពលកម្ម ស្លាកស្នាមនៃការបោកគ្រាប់បែក និងមានគំនរខោអាវពណ៌ខ្មៅនៅរាយប៉ាយនៅលើកុដិឈើ និងនៅក្បែរមាត់ស្រះជាដើម។ លើសពីនេះទៅទៀតនៅប៉ែកខាងក្រោយវត្តមានក្លិនសាកសពស្អុយសាយភាយចេញពីរណ្តៅកប់សពនៅក្បែរនោះ។

ក្រោមការដឹកនាំដោយលោក ធុន សុវត្ថិ បានផ្តួចផ្តើមប្រមូលកម្លាំងមនុស្សក្នុងសហគមន៍ មកចូលរួមរៀបចំវត្តឡើងវិញ ដោយប្រមូលសាកសពនៅសេសសល់យកទៅបូជាតាមប្រពៃណី និងរៀបចំបោសសម្អាតបរិវេណវត្ត និងអគារផ្សេងៗ ដែលយោធាប្រើប្រាស់ជាកន្លែងឃុំឃាំង កន្លែងធ្វើទារុណកម្មសួរចម្លើយ និង

កន្លែងស្នាក់នៅធ្វើការងារ ឱ្យទៅជាកន្លែងរៀបចំពិធីគោរពបូជា តាមបែបប្រពៃណីព្រះពុទ្ធសាសនា ដើម្បីបម្រើដល់វិស័យសាសនាព្រះពុទ្ធបន្តទៀត។[៦៤]

ជំពូក៧

ការជីករណ្តៅសាកសព និង ការកសាងស្តូបតម្កល់អដ្ឋិធាតុ

“សកម្មភាពជីករណ្តៅក្នុងអំឡុងឆ្នាំ១៩៨០ និង ដំណើរការកសាងស្តូបជាបន្តបន្ទាប់”



១. ការជីករណ្តៅនៅអំឡុងឆ្នាំ១៩៨០

នៅចុងឆ្នាំ១៩៧៩ និងដើមឆ្នាំ១៩៨០ ប្រជាជនមួយចំនួនបាន នាំគ្នាមកជីករណ្តៅសាកសពនៅខាងក្រោយវត្ត ដើម្បីរកសមាជិក គ្រួសារសាច់ញាតិបានស្លាប់ទីនេះ ហើយអ្នកខ្លះទៀត ដើម្បីស្វែងរក មាស និងវត្ថុមានតម្លៃផ្សេងៗ ដែលអ្នកទោសមួយចំនួនបានលួចលាក់ ដាក់ជាប់តាមខ្លួនពេលយកទៅសម្លាប់។ សកម្មភាពគាស់កាយក្នុង រណ្តៅសាកសព បានទាញយកផ្នែកខ្លះនៃសាកសពដូចជា ឆ្អឹងដៃ ឆ្អឹង លលាក្បាល និងផ្នែកផ្សេងទៀត ត្រូវបានរើបោះមកនៅជុំវិញមាត់ រណ្តៅ។ ក្រៅពីឆ្អឹងទាំងនោះ ក៏មានសំលៀកបំពាក់អ្នកទោស ត្រូវ បានប្រជាជនរើបោះមកជាមួយគ្នាផងដែរ។[១៥]

២. ការកសាងស្តូបតម្កល់អដ្ឋិធាតុ

ក្រោយពេលជីករណ្តៅពីសំណាក់ប្រជាជន ធ្វើឱ្យអដ្ឋិធាតុ ដែលបានកាយចេញពីរណ្តៅសាកសព និងក្រណាត់ខោអាវ នៅរាយ ប៉ាយពាសពេញលើដីមិនមានការរៀបចំកន្លែងទុកដាក់នៅឡើយទេ។ ដោយមើលឃើញស្ថានភាពដូចនេះ ទើបមានការចូលរួមផ្តួចផ្តើមពី សហគមន៍ កសាងកន្លែងទុកដាក់អដ្ឋិធាតុទាំងនោះ ឱ្យបានសមរម្យ សម្រាប់ធ្វើពិធីរំលឹកនៃការចងចាំ និងឧទ្ទិសបុណ្យកុសលឱ្យដល់អ្នក បានស្លាប់នៅទីនេះ។ ចំណែកសំលៀកបំពាក់អ្នកទោសទាំងនោះ យកទៅប្រគរទុកមួយរយៈបន្ទាប់មកក៏ដុតកម្ទេចចោលតែម្តង។[១៦]

- ការកសាងរោងតម្កល់អដ្ឋិធាតុនៅឆ្នាំ១៩៨០

រោងនេះសង់ពីឈើ ប្រក់ស្បូវ និងមានរនាបក្តាររៀបត្រឹមពាក់កណ្តាលរោងទៅក្រោយ។ រោងនេះ កសាងក្នុងឆ្នាំ១៩៨០ ដោយមានការចូលរួមពីប្រជាជនក្នុងមូលដ្ឋាន។ ក្រោយសាងសង់រួច ប្រជាជនបាននាំគ្នាជួយប្រមូលអដ្ឋិធាតុ ដែលនៅលើដីមកដាក់ប្រគរតម្រៀបគ្នានៅលើរនាបក្តារនៅក្នុងរោងមួយនេះ។[១៧]

គំនូរនេះបង្ហាញអំពីរូបភាពស្ពបសម្រាប់តម្កល់អដ្ឋិធាតុ លើកដំបូង ដែលកសាងអំពីឈើប្រក់ស្បូវ។

- **ការកសាងស្តូបនៅឆ្នាំ១៩៨២**

ក្នុងឆ្នាំ១៩៨២ ដោយមើលឃើញ រោងប្រក់ស្បូវចាស់មានសភាពចាស់ទ្រុឌទ្រោមខ្លាំង គណៈកម្មការ និងអាចារ្យវត្ត ដឹកនាំដោយលោកអាចារ្យ ធុន សុវត្តិ បានស្នើសុំទៅអាជ្ញាធរដែនដី ដើម្បីរៀបចំកសាងស្តូបថ្មីមួយជំនួសឱ្យរោងស្បូវ ដែលសាងសង់អំពីឈើ ប្រក់ក្បឿងជាមួយដំបូលរចនាបថខ្មែរ គ្មានជញ្ជាំង និងមានកម្ពស់ប្រមាណ ៧ម៉ែត្រ។ នៅចំកណ្តាលមានរៀបធ្វើរកម្ពស់ ១ម៉ែត្រពីដីសម្រាប់ដាក់តម្កល់អដ្ឋិធាតុនៅលើនោះ។[៦៨]

គំនូរនេះបង្ហាញអំពីរូបភាពស្តូបសម្រាប់តម្កល់អដ្ឋិធាតុ លើកទីពីរ ដែលកសាងអំពីឈើប្រក់ក្បឿងរំលេចដោយ រចនាបថដំបូលបែបខ្មែរ។

- ការកសាងស្តូបឆ្នាំ២០០១

រណ្តៅសាកសពមួយចំនួនទៀត ត្រូវបានគាស់បន្ថែមក្នុងឆ្នាំ២០០០ ដើម្បីរៀបចំទីតាំងសាងសង់ស្តូប។ ក្នុងឆ្នាំ២០០១ ស្តូបថ្មីចាប់ផ្តើមកសាង ដែលមានទំហំធំជាងមុន ជំនួសឱ្យស្តូបឈើចាស់ទ្រុឌទ្រោម។ ស្តូបនេះកសាងឡើងក្រោមគំនិតផ្តួចផ្តើមពីគណៈកម្មការវត្ត និងអាជ្ញាធរដែនដីក្រោមការរៃអង្គាសជំនួយថវិកាពីសប្បុរសជនរស់នៅក្រៅប្រទេស ដោយលោកឧកញ៉ា ឌុល ភោគ ប្រធានអង្គការសប្បុរសធម៌ខ្មែរនៅសហរដ្ឋអាមេរិច កាណាដា អូស្ត្រាលី ញូស៊ីឡែន ស្វីស និងបារាំង។ ស្តូបនេះត្រូវបានកសាងរួចរាល់ក្នុងឆ្នាំ២០០៨ ហើយបានដាក់ឈ្មោះថា “បូជនីយដ្ឋានជាតិ”។ បូជនីយដ្ឋាននេះ ធ្វើអំពីថ្មដំបូលប្រក់ក្បឿងជាមួយរចនាបថខ្មែរ ដែលមានខឿនចំនួន ២ថ្នាក់ រំលេចដោយចម្លាក់លានព័ន្ធជុំវិញ ដែលមានអត្ថន័យរៀបរាប់អំពីរឿងរ៉ាវមួយចំនួន ដែលបានប្រព្រឹត្តនៅក្នុងសម័យខ្មែរក្រហម។ នៅផ្នែកខាងលើនៃខឿន គឺជាកន្លែងតម្កល់អដ្ឋិធាតុមានចំនួន ៧ថ្នាក់ បាំងដោយជញ្ជាំងថ្ម និងបង្ហួចកញ្ចក់បិទជិតជុំវិញ។[៦៩]



គំនូរនេះបង្ហាញអំពីរូបភាពស្តូបសម្រាប់តម្កល់អដ្ឋិធាតុ លើកទីបី ដែលកសាងអំពីថ្មប្រក់ក្បឿង រំលេចដោយ រចនាបថដំបូលបែបខ្មែរ។

អង្គការយុវសន្តិភាព

បានចូលរួមក្នុងការងារអប់រំប្រវត្តិសាស្ត្រខ្មែរក្រហម យុត្តិធម៌អន្តរកាល ការផ្សះផ្សា និងការងារនៃការចងចាំ តាមរយៈកិច្ចពិភាក្សាអន្តរជំនាន់ សិក្ខាសាលាបណ្តុះបណ្តាលយុវជន ទស្សនកិច្ចសិក្សា ការតាំងពិព័រណ៌ សិល្បៈគំនូរ និងសម្តែង វេទិការសាធារណៈ ការសិក្សាស្រាវជ្រាវ ការចងក្រងប្រវត្តិសាស្ត្រផ្ទាល់មាត់របស់ជនរងគ្រោះ ការផ្សព្វផ្សាយ ពិធីបុណ្យបែបសាសនា ការគាំទ្រផ្លូវចិត្ត ការងារអភិរក្សទីតាំងឧក្រិដ្ឋកម្ម និងការបង្កើតឱ្យមានមជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍។

ជំពូក៨

ការអភិរក្សអតីតមន្ទីរសន្តិសុខ វត្តសំរោងក្នុង

“ការចងចាំ ការអប់រំ ស្រាវជ្រាវ
ផ្សព្វផ្សាយ ការអភិរក្ស និងការបង្កើត
មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍”

អគារធ្វើទារុណកម្ម និងទិដ្ឋភាពជុំវិញ មុនពេលជួសជុល
និងអភិរក្សដោយអង្គការយុវសន្តិភាព មុនឆ្នាំ២០០៩។

១. ការចងចាំ អប់រំ ផ្សព្វផ្សាយ និងការអភិរក្ស

ការចាប់ផ្តើមការងារលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ការផ្សះផ្សា និងការចងចាំ នៅឆ្នាំ២០០៥ អង្គការយុវសន្តិភាពបានធ្វើការសិក្សាស្រាវជ្រាវក្រោមប្រធានបទ “ការប្រល័យពូជសាសន៍នៅក្នុងចិត្តរបស់យុវជនកម្ពុជា” ដែលមានយុវជនកម្ពុជាប្រហែល ២០០នាក់ បានចូលរួមនៅក្នុងការស្រាវជ្រាវនេះ។ គម្រោងស្រាវជ្រាវមានគោលបំណងឈ្វេងយល់អំពីកម្រិតចំណេះដឹង អាកប្បកិរិយា និងអារម្មណ៍យុវជនកម្ពុជា ចំពោះសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងអំពីរបៀបនៃការចងចាំអំពើប្រល័យពូជសាសន៍ដែលត្រូវបានផ្ទេរទៅជំនាន់របស់ពួកគេ។ តាមរយៈការស្រាវជ្រាវអង្គការយុវសន្តិភាព បានទទួលនូវការឆ្លើយតបរបស់យុវជនចំពោះអ្នករស់រានមានជីវិត និងរបៀបដែលកម្ពុជាបានជ្រើសរើស ដើម្បីដោះស្រាយអតីតកាលរបស់ខ្លួន។ ការស្រាវជ្រាវនេះបានផ្តល់នូវកម្លាំងរុញច្រានសម្រាប់អង្គការយុវសន្តិភាពធ្វើការងារដើម្បី“ផ្តល់អំណាចដល់យុវជនក្លាយជាពលរដ្ឋសកម្ម ដែលយល់និងអនុវត្តន៍វប្បធម៌សន្តិភាព”។ បន្ថែមលើនេះ ជាវេទិកាសម្រាប់យុវជន ដើម្បីឈ្វេងយល់និងពិភាក្សាអំពីរបបកម្ពុជាប្រជាធិបតេយ្យ។ ជាលទ្ធផល នៅឆ្នាំ២០០៧ អង្គការយុវសន្តិភាពបានរៀបចំគម្រោងយុវជនដើម្បីយុត្តិធម៌ និងការផ្សះផ្សា ដែលបានជួយយុវជនក្នុងការឈ្វេងយល់ ពិភាក្សា និងបង្កើតអាកប្បកិរិយាប្រកបដោយការគោរពចំពោះអតីតកាលដ៏សោកសៅនេះ។

នៅឆ្នាំ២០០៧ នៅខេត្តបាត់ដំបង គឺឆ្នាំដំបូងបំផុត ដែលអង្គការយុវសន្តិភាពបានបើកវគ្គបណ្តុះបណ្តាលដល់ក្រុមយុវជនជាសិស្ស និស្សិត និងព្រះសង្ឃកំពុងសិក្សានៅក្នុងខេត្តមួយនេះអំពី “ការឈ្វេងយល់ ការចងចាំ និងការផ្លាស់ប្តូរ” ក្នុងគោលបំណងអប់រំប្រវត្តិសាស្ត្រខ្មែរក្រហម យុត្តិធម៌អន្តរកាល ការផ្សះផ្សា និងការងារនៃការចងចាំ តាមរយៈសិក្ខាសាលា កិច្ចពិភាក្សាអន្តរជំនាន់ ទស្សនកិច្ចសិក្សា ការតាំងពិព័រណ៌ និងវេទិកាសាធារណៈ។

២. ការបង្កើតមជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍

- អ្វីជាមជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍?

មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍ គឺជាឈ្មោះមួយដែលអង្គការយុវសន្តិភាព បានបង្កើតឡើងនៅអំឡុងពេលនៃការសិក្សាស្រាវជ្រាវទៅលើកេរដំណែលនៃការចងចាំពីរបបខ្មែរក្រហម ដោយមានការពិភាក្សាពិគ្រោះយោបល់ពីសហគមន៍នៃតំបន់គោលដៅដូចជា ខេត្តតាកែវ បាត់ដំបង កំពត និងសន្និសីទសន្តិភាពថ្នាក់ជាតិនិងអន្តរជាតិ។ គោលដៅនៃមជ្ឈមណ្ឌលទាំងអស់ គឺជាទីកន្លែងដែលផ្តល់នូវការសិក្សាឈ្វេងយល់ពីរបបកម្ពុជាប្រជាធិបតេយ្យ ការចងចាំ ការផ្សះផ្សា ការស្វែងរកការពិត ដែលស្ថិតលើទីតាំងឧក្រិដ្ឋកម្មផ្ទាល់ និងនៅជិតៗទីតាំងឧក្រិដ្ឋកម្ម។

មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍កើតចេញមកពីការចូលរួមរបស់សហគមន៍ជុំវិញទីតាំងកាប់សម្លាប់ក្នុងសកម្មភាពដើម្បីអភិវឌ្ឍន៍ទីតាំងចងចាំរួមគ្នា ក្នុងគោលបំណងកែប្រែទីតាំងនៃការកាប់សម្លាប់ទាំងនោះ ទៅជាមជ្ឈមណ្ឌលសម្រាប់ការចងចាំ ការប្រាប់អំពីការពិត ការព្យាបាលរបួសផ្លូវចិត្ត និងការកសាងសន្តិភាព។ ដំណើរការនេះ បង្កើតបរិយាកាស និងលើកទឹកចិត្តប្រជាពលរដ្ឋ

ជាពិសេសជនរងគ្រោះឱ្យបង្ហាញរឿងរ៉ាវផ្ទាល់ខ្លួន និងធ្វើការងារ ជាមួយគ្នាក្នុងការខិតខំប្រឹងប្រែងរួម ដើម្បីទទួលបាននូវទស្សនៈ វិស័យ និងសកម្មភាពរួម។ វាបានបញ្ចូល ភាគីពាក់ព័ន្ធសំខាន់ៗក្នុង ការជជែកពិភាក្សាអំពីធាតុចូល និងគំនិតផ្តួចផ្តើមដើម្បីកសាង កេរដំណែលការចងចាំតាមរបៀបមួយ ដែលមានលក្ខណៈជាតំណាង និងប្រកបដោយអត្ថន័យសម្រាប់ជនរងគ្រោះ។

អគារមជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍ បានកសាង ឡើងនៅតាមទីតាំងឧក្រិដ្ឋកម្មចែកចេញជាបីបន្ទប់សំខាន់ៗរួមមាន បន្ទប់សារមន្ទីរឬបន្ទប់ពិព័រណ៌ បន្ទប់កិច្ចសន្ទនា និងបន្ទប់បណ្ណាល័យ។ មជ្ឈមណ្ឌលសិក្សាសន្តិភាព បានផ្តល់ អំណាចដល់ប្រជាសហគមន៍ រួមមានអ្នកពាក់ព័ន្ធសំខាន់ៗដូចជាអាជ្ញាធរមូលដ្ឋាន អ្នករៀបរំ អ្នកដឹកនាំ សាសនា ជនរងគ្រោះ និងយុវជនបានចូលរួមក្នុងដំណើរការទាំងមូល នៃការធ្វើផែនការ ការសាងសង់ និងការអនុវត្តកម្មវិធីរបស់មជ្ឈមណ្ឌល ដែលនាំទៅរកអភិបាលកិច្ចល្អ និងការមិនឱ្យកើតមានឡើងសាជាថ្មី នៃអំពើឃោរឃៅ និងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនាពេលអនាគត។

មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍ សាងសង់ឡើង ដើម្បី ជាទីកន្លែងសម្រាប់ចែករំលែកការលំបាក ភាពទុក្ខព្រួយ ការខកចិត្ត បទពិសោធន៍រឿងរ៉ាវផ្សេងៗពីអតីតកាល រក្សាទុកនូវរាល់ការចងចាំ ទាំងអស់ឱ្យនៅរស់រវើកសម្រាប់គ្រប់ៗជំនាន់។ ប្រជាជនអាចសិក្សា ស្រាវជ្រាវរៀនសូត្រ និងផ្លាស់ប្តូរចំណេះដឹង ជំនាញអំពីការដោះស្រាយ ទំនាស់ ការផ្សះផ្សា និងការកសាងសន្តិភាពជាដើម។

មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍ ផ្តល់ឱកាសការរៀន សូត្រពេញមួយជីវិត ដោយមិនគិតអំពីភេទ អាយុ ដើមកំណើត ឬ សមត្ថភាព។

៣.មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍សំរោងក្នុង

ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៤ ដោយអង្គការយុវសន្តិភាព ក្នុងគោលបំណងប្រែក្លាយអតីតមន្ទីរសន្តិសុខវត្តសំរោងក្នុង (គុក) ដែលជាកន្លែងឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់មនុស្ស ទៅជាកន្លែងរំលឹកនៃការចងចាំ កន្លែងពិភាក្សាសិក្សារៀនសូត្រអំពីប្រវត្តិសាស្ត្រ យុត្តិធម៌សង្គម ការផ្សះផ្សា និងសន្តិភាព ដោយរួមបញ្ចូលនូវការងារអភិរក្ស ការស្រាវជ្រាវ ការអប់រំផ្សព្វផ្សាយ និងជាមណ្ឌលព័ត៌មាន។

អង្គការយុវសន្តិភាព បានកសាងអគារមជ្ឈមណ្ឌលថ្មីមួយដែលមានបណ្តោយ ១៨ម៉ែត្រ ទទឹង ៧ម៉ែត្រ កម្ពស់ ៩.៥០ម៉ែត្រ សង់អំពីថ្ម ប្រក់ស៊ីប្រូ។ អគារនេះ បែងចែកជាបីបន្ទប់សំខាន់ៗ គឺ បន្ទប់ពិភាក្សា បន្ទប់សារមន្ទីរ និងបន្ទប់បណ្ណាល័យ។

- តើមជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍សំរោងក្នុងជាគម្រោងសំណងរដ្ឋប្បវេណីដោយរបៀបណា?

តបតាមការស្នើសុំពីអង្គការយុវសន្តិភាព អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (សាលាក្តីខ្មែរក្រម) បានប្រកាសសាលក្រមជាស្ថាពរ កាលពីថ្ងៃទី០៧ ខែ សីហា ឆ្នាំ២០១៤ ដោយសម្រេចបញ្ចូលមជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍មួយនេះ ជាគម្រោងសំណងរដ្ឋប្បវេណីសម្រាប់ជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅទូទាំងប្រទេសក្នុងសំណុំរឿង ០០២/០១ប្រឆាំងនឹងនួនជា និងខៀវ សំផន។

- តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការអនុវត្ត គម្រោងមជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍នេះ?

គម្រោងមជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍នេះ អង្គការយុវសន្តិភាពជាអ្នកទទួលខុសត្រូវលើការកសាង និងការអនុវត្តរាល់កម្មវិធី ដើម្បីធានាបម្រើផលប្រយោជន៍រួមដល់ជនរងគ្រោះយូរអង្វែង ស្របនឹងគោលបំណងនៃការស្នើសុំទៅតាន់តុលាការ។

- តើមជ្ឈមណ្ឌលសន្តិភាពសហគមន៍នេះដំណើរការយ៉ាងដូចម្តេច?

មានសកម្មភាពជាច្រើន ដែលអង្គការយុវសន្តិភាពបានអនុវត្តនៅទីនេះ។ សកម្មភាពទាំងនោះមានដូចជា៖ ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម យុត្តិធម៌អន្តរកាល កិច្ចពិភាក្សាអន្តរជំនាន់ ទស្សនកិច្ចសិក្សាទីតាំងឧក្រិដ្ឋកម្ម ការសិក្សាស្រាវជ្រាវ ការពិព័រណ៌ចល័ត ការបង្កើតកម្មវិធីផ្សះផ្សារបួសផ្លូវចិត្តរបស់ជនរងគ្រោះ ការងារអភិរក្ស និងការកែលម្អទីតាំងប្រវត្តិសាស្ត្រ និងគាំទ្រគំនិតផ្តួចផ្តើមពីសហគមន៍។ លើសពីនេះ ក៏មានកម្មវិធីផ្តល់នូវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពយុវជន និងក្រុមសមាជិកគណៈកម្មការអភិរក្សទីតាំងឧក្រិដ្ឋកម្ម អំពីការគ្រប់គ្រង ការដឹកនាំ ស្មារតីចងចាំ និងអភិរក្ស ការអប់រំសន្តិភាព ការដោះស្រាយទំនាស់ ការធ្វើផែនការ ការស្វែងរកការគាំទ្រ និងវិធីសាស្ត្រសិក្សាស្រាវជ្រាវជាដើម ដោយផ្សាភ្ជាប់ជាមួយគម្រោងគាំទ្រជាបន្តបន្ទាប់ពីអង្គការយុវសន្តិភាពទាំង ផ្នែកថវិកា និងបច្ចេកទេសដល់ក្រុមយុវជន និងក្រុមគណៈកម្មការ ក្នុងដំណើរថែរក្សាការពារទីតាំង និងការអប់រំប្រវត្តិសាស្ត្រ ដែលបានប្រព្រឹត្តិដោយខ្មែរក្រហម។



រូបភាពខាងមុខ

មាត្រដ្ឋាន ១/១០០



រូបភាពផ្នែក-ក-ក

មាត្រដ្ឋាន ១/១០០

អគារមជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍សំរោងក្នុង ស្ថិតក្នុងវត្តសំរោងក្នុង ភូមិសំរោងក្នុង ឃុំសំរោងក្នុង ស្រុកឯកភ្នំ ខេត្តបាត់ដំបង។

កំណត់សម្គាល់

១ ឌី ខាំបូលី,ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧-១៩៩៧៩), ភ្នំពេញ:មជ្ឈមណ្ឌលឯកសារកម្ពុជា, ឆ្នាំ២០០៧,ទំព័រ១៩។

២ អង្គជុំនុំជម្រះវិសាមញ្ញក្នុងតុលាកម្ពុជា, សាលក្រមនៃសំណុំរឿងលេខ០០២/០២,សំណុំរឿង លេខ០០២/១៩ កញ្ញា ២០០៧/អវតក/អជសជ ,ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨, ទំព័រ១៧៨។

៣ អង្គជុំនុំជម្រះវិសាមញ្ញក្នុងតុលាកម្ពុជា, សាលក្រមនៃសំណុំរឿងលេខ០០២/០២,សំណុំរឿង លេខ០០២/១៩ កញ្ញា ២០០៧/អវតក/អជសជ ,ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨, ទំព័រ២១៣-២១៨។

៤ លក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា, ឆ្នាំ១៩៧៦, ទំព័រ១-២។

៥ អង្គជុំនុំជម្រះវិសាមញ្ញក្នុងតុលាកម្ពុជា, សាលក្រមនៃសំណុំរឿងលេខ ០០២/០១,សាលក្រមលេខ០០២/១៩ កញ្ញា ២០០៧/អវតក/អជសជ ,ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៦, ទំព័រ៨៦-៨៧។

៦ ដេវីដឆេណ្ឌលើរ,សំឡេងពីមន្ទីរ ស-២១,បកប្រែស៊ូ ប៊ុនស៊ូ, មជ្ឈមណ្ឌលឯកសារកម្ពុជា, ភ្នំពេញ, ឆ្នាំ២០០៣, ទំព័រ៧៨-៨១។

៧ អង្គជុំនុំជម្រះវិសាមញ្ញក្នុងតុលាកម្ពុជា, សាលក្រមនៃសំណុំរឿងលេខ ០០២/០១,សាលក្រមលេខ០០២/១៩ កញ្ញា ២០០៧/អវតក/អជសជ ,ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៦, ទំព័រ១៥៥។

៨ អង្គជុំនុំជម្រះវិសាមញ្ញក្នុងតុលាកម្ពុជា,សាលក្រមនៃសំណុំរឿងលេខ០០២/០១,សាលក្រមលេខ០០២/១៩ កញ្ញា ២០០៧/អវតក/អជសជ ,ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៦, ទំព័រ១៥៦-១៥៧។

៩ ឌី ខាំបូលី,ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧-១៩៩៧៩), ភ្នំពេញ:មជ្ឈមណ្ឌលឯកសារកម្ពុជា, ឆ្នាំ២០០៧,ទំព័រ៥។

១០ ខាំបូលី,ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧-១៩៩៧៩), ភ្នំពេញ:មជ្ឈមណ្ឌលឯកសារកម្ពុជា, ឆ្នាំ២០០៧,ទំព័រ៧២-៧៩។

១១ ឌី ខាំបូលី,ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧-១៩៩៧៩), ភ្នំពេញ:មជ្ឈមណ្ឌលឯកសារកម្ពុជា, ឆ្នាំ២០០៧,ទំព័រ៥។

១២ អង្គជុំនុំជម្រះវិសាមញ្ញក្នុងតុលាកម្ពុជា,"សាលក្រមនៃសំណុំរឿងលេខ០០១", សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧/អវតក/អជសជ/ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ទំព័រ៥៤-៥៧។

១៣ ចម្លើយសារភាពនៅមន្ទីរស-២១ របស់ បួយ ហឿន

១៤ Meng-Try Ea, The chanin of terror: The Khmer Rouge Southwest Zone Security System (Phnom Penh: Documentation Center of Cambodia, 2005, ទំព័រ២-៣។

១៥ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង,៤០ឆ្នាំ៖ ការចងចាំជនរងគ្រោះស-២១, សីហា ២០១៩-២០២០ ឆ្នាំ,ទំព័រ៥០។

១៦ ក្រសួងសិក្សាធិការនៃកម្ពុជាប្រជាធិបតេយ្យ, ភូមិសាស្ត្រកម្ពុជាប្រជាប្រជាធិបតេយ្យ ផ្នែកនយោបាយ ថ្នាក់ទី៣, បោះពុម្ពលើកទី១,១៩៧៧,ទំព័រ៧ និង ៤៦-៥០។

១៧ ម្លើយសារភាពនៅមន្ទីរស-២១ ខែក ប៊ុន ហោ ស៊ូ ជាអនុលេខាតំបន់៤ ភូមិភាគពាយ័ព្យ, ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧។

ដេរីដឆេណ្ឌល័រ,សំឡេងពីមន្ទីរ ស-២១,បកប្រែស៊ូ ប៊ុនស៊ូ, ភ្នំពេញ, មជ្ឈមណ្ឌលឯកសារកម្ពុជា, ឆ្នាំ២០០៣,ទំព័រ៧៩។
១៨ ចម្លើយសារភាពនៅមន្ទីរស-២១ របស់ បួយ បឿន ប្រធានកងធំយោធាសន្តិសុខភាគពាយ័ព្យចាប់ខ្លួនថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៧៨។
១៩ ចម្លើយសារភាពនៅមន្ទីរស-២១ របស់ ជា ភាវ ហៅ កយ អនុប្រធានសន្តិសុខភូមិភាគពាយ័ព្យ,ឆ្នាំ១៩៧៧។ ចម្លើយសារភាព បួយ បឿន ប្រធានកងធំយោធាសន្តិសុខភាគពាយ័ព្យ,ឆ្នាំ១៩៧៨។ ចម្លើយសារភាពរបស់របស់ ឯម នុត ហៅ សុង អនុលេខាសន្តិសុខភាគពាយ័ព្យ,ឆ្នាំ១៩៧៨។
២០ ម្លើយសារភាពនៅមន្ទីរស-២១ របស់ រស់ ញឹម លេខាភូមិភាគពាយ័ព្យ,ខែក ប៊ុន ហៅ ស៊ូ ជាអនុលេខាតំបន់៤, ឆម យ៉ា នារសាតំបន់៤, តឹក ម៉ន ហៅ រ៉ៃ លេខាស្រុក៤១, សូ អ៊ុំ ប្រធានសហករណ៍ឃុំអន្លង់វិល។
២១ ទស្សនាវត្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា លេខ ១២ ខែធ្នូ ឆ្នាំ២០០០។ ធន់ សុវត្តិ អតីតព្រះសង្ឃវត្តសំរោងក្នុងដែលលាចាកសិក្ខាបទ ក្នុងខែមេសា ឆ្នាំ១៩៧៦,សម្ភាសន៍ដោយ ម៉ន សុគឿន,ឆ្នាំ២០១៩។
២២ ហួត របៀប, ប្រវត្តិវត្តសំរោងក្នុង,២០០៤, ទំព័រ២៦។ អង្គជុំនុំជម្រះវិសាមញ្ញក្នុងតុលាកម្ពុជា,ពុទ្ធសាសនានៅកម្ពុជា, សាលក្រមនៃសំណុំរឿងលេខ ០០២/០១,សាលក្រមលេខ០០២/១៩ កញ្ញា ២០០៧/អវតក/អជសជ ,ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៦ ទំព័រ២២៩។
២៣ អង្គជុំនុំជម្រះវិសាមញ្ញក្នុងតុលាកម្ពុជា, ការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងសុំណុំរឿង ០០២/១៩-០៩-២០០៧, ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩, ទំព័រ៥។
២៤ ចម្លើយសារភាពនៅមន្ទីរស-២១ របស់ សួន ឡុក ស្នងការ

អនុសេនាធំ ៤៥៣ វរសេនាតូច៤៥ ភូមិភាគ៣យ័ព្យចាប់ខ្លួន ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៧។
២៥ លោកតាអាចារ្យ ទឹម អតីតព្រះសង្ឃវត្តសំរោងក្នុងក្នុងរបប ខ្មែរក្រហម, បាត់ដំបង,សម្ភាសន៍ដោយ ម៉ន សុគឿន,២០១៩។
២៦ កាក់ សុខន អតីតអ្នកសេដ្ឋកិច្ច (បរទេះដឹកជញ្ជូន) ក្នុងសម័យ ខ្មែរក្រហម និងអ្នកអ្នកដែលបានជួយជីកប្រឡាយព្រះសង្ឃ នៅប្រឡាយលោក, សម្ភាសន៍ដោយ សុខ គឿន,ឆ្នាំ២០២២។ អាចារ្យ ទឹម និង ធន់ សុវត្តិ អតីតព្រះសង្ឃវត្តសំរោងក្នុង នៅក្នុងរបបខ្មែរក្រហម,សម្ភាសន៍ដោយ ម៉ន សុគឿន, ឆ្នាំ២០១៩។
២៧ ធន់ សុវត្តិ អតីតព្រះសង្ឃវត្តសំរោងក្នុងដែលលាចាកសិក្ខាបទ ក្នុងខែមេសា ឆ្នាំ១៩៧៦,សម្ភាសន៍ដោយ ម៉ន សុគឿន, ឆ្នាំ២០១៩។
២៨ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ,មហាសន្និបាតលើកទី៣, អនុមតិថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥,ប្រកាសឱ្យប្រើប្រាស់ជា ផ្លូវការថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦,មាត្រា២០ ទំព័រ១៥-១៦។
២៩ កាក់ សុខន , ធន់ សុវត្តិ,លោកអាចារ្យ ទឹម, អតីតព្រះសង្ឃវត្ត សំរោងក្នុង, សម្ភាសន៍ ដោយ ម៉ន សុខគឿន, ខេត្តបាត់ដំបង ឆ្នាំ២០១៩។ ឈុំ ជៀន អតីត អ្នកទោសម្នាក់,សម្ភាសន៍ដោយ សល់ រតនៈ និងខន រក្សា។ សុិប ស៊ីម អតីតអ្នកទោសម្នាក់ សម្ភាសន៍ដោយ សឿប ចិត្រា។ ឈាន គឿន អតីតកុមារអានឯកសារនៅបុស្តិ៍យោម, សម្ភាសន៍ ដោយ ហ៊ាង នីកា និង ហ៊ុន សេរីវឌ្ឍនា។ ឆេង ម៉ៅ អ្នកធ្លាប់ចូលក្នុងមន្ទីរសន្តិសុខ និងប្តីជា អ្នកទោសសម្ភាសន៍ដោយ អ៊ុន រិទ្ធី។ ភោគ ផូ អ្នកធ្លាប់ចូលក្នុង មន្ទីរសន្តិសុខ, សម្ភាសន៍ដោយ ហួត គីមហាក់, ខេត្តបាត់ដំបង ខែមេសា-ឧសភា ឆ្នាំ២០២២។ លោក វ៉ាន់ ថាន អតី អ្នកទោស ម្នាក់, សម្ភាសន៍ដោយ ខន រក្សា, ខេត្តកំពង់ឆ្នាំង,ថ្ងៃទី០៧ខែតុលា

ឆ្នាំ២០២២។ ជន រឿន អតីតអ្នកទោសម្នាក់, សម្ភាសន៍ដោយ ហ៊ិត ដារ៉ែត និងវីផល្លា, ខេត្តបាត់ដំបង,ខែមេសា ឆ្នាំ២០២៣។ ងិន ងួន អតីតអ្នកជួយសង្គ្រោះអ្នកទោស និង គីម ងួនជា អតីតព្រះសង្ឃ សម្ភាសន៍ដោយសុខ គឿន, ខេត្តបាត់ដំបង ឆ្នាំ២០១៤។

៣០ ម្តើយសារភាពនៅមន្ទីរស-២១ របស់ រស់ ញឹម លេខា ភូមិភាគ៣យ៉ាព្យ,ខែក ប៊ុន ហោ សូ ជាអនុលេខាតំបន់៤, ឆម យ៉ា នារសាតំបន់៤, តឹក ម៉ន ហោ រ៉ៃ លេខាស្រុក៤១, សូ អ៊ុំ ប្រធានសហករណ៍ឃុំអន្លង់វិល។

៣១ ឈុំ ជៀន អតីតអ្នកទោសម្នាក់,សម្ភាសន៍ដោយ សល់ រតន: និងខន រក្សា។ សុិប ស៊ីម អតីតអ្នកទោសម្នាក់ សម្ភាសន៍ដោយ សឿប ចិត្រា។ ឈាន គឿន អតីតកុមារអានឯកសារនៅបុស្តិ៍ យាម, សម្ភាសន៍ដោយ ហ៊ាង នីកា និង ហ៊ុន សេរីវឌ្ឍនា។ ឆេង ម៉ៅ អ្នកធ្លាប់ចូលក្នុងមន្ទីរសន្តិសុខ និងប្តីជាអ្នកទោស សម្ភាសន៍ដោយ អ៊ុន រិទ្ធី។ ភោគ ផូ អ្នកធ្លាប់ចូលក្នុងមន្ទីរ សន្តិសុខ, សម្ភាសន៍ដោយ ហួត គីមហាក់, ខេត្តបាត់ដំបង ខែមេសា-ឧសភា ឆ្នាំ២០២២។ លោក វ៉ាន់ ថាន អតី អ្នកទោស ម្នាក់, សម្ភាសន៍ដោយ ខន រក្សា, ខេត្តកំពង់ឆ្នាំង,ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២។ ជន រឿន អតីតអ្នកទោសម្នាក់, សម្ភាសន៍ ដោយ ហ៊ិត ដារ៉ែត និងវីផល្លា, ខេត្តបាត់ដំបង, ខែមេសា ឆ្នាំ២០២៣។

៣២ បញ្ជីឈ្មោះអ្នកទោសចូលនៅមន្ទីរស-២១ ក្នុងឆ្នាំ១៩៧៧។

៣៣,៣៤,៣៥,៣៦,៣៧,៣៨ ឈុំ ជៀន អតីតអ្នកទោសម្នាក់,សម្ភាសន៍ ដោយ សល់ រតន: និងខន រក្សា។ សុិប ស៊ីម អតីតអ្នកទោស ម្នាក់ សម្ភាសន៍ដោយ សឿប ចិត្រា, ខែមេសា-ឧសភា ឆ្នាំ២០២២។ វ៉ាន់ ថាន អតីតអ្នកទោសម្នាក់,សម្ភាសន៍ដោយ ខន រក្សា,កំពង់ឆ្នាំង, ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២។ ជន រឿន អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង ជាប់ឃុំក្នុង

អគាធម្មសភា សម្ភាសន៍ដោយ ហ៊ិត ដារ៉ែត និង វី ផល្លា, បាត់ដំបង, ខែមេសា ឆ្នាំ២០២៣។

៣៩, ៤០,៤១,៤២,៤៣ ឈុំ ជៀន អតីតអ្នកទោសម្នាក់,សម្ភាសន៍ដោយ សល់ រតន: និងខន រក្សា,ខេត្តបាត់ដំបង,ខែមេសា-ឧសភា ឆ្នាំ២០២២។ សុិប ស៊ីម អតីតអ្នកទោសម្នាក់ សម្ភាសន៍ដោយ សឿប ចិត្រា, ខែមេសា-ឧសភា ឆ្នាំ២០២២។ វ៉ាន់ ថាន អតីតអ្នកទោសម្នាក់,សម្ភាសន៍ដោយ ខន រក្សា,ខេត្តកំពង់ឆ្នាំង, ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២។ ឈ្នាង សួម អតីតអ្នកទោសម្នាក់ សម្ភាសន៍ដោយ សុខ គឿន,ខេត្តបាត់ដំបង ឆ្នាំ២០១៤។

៤៤ ឈាន គឿន អតីតកុមារអានឯកសារនៅបុស្តិ៍យាម, សម្ភាសន៍ដោយ ហ៊ាង នីកា និងហ៊ុន សេរីវឌ្ឍនា,ខេត្តបាត់ដំបង, ខែមេសា-ឧសភា ឆ្នាំ២០២២។

៤៥ អង្គជុំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, សាវនាការស្តាប់សក្ខីកម្មសាក្សី ប៉ែ ជុយ ជីពសែ អតីតអ្នកកាន់កាប់ញើ្ញឈ្មោះអ្នកទោសក្នុងមន្ទីរសន្តិសុខស្រុក ថ្ងៃទី១២ ខែវិច្ឆិកាឆ្នាំ២០១២។

៤៦ ឈុំ ជៀន អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង ,សម្ភាសន៍ ដោយ សល់ រតន: និងខន រក្សា។សុិប ស៊ីម អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង សម្ភាសន៍ដោយ សឿប ចិត្រា, ខេត្តបាត់ដំបង ខែមេសា-ឧសភា ឆ្នាំ២០២២។ វ៉ាន់ ថាន អតីត អ្នក នៅមន្ទីរសន្តិសុខវត្សសំរោងក្នុង,សម្ភាសន៍ដោយ ខន រក្សា,ខេត្តកំពង់ឆ្នាំង,ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២។ ឈ្នាង សួម អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្ត សំរោងក្នុង សម្ភាសន៍ដោយ សុខ គឿន,ខេត្តបាត់ដំបង ឆ្នាំ២០១៤។

៤៧ វ៉ាន់ ថាន អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង, ក្រោយមកជាអ្នករាប់អានគ្នាជាមួយប្រធានមន្ទីរសន្តិសុខវត្តសំរោងក្នុង ក្រោយត្រូវបានដោះលែង, សម្ភាសន៍ ដោយ ខន រក្សា,ខេត្តកំពង់ឆ្នាំង,ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២។

៤៨ ឈាន គឿន អតីតកុមារអានឯកសារនៅបុស្តិ៍យាម, សម្ភាសន៍ ដោយ ហ៊ាង នីកា និង ហ៊ុន សេរីវឌ្ឍនា,ខេត្តបាត់ដំបង, ខែមេសា-ឧសភា ឆ្នាំ២០២២។

៤៩ ឈុំ ជៀន អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្សសំរោងក្នុង, សម្ភាសន៍ ដោយ សល់ រតនៈ និង ខន រក្សា,ខេត្តបាត់ដំបង, ខែមេសា-ឧសភា ឆ្នាំ២០២២។ សុិប ស៊ីម អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង សម្ភាសន៍ដោយ សឿប ចិត្រា, ខេត្តបាត់ដំបង, ខែមេសា-ឧសភា ឆ្នាំ២០២២។ រ៉ាន់ ថាន អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង,សម្ភាសន៍ ដោយ ខន រក្សា,ខេត្តកំពង់ឆ្នាំង, ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២។ ឈ្នាង សួម អតីតអ្នកទោសម្នាក់ សម្ភាសន៍ដោយ សុខ គឿន,ខេត្តបាត់ដំបង ឆ្នាំ២០១៤។

៥០ រ៉ាន់ ថាន អតីត អ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង ,សម្ភាសន៍ដោយ ខន រក្សា,ខេត្តកំពង់ឆ្នាំង, ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២។ សុិប ស៊ីម អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង សម្ភាសន៍ដោយ សឿប ចិត្រា, ខេត្តបាត់ដំបង, ខែមេសា-ឧសភា ឆ្នាំ២០២២។

៥១ ឈុំ ជៀន អតីតអ្នកទោស នៅមន្ទីរសន្តិសុខវត្តសំរោងក្នុង ក្រោយមកត្រូវបានចាត់តាំងជាអ្នកប្រមូលលាមកអ្នកទោស និងជាអ្នកមើលថែសត្វគោ ,សម្ភាសន៍ ដោយ សល់ រតនៈ និង ខន រក្សា,ខេត្តបាត់ដំបង,ខែមេសា-ឧសភា ឆ្នាំ២០២២។

៥២ ឈ្នាង សួម អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង ជាប់ឃុំក្នុងអគាធម្មសភា សម្ភាសន៍ដោយ សុខ គឿន, ខេត្តបាត់ដំបង, ឆ្នាំ២០១៤។ ជន រឿន អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង ជាប់ឃុំក្នុងអគាធម្មសភា សម្ភាសន៍ដោយ ហ៊ុត ដារ៉ែត, ខេត្តបាត់ដំបង, ខែមេសា ឆ្នាំ២០២៣។

៥៣ ភោគ ផូ អ្នកធ្លាប់បានចូលក្នុងមន្ទីរសន្តិសុខវត្តសំរោងក្នុង និង

បានមើលឃើញទិដ្ឋភាពផ្ទាល់ក្នុងអគារឃុំឃាំងបណ្តោះ
អាសន្ននៃសាលាបាយ សម្ភាសន៍ដោយ អ៊ុន រិទ្ធី,ខេត្តបាត់ដំបង,
ខែមេសា-ឧសភា ឆ្នាំ២០២២។

៥៤, ៥៥, ៥៦ ឈុំ ជៀន អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្ត
សំរោងក្នុងត្រូវបានចាត់តាំងជាអ្នកប្រមូលលាមកអ្នកទោស
ជាអ្នកមើលថែសត្វគោ និងជាអ្នកស្នាក់នៅក្នុងអគារនេះផ្ទាល់,
សម្ភាសន៍ ដោយ សល់ រតនៈ និងខន រក្សា,ខេត្តបាត់ដំបង,
,ខែមេសា-ឧសភា ឆ្នាំ២០២២។

៥៧,៥៨ ឈុំ ជៀន អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្សរោងក្នុង,
សម្ភាសន៍ ដោយ សល់ រតនៈ និងខន រក្សា,ខេត្តបាត់ដំបង,
ខែមេសា-ឧសភា ឆ្នាំ២០២២។ សុប ស៊ីម អតីតអ្នកទោសនៅ
មន្ទីរសន្តិសុខវត្តសំរោងក្នុងសម្ភាសន៍ដោយ សឿប ចិត្រា
,ខេត្តបាត់ដំបង,ខែមេសា-ឧសភា ឆ្នាំ២០២២។ វ៉ាន់ ថាន អតីត
អ្នកទោស និងក្រោយមកធ្វើជាអ្នកជាំបាយនៅមន្ទីរសន្តិសុខ
វត្តសំរោងក្នុង,សម្ភាសន៍ដោយ ខន រក្សា, ខេត្តកំពង់ឆ្នាំង,
ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២។ ឈ្នាង សួម អតីតអ្នកទោស
នៅមន្ទីរសន្តិសុខវត្តសំរោងក្នុងសម្ភាសន៍ដោយ សុខគឿន,
ខេត្តបាត់ដំបង, ឆ្នាំ២០១៤។

៥៩ វ៉ាន់ ថាន អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង,
សម្ភាសន៍ដោយ ខន រក្សា,ខេត្តកំពង់ឆ្នាំង, ថ្ងៃទី០៧ ខែតុលា
ឆ្នាំ២០២២។ អាជ្ញាធរឃុំសំរោងក្នុង គណៈកម្មាធិការវត្ត និង
គណៈកម្មាធិការអភិរក្សទីតាំងឧក្រិដ្ឋកម្មវត្តសំរោងក្នុង ក្នុង
របបខ្មែរក្រហម សម្ភាសន៍ដោយអង្គការយុវសន្តិភាព
២០០៩-២០១៤។

៦០ សុប ស៊ីម អតីតអ្នកទោស នៅមន្ទីរសន្តិសុខវត្តសំរោងក្នុង និង
ជាអ្នកដែលយោធាទាំឱ្យទៅងូតទឹកនៅទីនោះ សម្ភាសន៍ដោយ
សឿប ចិត្រា, ខេត្តបាត់ដំបង, ខែមេសា-ឧសភា ឆ្នាំ២០២២។

[๖๑] ឈុំ ជៀន អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង និងជាប្រមូលលាមកអ្នកពីអគារឃុំឃាំងមកចាក់នៅមាត់ស្រះនេះរាល់ថ្ងៃ, សម្ភាសន៍ ដោយ សល់ រតន: និងខន រក្សា, ខេត្តបាត់ដំបង,ខែមេសា-ឧសភា ឆ្នាំ២០២២។

[๖๒] សុិប ស៊ីម អតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តសំរោងក្នុង និងជាអ្នកដែលយោធាប្រើឱ្យជីករណ្តៅ សម្ភាសន៍ដោយ សឿប ចិត្រា, ខេត្តបាត់ដំបង, ខែមេសា-ឧសភា ឆ្នាំ២០២២។

[๖๓, ๖๔, ๖๕, ๖๖, ๖๗, ๖๘, ๖๙] អាជ្ញាធរឃុំសំរោងក្នុង គណៈកម្មាធិការវត្ត និងគណៈកម្មការអភិរក្សទីតាំងឧក្រិដ្ឋកម្មវត្តសំរោងក្នុង ក្នុងរបបខ្មែរក្រហម អំពីដំណើរការរៀបចំគាស់អដ្ឋិធាតុ និងកសាងស្តូបរំលឹកនៃការចងចាំចាប់ពីអំឡុងឆ្នាំ១៩៨០, សម្ភាសន៍ដោយអង្គការយុវសន្តិភាព ២០០៩-២០១៤។

សន្ទានុក្រម

កងកុមារ : ក្រុមក្មេងៗដែលមានអាយុតិចជាង១៥ឆ្នាំ ដែលមាននាទីជួយផ្នែកខ្លះ ក្នុងវិស័យកសិកម្ម។

កងចល័ត :គឺជាកងយុវជន យុវនារី ដែលមានសុខភាពមាំមួន អាចបំពេញការងារនៅក្នុងរបបនោះបាន ដោយមានការចល័តពីកន្លែងមួយទៅកន្លែងមួយតាមបញ្ជា។

កម្ពុជាប្រជាធិតេយ្យ: ជាឈ្មោះផ្លូវការរបស់រដ្ឋកុម្មុយនីស្តមួយ(កម្ពុជា) ចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩។

ខុសសីលធម៌ :ជាការចោទប្រកាន់ចំពោះបុគ្គលទាំងឡាយណា មានទំនាក់ទំនងស្នេហា ឬផ្លូវភេទដោយមិនបានរៀបការក្នុងសម័យខ្មែរក្រហម។

ប្រជាជនថ្មីៗ : ជាប្រភេទប្រជាជនដែលត្រូវគេជម្លៀសចេញពីទីក្រុង ឬទីប្រជុំជននានាចាប់ពីថ្ងៃ១៧ មេសា ១៩៧៥ ឱ្យទៅកាន់ទីជនបទ ឬគេអាចហៅម៉្យាងទៀតបានថា ប្រជាជន ១៧ មេសា។

ប្រជាជនចាស់ ឬប្រជាជនមូលដ្ឋាន: ជាក្រុមប្រជាជន ដែលបានរស់នៅក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ពីមុនថ្ងៃ១៧ មេសា ១៩៧៥។

ភូមិភាគពាយ័ព្យ : ផ្ទៃដីនៃប្រទេសកម្ពុជារួមមានខេត្តពោធិសាត់ និងបាត់ដំបង និងមានតំបន់ព្រំពីរនៅក្រោមការគ្រប់គ្រង គឺតំបន់១ តំបន់២ តំបន់៣ តំបន់៤ តំបន់៥ តំបន់៦ និងតំបន់៧ ដែលមាន រស់ ញឹម ជាលេខា។

តំបន់រំដោះ : សំដៅទៅលើតំបន់ដែលបានកាន់កាប់ដោយ

កងទ័ពខ្មែរក្រហមនៅមុនថ្ងៃ១៧ មេសា ១៩៧៥។

សហករណ៍ : បណ្តុំប្រជាជន ដែលរស់នៅប្រមូលផ្តុំគ្នាជា សមូហភាព និង ធ្វើការងារកសិកម្មរួមគ្នា។

អង្គការ : សំដៅទៅលើសគណបក្សកុម្មុនីស្តកម្ពុជា។ ជាទូទៅ ពាក្យនេះមិនត្រូវបានគេប្រើសំដៅទៅលើបុគ្គលណាម្នាក់នោះទេ ទោះជាប្រជាជនសម័យនោះបានសំដៅលើបុគ្គលម្នាក់ៗ ក៏ដោយ។

លេខា : សំដៅលើតួរនាទីស្មើនឹងប្រធាន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

ឈ្លប : ភ្នាក់ងារស៊ើបការនៅក្នុងសហករណ៍ ដែលមានទាទីតាមដានប្រជាជននៅក្នុងភូមិ ឬសហករណ៍។

អនុលេខា : សំដៅតួនាទីស្មើនឹងអនុប្រធាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

កន្លែងអប់រំកែប្រែ : ជាកន្លែងដែលគេឃុំឃាំងមនុស្ស និងរៀបចំឱ្យធ្វើការងារ និងរៀបចំឱ្យធ្វើការងារ និងទទួលការតាមដានមុននឹងដោះលែង ឬបញ្ជូនទៅកាន់មន្ទីរសន្តិសុខ ឬក៏យកសម្លាប់ចោល។